01392288

E1/498.1

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber
Chambre de Premiere instance

**<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>**

**<u>ជំនុំជម្រះក្ដីនៅដំណាក់កាលពីរ</u>**

**<u>សាធារណៈ:-កោសលុប</u>**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦**

**ម៉ោង ០៩:១២នាទី**

**សវនាការលើកទី៤៧៩**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 17-Feb-2017, 10:58
CMS/CFO: Sann Rada

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន  ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី បម្រុង

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ

កញ្ញា អេវលីន ខាំផូស សង់ចេស

*(Ms. Evelyn CAMPOS SANCHEZ)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ស្រ៊ា រតនៈ

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms. Marie GUIRAUD)*

លោក ហុង គឹមសួន

លោក វ៉ែន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| លោក ស្រ៊ា រតនៈ | ខ្មែរ |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក វ៉ែន ពៅ | ខ្មែរ |
| សាក្សី 2-TCW-913 | ខ្មែរ |
| ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-235 | ខ្មែរ |

# ខ្លឹមសារ / ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី÷** 2-TCW-913


សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........ ទំព័រ ៥

សួរដោយលោក នីកូឡាស គូមជែន ផ្ដើមពី........ ទំព័រ ៧

សួរដោយលោក ហុង គីមសួន ផ្ដើមពី ........ ទំព័រ ៤២

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ........ ទំព័រ ៤៦

សួរដោយលោក គង់ សំអុន ផ្ដើមពី........ ទំព័រ ៥០


**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី÷** 2-TCCP-235


សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........ ទំព័រ ៥៩

សួរដោយលោក វ៉ែន ពៅ ផ្ដើមពី ........ ទំព័រ ៦០

សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្ដើមពី........ ទំព័រ ៧៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:១២:៤៦]

**ក្រឡាបញ្ជី៖**

អញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តាមកាលវិភាគដែលអង្គជំនុំជម្រះបានជម្រាបជូនភាគីកាលពីថ្ងៃទី០៨កន្លងមកនេះ គឺកំណត់ថា ថ្ងៃនេះអង្គជំនុំជម្រះធ្វើសវនាការបន្តស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន ហើយនិងមានសាក្សីបម្រុង 2-TCW-913។ ប៉ុន្តែដោយថ្ងៃគឺដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន គាត់មានបញ្ហាសុខភាព មិនអាចមកកាន់តុលាការបាន--។

មានបញ្ហាអីទៀត? មានបញ្ហា? បញ្ហាតែឯង?

*(ចៅក្រមពិភាក្សាគ្នា)*

សាជាថ្មីម្ដងទៀត តាមកាលវិភាគដែលអង្គជំនុំជម្រះបានកំណត់កាលពីថ្ងៃទី០៨ កន្លងមកនេះ ថានៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី -- សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន និងសាក្សី 2-TCW-913 ប៉ុន្តែដោយសារដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន នៅព្រឹកនេះគាត់មានបញ្ហាសុខភាព គាត់មិនអាចមកកាន់តុលាការបាន ហេតុដូច្នេះអង្គជំនុំជម្រះសម្រេចធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី 2-TCW-913។

[០៩:១៥:២៣]

ហើយមុននឹងចាប់ផ្ដើមដំណើរការ អង្គជំនុំជម្រះសុំជម្រាបជូនដំណឹងដល់ភាគីនៃរឿងក្ដីជ្រាបថា នៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ ហើយទំនងជាអាចបន្តរហូតទៅដល់ថ្ងៃស្អែក លោកចៅក្រម យូរ ឧត្តរា ដែលជាចៅក្រមជាតិ លោកអវត្តមានដោយមូលគាត់មានធុរៈចាំបាច់ផ្ទាល់ខ្លួន មិនអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះបាន ហើយយើងខ្ញុំបានពិគ្រោះយោបល់ជាមួយនឹងចៅក្រមពេញសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូង យើងសម្រេចតែងតាំងលោកចៅក្រម ធូ មណី ដែលជាចៅក្រមបម្រុងខាងភាគីជាតិជំនួសកន្លែងចៅក្រម យូរ ឧត្តរា ដែលបានអវត្តមាន ហើយរហូតដល់ពេលណា

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោកចៅក្រម យូរ ឧត្តរា មានវត្តមាន និងមានលទ្ធភាពចូលរួមបំពេញការងារក្នុងដំណើរការសវនាការនៅអង្គជំនុំជម្រះសាលាដំបូងវិញបាន។ ហើយការសម្រេចនេះ ផ្អែកលើបទប្បញ្ញត្តិនៃវិធាន៧៩(៤) នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ក្រឡាបញ្ជីសវនាការលោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគីនិងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន។ លើកលែងតែលោកស្រី អង់តា ហ្គីសសេ អវត្តមានដោយពុំបានជូនដំណឹងអំពីមូលហេតុ។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនា-ការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សាក្សីដែលនឹងត្រូវមកផ្ដល់សក្ខីកម្មនៅថ្ងៃនេះ មានរហស្សនាម 2-TCW-913។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីបានធ្វើសម្បថរួចហើយ នៅចំពោះមុខលោកតាដំបងដែកកាលពីព្រឹកមិញនេះ។ សាក្សីមានវត្តមានរួចហើយនៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សូមអរគុណលោកប្រធាន។

[០៩:១៧:៣៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា គាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះ ថាមានអាការៈឈឺចង្កេះជាប្រចាំ អង្គុយយូរកាន់តែឈឺខ្លាំង និងបានផ្តល់អនុសាសន៍ថា សុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

[០៩:១៩:០៧]

ហើយមុននឹងស្តាប់សក្ខីកម្មសាក្សី 2-TCW-913 អង្គជំនុំជម្រះកត់សម្គាល់ថា សាក្សីរូបនេះត្រូវបានស្តាប់ចម្លើយនៅក្នុងកិច្ចស៊ើបអង្កេតដែលកំពុងតែដំណើរការនៅក្នុងសំណុំរឿងផ្សេង។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកំណត់សាក្សីរូបនេះស្ថិតនៅក្នុងក្រុម"ក"នៃក្រុមទាំងបីប្រភេទនៅក្នុងអនុស្សរណៈរបស់ខ្លួន (មើលឯកសារE319/35) ហើយបានស្នើថាសាក្សីរូបនេះគួរប្រើរហស្សនាម ក្នុងគោលបំណងការពារនូវភាពសម្ងាត់នៃកិច្ចដំណើរការស៊ើបអង្កេត។ អង្គជំនុំជម្រះយល់ឃើញថាវិធានការមានកម្រិតបែបនេះ គឺត្រឹមត្រូវសមស្របតាមករណីបែបនេះ។ ហើយការបង្គាប់នេះ គឺត្រូវធ្វើឲ្យតុល្យភាពគ្នារវាងតម្រូវការនៃសាធារណភាពនៃសវនាការ ជាមួយនឹងការការពារសុចរិតភាពនៃការងារស៊ើបអង្កេត។ ហើយអង្គជំនុំជម្រះក៏សូមរំឭកដល់ភាគីដែរថា ឲ្យគោរពឲ្យបានខ្ជាប់ខ្ជួននូវសេចក្តីណែនាំចុះនៅក្នុងឯកសារ E319/7 ក្នុងការប្រើប្រាស់ឯកសារដាក់បង្ហាញពីសំណុំរឿងផ្សេង។

ហើយមុននឹងកោះអញ្ជើញសាក្សីមកចូលមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ ដោយឯកសារពាក់ព័ន្ធហ្នឹង គឺមិនទាន់ទទួលយកឯកសារភស្តុតាង គឺឥឡូវនេះ អង្គជំនុំជម្រះសម្រេចទទួលយកឯកសារទាំងនេះ ធ្វើជាឯកសារភស្តុតាង។ ទី១ គឺឯកសារ E319/23.3.38 ហើយឯកសារហ្នឹងគឺ

មានឧបសម្ព័ន្ធភ្ជាប់គឺ E319/23.3.38.1 និងមួយទៀតគឺ E319/23.3.38.2។ ឯកសារទី២ គឺ E319/23.3.33។ ឯកសារនេះមានឧបសម្ព័ន្ធ ឯកសារភ្ជាប់ចំនួនបួន គឺ១ E319/23.3.39.1, ទី២ គឺ E319/23.3.39.2, ឯកសាភ្ជាប់ទី៣ គឺ E319/23.3.29.3 និងឯកសារទី៤ គឺ E319/23.3.39.4។ និងឯកសារទី៣គឺ E319/23.3.40 ឯកសារនេះគឺមានឯកសារជាឧបសម្ព័ន្ធភ្ជាប់ គឺឯកសារ E319/23.3.40.1។ ហើយឯកសារទាំងនេះ អង្គជំនុំជម្រះដាក់លេខ E3 ហើយនិងជូនដំណឹង ជូនដល់ភាគីពាក់ព័ន្ធតាមរយៈអ៊ីម៉ែលនាពេលក្រោយបន្តិចទៀតនេះ។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី 2-TCW-913 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:២២:៤៦]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ដំបូងខ្ញុំសូមធ្វើការកែតម្រូវតូចមួយ ទាក់ទងទៅនឹងអវត្តមានរបស់សហមេធាវីអន្តរជាតិ ការពិតគាត់បានជូនដំណឹងរួចហើយ តាំងពីថ្ងៃទី០៨ ខែនេះ មុនពេលសម្រាកនេះ។ ទី២ ទាក់ទងនឹងឯកសារដែលលោកបានប្រធានលើកអម្បាញ់មិញនេះ តើជាការប្រើប្រាស់របស់អង្គជំនុំជម្រះ ឬភាគីអាចប្រើប្រាស់ឯកសារទាំងអស់នោះដែរ?

**ប្រធានអង្គជំនុំ៖**

បាទ នេះ អង្គជំនុំជម្រះសម្រេចទទួលយកជាភស្តុតាង សម្រាប់សួរដេញដោលរូបនេះ ដោយសារឯកសារនេះគឺ មាននៅក្នុងឯកសារផ្សេង ដែលមិនទាន់បានទទួលយកជាឯកសារភស្តុតាង។ អង្គជំនុំជម្រះសម្រេចទទួលយកជាឯកសារភស្តុតាង គ្រាន់តែលេខ E3 ហ្នឹងគឺមិនទាន់ដាក់មិនទាន់ ឥឡូវហ្នឹង គឺអង្គជំនុំជម្រះនឹងជម្រាបជូនភាគីតាមក្រោយ។ អ៊ីចឹងគឺឯកសារភស្តុតាង។ មានន័យថា ភាគីពាក់ព័ន្ធទាំងអស់ហ្នឹង គឺយកជាមូលដ្ឋាន ក្នុងការពិភាក្សាដេញដោលសាក្សីរូបនេះ។

[០៩:២៤:០៩]

**ប្រធានអង្គជំនុំ៖**

សួស្តីលោកសាក្សី នៅក្នុងកិច្ចដំណើរការសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ តាមសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ យើងនឹងប្រើប្រាស់តែរហស្សនាមរបស់លោកតែប៉ុណ្ណោះ

ហើយលោកសាក្សីមានរហស្សនាម 2-TCW-913។ ហើយជាទូទៅ និងតាមធម្មតា គឺភាគីតែងតែប្រើប្រាស់ហៅលោកក្នុងនាមជាសាក្សីតែប៉ុណ្ណោះ។ អ៊ីចឹងហើយ សូមលោកយល់ថា អង្គជំនុំជម្រះនឹងមិនអនុញ្ញាតឲ្យភាគីពាក់ព័ន្ធ រួមទាំងអង្គជំនុំជម្រះខ្លួនឯង ប្រើនាមត្រកូល និងនាមខ្លួនរបស់លោកជាសាធា-រណៈនៅក្នុងសវនាការនេះឡើយ។

ហើយមន្ត្រីរដ្ឋបាលតុលាការយកឯកសារនេះ ទៅជូនលោកសាក្សីពិនិត្យ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** តទៅនេះ អង្គជំនុំជម្រះសូមឲ្យលោកពិនិត្យ និង បញ្ជាក់អត្តសញ្ញាណរបស់លោកដែលមាននៅក្នុងឯកសារ E319/23.3.38 ដែលមានលេខ ERN ជាភាសាខ្មែរ 00979421, ERN ជាភាសាអង់គ្លេស 00983531 និង ERN ជាភាសាបារាំង 01123513។ សូមលោកសាក្សីពិនិត្យមើលហ្នឹងកន្លែងដែលមាន*ហាយឡាយ*ពណ៌ទឹកក្រូច តើឈ្មោះលោក គឺនាម និងគោត្តនាម ឬនាមត្រកូលរបស់លោក សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត មុខរបរ ឈ្មោះឪពុក ឈ្មោះម្ដាយ ឈ្មោះប្រពន្ធរបស់លោក និងចំនួនកូនរបស់លោក ពិតជាត្រឹមត្រូវដែរឬទេ? ហើយលោកសាក្សីឆ្លើយគ្រាន់តែឆ្លើយថា ការសរសេរនេះគឺជាត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវតែប៉ុណ្ណោះ។ សាក្សី! តើលោកអាចមានព័ត៌មាននៅក្នុងឯកសារនេះ គឺត្រឹមត្រូវដែរឬទេ សរសេរបែបនេះ?

[០៩:២៦:៥៣]

**2-TCW-913៖**

**ឆ៖** បាទ លោកប្រធាន ពិតជាត្រឹមត្រូវពិតមែន ក្នុងសរសេរឯកសារហ្នឹង ពិតច្បាស់លាស់មែន លោកប្រធាន។

**ស៖** លោកសាក្សី តើលោកមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបលោក នួន ជា និង លោក ខៀវ សំផន និងភាគីទាំងឡាយដែលទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះដែរឬទេ តាមសមត្ថភាពដែលលោកដឹង គឺសំណុំរឿង០០២? តើលោកមានជាប់ញាតិសន្តាន ឬក៏ញាតិលោហិត ញាតិពន្ធអីដែរទេ?

**ឆ៖** បាទ លោកប្រធាន អត់មានជាប់ពាក់ព័ន្ធអីនឹងលោហិត ញាតិសន្តាន ខៀវ សំផន ទេ អត់មានទេ។

01392297



**សៈ** លោកបានធ្វើសម្បថហើយនៅ មុននឹងចូលមកចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ?

**ឆៈ** បាទ ធ្វើរួចហើយ។

[០៩:២៨:២១]

**សៈ** បាទ អរគុណ។ ហើយតទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងឋានៈលោកជាសាក្សី នៅចំពោះមុខអង្គជំនុំជម្រះ។ លោកសាក្សី ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកមានសិទ្ធិបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬការសុំឲ្យលោករៀបរាប់ អត្ថាធិប្បាយដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ អំពីករណីយកិច្ច ក្នុងឋានៈជាសាក្សីលោកត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតប ឬក៏ការធ្វើអត្ថាធិប្បាយដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិសម្រាប់សាក្សីរួចហើយអម្បាញ់មិញនេះ។

ក្នុងឋានៈជាសាក្សី ត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគី ឬក៏ចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

លោកសាក្សី តើលោកធ្លាប់បានផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ រយៈពេលកន្លងមក? ប្រសិនបើធ្វើ ធ្វើប៉ុន្មានដង? ធ្វើនៅទីកន្លែងណា លោកចាំដែរទេ?

**ឆៈ** ធ្វើបានពីរដង ប៉ុន្តែខ្ញុំភ្លេចដែរហើយ។

**សៈ** ធ្វើនៅកន្លែងណាដែរ លោកចាំដែរទេ? មកធ្វើៗនៅកន្លែងណា នៅ?

**ឆៈ** ធ្វើនៅសាលានេះ ខ្ពស់ មើលឃើញ។

[០៩:២៩:៥៩]

**សៈ** បាទ អរគុណ។ ហើយមុននឹងចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ តើលោកសាក្សីបានពិនិត្យមើលឃើញ បានអាន គឺកំណត់ហេតុដែលលោកបានផ្តល់សក្ខីកម្មកាលពីពីរដងកាលពីពេលមុន ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆៈ** ពិតមែន ខ្ញុំបានអានពិតមែន។

**សៈ** តាមសមត្ថភាពដែលលោកអាចដឹងនិងចងចាំបាន តើលោកអាចបញ្ជាក់បានដែរទេថា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

កំណត់ហេតុស្តាប់សក្ខីកម្មដែលលោកបានអាន ដើម្បីរំឭកការចងចាំនោះ គឺពិតជាត្រឹមត្រូវ សមស្របស៊ីសង្វាក់គ្នាទៅនឹងកិច្ចសម្ភាសន៍ដែលលោកបានផ្តល់ជាមួយនឹងអ្នកស៊ើបអង្កេត កាលពីពីរដងលើកមុននោះដែរឬទេ?

**ឆ៖** ពិតមែន ខ្ញុំអានឯកសារនុ៎ងគឺបានពិតប្រាកដមែន។ ហើយខ្ញុំក៏បានភ្លេចខ្លះអីខ្លះ ប៉ុន្តែខ្ញុំអានធ្លាប់អានមក កន្លងមក គឺបានអាននិងមើលទៅវាតាមគេណែនាំខ្ញុំរៀនសូត្រហ្នឹង ពីថ្ងៃនុ៎ងទៅ ខ្ញុំចំណាំបានប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយក្នុងការសួរដេញដោលសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួននៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្តី។ សហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលសរុបពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរដេញដោលសាក្សីរូបនេះ។ សូមអញ្ជើញ!

[០៩:៣១:៤៥]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ ខ្ញុំចង់ឲ្យលោកជួយប្រាប់បន្តិច មិនចាំបាច់ប្រាប់អំពីឈ្មោះភូមិឃុំទេ ប៉ុន្តែចង់ឲ្យប្រាប់ថាតើក្រុមគ្រួសារលោកមកពីភូមិភាគណា? ឧទាហរណ៍ថាភូមិភាគ<និរតី> ឬក៏ពាយ័ព្យជាដើមហ្នឹង តើគ្រួសារលោកមកពីភូមិភាគខាងណាដែរ?

**2-TCW-913៖**

**ឆ៖** បាទ មកពីភូមិភាគបូព៌ា។

**ស៖** នៅក្នុងពេលសង្គ្រាម គឺបានន័យថានៅក្នុងរបស់ លន់ នល់ ថាតើលោកមានការងារ ឬក៏លោកមានតួនាទីអ្វីដែរ?

**ឆ៖** បាទ ខ្ញុំនៅជំនាន់របបកើតសង្គ្រាម មកនៅជំនាន់ លន់ នល់ ខ្ញុំធ្វើជាកសិករ ធ្វើស្រែចម្ការអត់មានធ្វើអ្វីទេ។

**ស៖** តើលោកធ្លាប់បួសជាព្រះសង្ឃទេ?

**ឆ៖** បាទ ខ្ញុំបួស៣ឆ្នាំ ព្រះសង្ឃ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** លោកឆ្លើយថា លោកបួសជាព្រះសង្ឃ៣ឆ្នាំ ប៉ុន្តែខ្ញុំចង់ដឹងថាតើលោក<ឈប់បួសជាសង្ឃ>នៅពេលណាដែរ នៅឆ្នាំណាដែរ? <>

**ឆ៖** ខ្ញុំបួស ៗជាព្រះសង្ឃហ្នឹងវាមួយពាន់ប្រាំបួនរយ -- អ្ហ៎! ៧៣ ខ្ញុំបួសព្រះសង្ឃ ខ្ញុំភ្លេច។ ហើយខ្ញុំសឹកវិញនៅ៧៥ ឆ្នាំ១៩៧៥។

[០៩:៣៣:៤២]

**ស៖** នៅថ្ងៃ១៧ មេសា ៧៥ គឺនៅពេលដែលភ្នំពេញធ្លាក់ក្នុងរបបខ្មែរក្រហមហ្នឹង តើលោកនៅជាព្រះសង្ឃនៅឡើយ ឬក៏លោកសឹករួចទៅហើយ?

**ឆ៖** ខ្ញុំនៅជាព្រះសង្ឃ។

**ស៖** តើនៅថ្ងៃ១៧ មេសា ៧៥ហ្នឹង លោកគង់នៅទីណាដែរ?

**ឆ៖** គង់នៅវត្តតាសួស ភូមិត្រស់ ស្រុករមាសហែក ខេត្តស្វាយរៀង។

**ស៖** តើនៅក្នុងវត្តហ្នឹងមានព្រះសង្ឃគង់នៅច្រើនដែរឬទេនៅពេលហ្នឹង? តើលោកអាចប្រាប់ពីចំនួនព្រះសង្ឃដែលគង់នៅក្នុងវត្តនោះ ក្នុងពេលនោះបានទេ?

**ឆ៖** នៅក្នុងពេលឆ្នាំ៧៥ហ្នឹងមានព្រះសង្ឃនៅប្រហែលជា១៩អង្គ ទាំងសាមណេរ ទាំងភិក្ខុ។

**ស៖** ចុះនៅក្រោយ<ខែ>មេសា ៧៥ហ្នឹង <តើមានអ្វីកើតឡើងចំពោះលោក និងព្រះសង្ឃផ្សេងទៀត?> តើដោយសារមូលហេតុអ្វី ទើបលោកសឹកឈប់បួសជាព្រះសង្ឃនោះ?

**ឆ៖** មូលហេតុមកវាសឹកគឺជាព្រះសង្ឃហ្នឹង គេបណ្ដេញឲ្យខ្ញុំសឹក។ ពួកខ្មែរក្រហមបណ្ដេញឲ្យខ្ញុំសឹក បណ្ដេញឲ្យសឹកអស់ទូទាំងវត្តតាសួសទាំងមូល។ អ៊ីចឹងទេខ្ញុំរស់នៅអត់បាន ត្រូវចៀសវាងសឹក។ គេមិនឲ្យនៅតទៅមុខទៀត។

**ស៖** តើលោកអាចប្រាប់ឲ្យលម្អិតបន្តិចបានទេ តើគេផ្សឹកលោកពីព្រះសង្ឃហ្នឹង គឺគេផ្សឹកដោយរបៀបណាដែរ?

[០៩:៣៨:០៧]

**ឆ៖** គេផ្សឹកពួកយើងខ្ញុំនៅជាលោកហ្នឹង គេផ្សឹក គេបង្ខំចិត្តដោយបង្ខំ គេឲ្យសឹក។ គេមិនទុកឲ្យនៅតទៅមុខទៀត ដើម្បីគេផ្សឹក ដើម្បីគេបំបាត់ព្រះពុទ្ធសាសនារបស់យើង។ គេអត់ឲ្យមាននៅតទៅមុខទៀត ដឹកផ្សឹកឲ្យអស់ពីវត្តអាវ៉ាម។

**ស៖** តើក្រោយថ្ងៃ១៧ មេសា ៧៥ហ្នឹង តើប៉ុន្មានសប្ដាហ៍ ឬក៏ប៉ុន្មានខែដែលគេចាប់ផ្ដើមបង្ខំឲ្យ

លោកផ្សឹកនោះ? តើប៉ុន្មានខែ ឬក៏ប៉ុន្មានអាទិត្យដែរក្រោយថ្ងៃ១៧ មេសា ៧៥?

**ឆ៖** គេបង្ខំខ្ញុំប្រហែលជារយៈពេលប្រហែលជាមួយខែ។ គេប្រាប់ពីរដងបីដង ឲ្យសឹក បើយើងមិនសឹកទេ គេមិនព្រម។ គេត្រូវតែឲ្យយើងសឹកជាបន្ទាន់ ដើម្បីគេបោសសម្អាតកុំឲ្យមានព្រះសង្ឃនៅក្នុងវត្ត។ បើយើងនៅតទៅមុខទៀត អត់បាន។ អង្គការ គេមិនឲ្យនៅតែម្តង។ អ៊ីចឹងទេយើងត្រូវដាច់ខាត ចៀសវាងត្រូវសឹក កុំឲ្យមានគ្រោះថ្នាក់ គេធ្វើបាបលោកសង្ឃ។

**សៈ** សូមអរគុណ។ តើលោកអាចប្រមាណមើលថាតើនៅខែណាដែរ ក្នុងឆ្នាំ៧៥នោះ?

**ឆ៖** នៅក្នុងខែ ៧៥ ខែមេសា ៧៥ ផ្សឹក។

**សៈ** ក្រោយពេលដែលគេផ្សឹកលោករួចហើយ តើលោកធ្វើអ្វីបន្តទៀត?

**ឆ៖** គេផ្សឹកខ្ញុំរួចហើយ គេឲ្យមកចូលជាសហករណ៍ធ្វើស្រែចម្ការនៅក្នុងសហករណ៍ ដើម្បីស្ទូងដក ធ្វើស្រែចម្ការ។

**សៈ** តើលោកអាចប្រាប់បានទេ តើនៅសហករណ៍ណាដែរ?

**ឆ៖** បាទ នៅសហករណ៍ភូមិបឹង នៅក្នុងសហករណ៍ភូមិបឹង ភូមិរបស់ខ្ញុំដដែល។

[០៩:៣៨:៣៤]

**សៈ** តើលោកនៅក្នុងសហករណ៍ហ្នឹងអស់រយៈពេលប៉ុន្មានខែ ប៉ុន្មានឆ្នាំដែរ? ហើយបន្ទាប់មកទៀត លោកទៅណាដែរ?

**ឆ៖** បាទ នៅក្នុងសហករណ៍នៅរយៈពេលអស់ប្រហែលជាពីរបីខែប៉ុណ្ណឹងទេ។ ហើយគេក៏បញ្ជូនខ្ញុំឲ្យមកធ្វើរោងចក្រនៅទីក្រុងភ្នំពេញ។ បញ្ជូន ពេលបញ្ជូននោះ សក់ខ្ញុំទើបនឹងដុះខ្លីៗមិនទាន់វែងផង។ សក់ខ្ញុំនៅខ្លីៗ មិនទាន់ដុះវែងទេ បញ្ជូនមក ឲ្យចូលមកភ្នំពេញ ដើម្បីធ្វើជាកម្មកររោងចក្រ។ តែខ្ញុំមិនដឹងរោងចក្រអីទេ គេគ្រាន់តែថាប៉ុណ្ណឹង ឲ្យចូលមកធ្វើកម្មកររោងចក្រ។

**សៈ** តើនៅពេលដែលលោកមកដល់ភ្នំពេញហ្នឹង មានអ្វីកើតឡើងចំពោះលោកដែរ?

**ឆ៖** បាទ មកដល់ភ្នំពេញហ្នឹង គេឲ្យនៅចិញ្ចឹមជ្រូក ចិញ្ចឹមទានៅក្នុងកន្លែងសាលាបាក់ទូកសាលាបុរីកីឡាហ្នឹង គេឲ្យចិញ្ចឹមមាន់ ចិញ្ចឹមទា ចិញ្ចឹមជ្រូក ហើយនិងដាំបាយ ដាំអីហូបគ្នាឯងមកពីនុំងមក។ មកនុំងច្រើនដែរ ប៉ុន្តែខ្ញុំអត់ចាំ មិនដឹងមកពីខេត្តណាខ្លះ មករស់នៅជាមួយគ្នាហ្នឹង។ មកកាលនុំង មកនៅបុរីកីឡា ហើយនិងសាលាបាក់ទូក។ តែខ្ញុំមិនទាន់បានជាធ្វើអីធំដុំទេ គ្រាន់តែមកហ្នឹង គ្រាន់តែមកចិញ្ចឹមសត្វជ្រូក មាន់ទានៅកន្លែងហ្នឹង។

**ស៖** មុនពេលដែលលោកទៅទីក្រុងភ្នំពេញ តើលោកមានបានចូលរួមវគ្គរៀនសូត្រនយោបាយ ឬក៏វគ្គបណ្ដុះបណ្ដាលអីផ្សេងទេ?

[០៩:៤០:៣៦]

**ឆ៖** បាទ វាឲ្យខ្ញុំធ្វើប្រវត្តិរូប ឲ្យខ្ញុំធ្វើប្រវត្តិរូប មកដល់វាឲ្យធ្វើប្រវត្តិរូបទៅ ដើម្បីវាចាត់តាំងឲ្យធ្វើការងារខាងដំបាយ បម្រើភ្ញៀវអីចឹង។ ហ្នឹងនៅក្នុងបុរីកីឡា ចិញ្ចឹមទាផង ចិញ្ចឹមជ្រូកផង ហើយនិងបម្រើបាយពួកគេមកពីរៀនសូត្រ មកពីខេត្តណាៗនេះ ខ្ញុំ គេឲ្យពួកខ្ញុំអ្នកដាំបាយ អ្នកបម្រើភ្ញៀវ។ ទទួលបាយគេ បាយទឹកគេ នៅហ្នឹង ក្នុងបុរីកីឡាហ្នឹង។ ខ្ញុំឆ្លើយខ្លីៗប៉ុណ្ណឹង លោកប្រធាន។

**ស៖** សូមអរគុណលោក។ ខ្ញុំចង់សួរអ៊ីចេះ តើលោកមានបានឆ្លងកាត់វគ្គរៀនសូត្រអ្វីទេ មុនពេលដែលលោកទៅទីក្រុងភ្នំពេញ គឺថាមុនពេលដែលលោកទៅធ្វើការនៅបុរីកីឡានោះ?

**ឆ៖** បាទ អត់ដែលមានទេ។ អត់ដែលមានបើកវគ្គរៀនសូត្រអីអត់មានទេ។ ព្រោះយើងទើបតែមកដល់ថ្មី គ្មានបានរៀនសូត្រទេ។ គ្រាន់តែគេឲ្យចាត់តាំងឲ្យយើងដាំបាយបម្រើភ្ញៀវបម្រើអីហ្នឹង មានពិតមែន។ ដូច្នេះវគ្គធំតូច អត់ដែលបានរៀនសូត្រទេ។

**ស៖** នៅបុរីកីឡាហ្នឹង តើបុរីកីឡាហ្នឹងជាកន្លែងអីដែរ នៅពេលដែលគេចាត់តាំងឲ្យលោកទៅនោះ?

**ឆ៖** កន្លែងបុរីកីឡាហ្នឹង គឺកន្លែងជំនាន់ហ្នឹង គេមកហៅ កម្មាភិបាលរបស់គេ គេមករៀនសូត្រហ្នឹង មិនដឹងមកពីខេត្តណាខ្លះ។ ខ្ញុំអ្នកបម្រើបាយ បម្រើភ្ញៀវហ្នឹង មិនដែលចូលជិតគេផង អត់ដឹង។ បានតែពេលបម្រើបាយបម្រើអីគេហ្នឹង ពេលដល់បាយទៅ ផ្ដុំកញ្ចែទៅ ឲ្យគេចូលហូបទៅ។

[០៩:៤២:៤៥]

**ស៖** លោកឆ្លើយថា កម្មាភិបាលជាអ្នក -- កម្មាភិបាលត្រូវចូលរួមនៅវគ្គហ្នឹង។ ថាតើនៅកន្លែងបុរីកីឡាហ្នឹង គេបើកវគ្គបណ្ដុះបណ្ដាលហ្នឹង តើវាជា<អគារមួយ> ឬក៏គេធ្វើនៅកណ្ដាលវាល ឬក៏យ៉ាងម៉េចដែរ កន្លែងរៀនសូត្រនោះ?

**ឆ៖** ទៅដល់ផង។ ខ្ញុំគ្រាន់តែដឹងខ្ញុំអ្នកបម្រើបាយ ខ្ញុំអត់ដែលទៅដល់ទេ ប៉ុន្តែគេថា បម្រើភ្ញៀវរបស់គេមករៀនសូត្រ ក្នុងបុរីកីឡា។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមទោស។ តើលោកអាចឆ្លើយឡើងវិញម្ដងទៀតទេ ព្រោះអ្នកបកប្រែគាត់បកអត់ទាន់អ្វីដែល

លោកឆ្លើយដំបូងនោះ ព្រោះលោកឆ្លើយលឿនពេក។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ឥឡូវអ៊ីចេះវិញ លោកសាក្សី គឺថាមិនមែនជាកំហុសលោកទេ ដោយសារលោកឆ្លើយលឿននោះ។ ដូច្នេះប្រសិនបើខ្ញុំចាំមិនខុសទេ ខ្ញុំចង់សួរលោកអ៊ីចេះ នៅបុរីកីឡាហ្នឹង តើវាជាអគារបិទជិត ឬមួយក៏ជាវាលចំហដែលគេបើកវគ្គរៀនសូត្រហ្នឹង លោកចាំទេ?

2-TCW-913៖

**ឆ៖** បាទ លោកប្រធាន អត់បិទជិតទេ។ វារៀនសូត្រនោះ បើកចំហដែរ គ្រាន់តែកន្លែងសាលាគេវាធំដែរ សាលាគេធំ កន្លែងនោះ។ តែអត់មានបានបិទអីជិតទេ នៅរៀនក្នុងនុ៎ង។ អ៊ីចឹងតាមខ្ញុំមើលឃើញប៉ុណ្ណឹង។

**ស៖** អ៊ីចឹង តើកន្លែងរៀនសូត្រហ្នឹងវាមានដំបូល វាមានជញ្ជាំងអីបិទដែរឬទេ ឬមួយក៏ចំហវាល?

[០៩:៤៤:៣៩]

**ឆ៖** បាទ មានដំបូល មានដំបូលបិទជិត អត់នៅកណ្ដាលវាលរហោឋានទេ។ មានដំបូល មានកៅអី មានតុទូគេរៀនសូត្រនោះ។

**ស៖** នៅពេលដែលគេចាត់តាំងឱ្យលោកធ្វើការងារនៅទីនោះ តើលោកធ្លាប់ឆ្លងកាត់វគ្គរៀនសូត្រនយោបាយដែរឬទេ?

**ឆ៖** បាទ អត់ដែលផង។ គ្រាន់តែគេឱ្យយើងបម្រើភ្ញៀវ ដាំបាយ ដាំទឹកបម្រើហ្នឹង អត់ដែលបានចូលរៀនទេ មកដល់កន្លែងនុ៎ង។ ជាកម្មករបម្រើបាយគេនុ៎ង ដាំបាយ ដាំទឹកឱ្យគេហូប ដូច្នេះអត់ដែលបានចូលរៀនវគ្គធំ តូច អត់ដែលទេ។

**ស៖** តើនរណាជាមេរបស់លោក ជាប្រធានរបស់លោក?

**ឆ៖** ប្រធាននៅអង្គភាព គឺឈ្មោះ តា -- ឈប់នឹករកសិន ចង់ភ្លេចហើយ តាចំរើន – ឈ្មោះតាចំរើន ប្រធាននៅក្នុងបុរីកីឡា។ ឈ្មោះ តាចំរើន ប៉ុន្តែខ្ញុំអត់ ភ្លេចនាម ខាងត្រកូលគាត់ ដឹងតែឈ្មោះតាចំរើន។ ខ្ញុំទៅឆាប់ដែរ វាមិនបាននៅយូរប៉ុន្មានអង្គាល់នុ៎ង។

**ស៖** តើលោកធ្វើការនៅបុរីកីឡាអស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** ខ្ញុំធ្វើការនៅក្នុងបុរីកីឡាអស់រយៈពេល៣ខែ គេដកខ្ញុំទៅស្ទឹង -- ទៅម្ដុំសហករណ៍ស្ទឹង

ទៅសហករណ៍ស្ទឹង គេឲ្យទៅធ្វើការអីនុ៎ង។ គេដកពីខ្ញុំទៅ ចេញទៅសហករណ៍ស្ទឹងទៀត ដូច្នេះខ្ញុំមិនដែលរារាំង គេឲ្យទៅណាទៅនុ៎ង ព្រោះគេដាក់ផែនការទៅហើយ ខ្ញុំចេះតែទៅៗ ទៅសហករណ៍ស្ទឹងមានជ័យ។ គេថា សហករណ៍ស្ទឹងកាលនោះ ឈ្មោះគេសហករណ៍ស្ទឹង ទៅដើម្បីកាន់ក្របីភ្ជួរស្រែ។

[០៩:៤៧:១២]

**ស៖** តើទីតាំងដែលលោកធ្វើការនៅបុរីកីឡាហ្នឹង តើគេមានហៅជាលេខកូដអីទេ? ឧទាហរណ៍ថា ដូចជា “ស” ឬក៏ “ម” អីទេ?

**ឆ៖** មាន, លេខកូដ គឺលេខកូដ “ក-៥” គេដាក់ព្រះនាម “ក-៥”។

**ស៖** តើលោកដឹងទេ អ្នកណាជាអ្នកគ្រប់គ្រងទាំងមូលទៅលើ ក-៥ នោះ?

**ប្រធានអង្គជំនុំ៖**

កុំអាលឆ្លើយ!

ចាំក្បាលមីក្រូហ្វូនឲ្យភ្លើងសញ្ញាក្រហមសិនណ៎ា សឹមឆ្លើយ!

ឆ្លើយ!

**2-TCW-913៖**

**ឆ៖** បាទ ខ្ញុំចេញមកពីផ្ទះមក នៅអស់រយៈពេល៣ខែ អត់ដឹងៗអ្នកណាធំ អ្នកណាតូច ខ្ញុំអត់បានដឹងដែរ។ ដឹងតែ តាចំរើន នៅត្រួតត្រា ក្តាប់ក្តោបនៅក្នុងបុរីកីឡា។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** តើលោកធ្លាប់ឮឈ្មោះ ប៉ង់ ទេ?

**ឆ៖** បាទ ឮ តែខ្ញុំអត់ដែលឃើញមុខ ដែលជួបមុខផង ប៉ុន្តែឮគេនិយាយថា ឈ្មោះ ប៉ង់ ឈ្មោះផង់ ឮ។ ខ្ញុំបានឮ ឮគេនិយាយតៗគ្នា ប៉ុន្តែអត់បានឃើញមុខផ្ទាល់ទេ។ ដូច្នេះមិនដឹងមុខគាត់យ៉ាងម៉េចទេ ប៉ង់ ប៉ុន្តែឮឈ្មោះ។

[០៩:៤៨:៥៥]

**ស៖** ចុះលោកដែលឮឈ្មោះ ភុំៗ ទេ?

**លោក ស្រ៊ា រតនៈ៖**

សូមៗ ខ្ញុំបាទសូមបញ្ជាក់ថាឈ្មោះ ពុំ។

**2-TCW-913៖**

**ឆ៖** បាទ ដែលឮដែរ ឮគេហៅឈ្មោះ ពុំៗ ដែរ។ ប៉ង់ និង ពុំ ឮដែរ ប៉ុន្តែអត់ដែលឃើញឈ្មោះ។ អត់ដែលឃើញខ្លួនប្រាណរបៀបម៉េចទេ អត់ដែលស្គាល់។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកនិយាយអំពីចិញ្ចឹមជ្រូក ចិញ្ចឹមមាន់ <និងដាំបាយ>ជាដើមហ្នឹង តើលោកមានធ្វើអីផ្សេងទៀតទេ ក្រៅពីការងារនេះ?

**ឆ៖** ក្រៅពីចិញ្ចឹមមាន់ ចិញ្ចឹមទា ចិញ្ចឹមជ្រូកនុ៎ង មានដាំអំពៅបន្តិចបន្តួច សកអំពៅ ដាំអំពៅប្រហែលជាកន្លះហិកតាក្នុងសាលាបាក់ទូក និងសកអំពៅសកអី មានធ្វើការងារប៉ុណ្ណឹង។ អត់មានធ្វើអីច្រើនមុខទេ ធ្វើតែចិញ្ចឹមមាន់ចិញ្ចឹមជ្រូក ហើយនិងសកអំពៅ ដាំអំពៅហ្នឹង ថែអំពៅ អំពៅស្ករយើង។

**ស៖** តើនៅក្នុងកងរបស់លោកនៅបុរីកីឡាហ្នឹងមានមនុស្សប៉ុន្មាននាក់ ស្រីប៉ុន្មាននាក់ ប្រុសប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ ខ្ញុំអត់បានចាំ អត់បានរាប់ដែរ អត់បាន ព្រោះខ្ញុំទៅហ្នឹងអត់មានចំណាំទេ ព្រោះវាសុទ្ធតែខុសៗគ្នា អានេះមុខព្រួញខាងណេះ អានេះមុខព្រួញខាងណោះ។ ដូច្នេះខ្ញុំអត់មានចំណាំ អត់បានរាប់ចំនួនដឹង អត់បានដឹង។ គ្រាន់ដឹងថាមុខផ្សេងៗគ្នា ខ្ញុំគឺបម្រើភ្ញៀវបម្រើបាយ នៅក្រសួងខាងគេខាងអីខ្ញុំអត់ដឹងដែរ។ ប៉ុន្តែមនុស្សច្រើនដែរ ប៉ុន្តែអត់វាមិនពិតប្រាកដ មិនដឹងគេធ្វើការអី ខាងអីៗខ្ញុំអត់ដឹង ដឹងតែខ្លួនឯងនៅត្រង់ហ្នឹង ហើយនៅរយៈពេល៣ខែខ្ញុំអាច គេដកខ្ញុំចេញពីហ្នឹងទៀតទៅសហករណ៍ស្ទឹង។

[០៩:៥១:២២]

**ស៖** តើគេមានធ្លាប់មានឈ្មោះហៅក្រៅអ្វីសម្រាប់កងរបស់លោកទេ? តើកងរបស់លោកហ្នឹងមានឈ្មោះផ្សេង ឧទាហរណ៍ដូចថាឈ្មោះជាលេខកូដ ឬក៏អីផ្សេងដែរឬទេ ឬមួយក៏ថា ជាឈ្មោះដែលគេហៅលេងខាងក្រៅអីដែរទេ?

**ឆ៖** បាទ អត់ដែលឮគេហៅផង ឮតែហៅក-៥ អត់ដែលឮហៅឈ្មោះផ្សេងពីហ្នឹងផង។ ហើយក-៥ ក៏ខ្ញុំមិនដឹងដែរ ក-៥ កអីទេ អត់ដឹងអក្សរគេកាត់ គេសរសេរម៉េចដែរ ប៉ុន្តែថាគេហៅក-៥ៗ ចេះហៅតាមគ្នាទៅ មិនដឹងជាអក្សរគេកាត់យ៉ាងម៉េចអីយ៉ាងម៉េច មេគេដាក់អ៊ីចឹងមកយើងអត់ដឹង។ ដូច្នេះខ្ញុំឮគេហៅក-៥ៗ។

**ស៖** តើលោកធ្លាប់ឮគេហៅថា "ក្រុមស្វា" ដែរទេ?

**ឆ៖** ឮ។ ពួកខ្ញុំមកដល់គេហៅខ្ញុំសុទ្ធតែពួកក្រុមទ័ពស្វា មកដល់ភ្នំពេញ ក្នុងបុរីកីឡា គេហៅ

ពួកខ្ញុំថាអ៊ីចឹង។ ព្រោះពួកខ្ញុំមកដល់ពួកសុទ្ធតែមកថ្មី វាមិនដឹងទិសតំបន់អី ដល់អ៊ីចេះនេះ វាចេះតែដើររកនេះដើររកនោះ ឡើងផ្ទះថ្មផ្ទះអីចេះតែឡើង នាំគ្នាឡើងទៅ រោចនេះរោចនោះ ឡើងមែន រួចគេហៅពួកខ្ញុំ ចោទពួកខ្ញុំសុទ្ធតែពួកទ័ពស្វា មកដល់ទីក្រុងភ្នំពេញនេះ។

**ស៖** លោកនិយាយថា គេបណ្តុះបណ្តាលកម្មាភិបាលនៅបុរីកីឡា <នៅពេលលោកនៅទីនោះ។> ខ្ញុំចង់ដឹងថា តើគេបណ្តុះបណ្តាលកម្មាភិបាលហ្នឹង<ញឹកញាប់ដែរឬទេ>? រៀងរាល់ថ្ងៃ រៀងរាល់សប្តាហ៍ ឬមួយក៏យ៉ាងម៉េច? <តើលោកបានឃើញវគ្គបណ្តុះបណ្តាលហ្នឹងធ្វើឡើងប៉ុន្មានដងដែរ?>

[០៩:៥៣:៣៣]

**ឆ៖** បាទ ខ្ញុំបម្រើភ្ញៀវ៣ខែ ខ្ញុំដឹងៗថា ជួនណាមួយខែមានពីរដង គេបណ្តុះបណ្តាល គេហៅគេ គ្នាគេមកពីខាងណាៗខ្ញុំមិនដឹងទេ ប៉ុន្តែខ្ញុំនៅនុ៎ង ខ្ញុំឃើញគេមករៀបបាយឲ្យគេមានពីរដង មួយខែ។ ហើយត្រូវចប់ការងារទៅ គេទៅវិញអស់ទៅ រៀបចំបបោសសម្អាតកន្លែងបាយកន្លែងទឹកអីត្រឹមត្រូវស្អាតបាតទៅសម្រាប់គេ ស្រាប់កន្លះខែទៀត គេហៅមកមួយសាទៀត។

**ស៖** តើវគ្គបណ្តុះបណ្តាលហ្នឹងមានរយៈពេលប៉ុន្មានដែរ ប៉ុន្មានថ្ងៃ ប៉ុន្មានអាទិត្យអីដែរ?

**ឆ៖** បាទ គេបណ្តុះបណ្តាលហ្នឹងបើតាមខ្ញុំបម្រើបាយបម្រើអីគេហ្នឹង ប្រហែលជាមួយអាទិត្យ ឬមួយ៣ថ្ងៃក៏មាន មួយអាទិត្យក៏មាន។ ជួនណាគេវគ្គគេឆាប់ទៅតែ៣ថ្ងៃទេ អ្នកបម្រើបាយដឹងបម្រើឲ្យគេហូប។

**ស៖** តើអ្នកណាជាអ្នកដឹកនាំវគ្គបណ្តុះបណ្តាលនេះ?

**ឆ៖** បាទ ខ្ញុំអត់ដឹងដែរ។ បើបណ្តុះបណ្តាលហ្នឹងមានតែ តាចំរើន ហ្នឹង តែខ្ញុំអត់ដឹង ខ្ញុំគ្រាន់តែអ្នកដាំបាយ។ នៅពេលនុ៎ង មានគេគិតគូរប្រាប់អ្នកនេះ អ្នកនោះថា អ្នកនេះធ្វើនេះ អ្នកនោះធ្វើនោះ អត់មាន។ បញ្ហាធ្វើអ្វីមួយ គេអត់ប្រាប់ យើងឲ្យដឹងផង ប៉ុន្តែយើង ការងារយើងមុខព្រួញខាងដាំស្លអ៊ីចឹង គឺគិតតែខាងហ្នឹង គិតតែខាងហ្នឹង ដើម្បីឲ្យភ្ញៀវគេហូប។

[០៩:៥៥:៣០]

**ស៖** តើលោកធ្លាប់ឃើញមេដឹកនាំជាន់ខ្ពស់អ្នកណាម្នាក់មកបុរីកីឡាទេ នៅពេលដែលលោកស្នាក់នៅទីនោះ?

**ឆ៖** ខ្ញុំមិនបានឃើញផ្ទាល់ទេ តែឮគេថា គេមកបង្រៀនសូត្រនុ៎ង។ ខ្ញុំអត់ទៅជិត គេមិនឲ្យទៅ

ជិតផង យើងវាអ្នកស្លដាំ។ ប៉ុន្តែអត់ដែលទៅឃើញរូបរាងរបៀបម៉េចៗ អត់ដឹង។ គេមិនឲ្យទៅជួប ព្រោះយើងវាអ្នកស្លដាំ ដើម្បីបម្រើពួកអ្នករៀនសូត្រ។

**ស៖** ឥឡូវនេះខ្ញុំសួរលោកម្តងទៀត ឥឡូវហ្នឹងខ្ញុំចង់ឲ្យលោកប្រាប់ថា លោកចាំអ្វីខ្លះ។ តើលោកចាំថា ធ្លាប់ តើលោក -- ថាលោកធ្លាប់ឃើញមេដឹកនាំជាន់ខ្ពស់មកបុរីកីឡាទេ?

**ឆ៖** បាទខ្ញុំឮតែគេថាមកៗ ប៉ុន្តែគេមិនឲ្យយើងចូលទៅកន្លែងសាលាគេបង្រៀន គេមិនឲ្យចូលផង។ ដូច្នេះ អត់ដែលបានឃើញគេដូចម៉េចផង យើងអត់បានទៅជិតគេ កន្លែងកីឡា បុរីកីឡាហ្នឹង។ តែដឹងគេចូលរួមក្នុងសាលា អាផ្ទះធំមួយនុ៎ងអង្កាល់នុ៎ង មានបន្ទប់សាលាគេធំ ប៉ុន្តែគេអត់ឲ្យយើងចូលទៅជិតគេ។ យើងគិតតែអ្នកបម្រើភ្ញៀវ គិតតែធ្វើហ្នឹង ដាំតែបាយទៅ។ ខ្ញុំឆ្លើយស្មោះចំពោះអ៊ីចឹងហ្មង។ អត់ដែលបានទៅជិតគេផង អត់ដឹងលោកណាៗ មកអត់ដឹង។

**ស៖** នៅពេលដែលលោកនិយាយថា លោកដាំបាយឲ្យគេហ្នឹង តើលោកដាំបាយឲ្យអ្នកដែលចូលរួមរៀនសូត្រ ឬក៏លោកដាំបាយឲ្យអ្នកណាផ្សេង?

**ឆ៖** បាទ ខ្ញុំដាំបាយហ្នឹង បម្រើភ្ញៀវគេមករៀនហ្នឹង អ្នករៀនសូត្រ។ ឧទាហរណ៍ថា ត្រឹម៥០នាក់ ឬ៤០នាក់អ៊ីចឹង ខ្ញុំដាំផ្គត់ផ្គង់ឲ្យពួកគេអ្នកមករៀនសូត្រ អត់មានដាំឲ្យអ្នកណាម្នាក់ទេ ទៀតទេ មានតែដាំឲ្យតែពួកដែលគេថាសិក្ខាកាមគេហ្នឹង គេមករៀនសូត្រកន្លែងនុ៎ង គឺដាំត្រៀមឲ្យ ដាំបាយឲ្យតែពួកគេហូប។

[០៩:៥៧:៤៧]

**ស៖** ក្រៅពីដាំបាយ តើលោកមានធ្វើម្ហូប ឬក៏លោកមានលើកម្ហូបម្ហាបាយចំណីហ្នឹងទៅឲ្យពួកគេទេ? <តើលោកបានធ្វើអ្វីខ្លះចំពោះម្ហូបទាំងអស់នោះ មុនពេលដែលគេពិសា?>

**ឆ៖** បាទ អ្នកលើកម្ហូបផ្សេង អ្នករកម្ហូបផ្សេង គ្រាន់តែយើង គ្រាន់តែដាំបាយស្លទៅ បួនប្រាំនាក់ ប្រាំមួយប្រាំពីរហ្នឹងអ្នកដាំ អ្នកលើកម្ហូប រៀបចំឲ្យគេផ្សេងទៀត។ សុទ្ធតែមានឋានៈគេ។ អ្នកណាគេរៀបចំលើកម្ហូប លើកទៅ។ អ្នកណាគេដាំបាយ ដាំទៅ។ ដូច្នេះគេបែងចែកឲ្យច្បាស់លាស់។ ហើយខ្ញុំដាំបាយដាំអីហ្នឹង ខ្ញុំគិតតែដាំបាយបម្រើគេ។ អ្នករៀបចំបាយទឹកអី លើគេអ្នកមករៀបមួយសាទៀត មានគេអ្នករៀបចំឲ្យភ្ញៀវ។

**ស៖** តើលោកហូបបាយ ហើយនិងម្ហូបអាហារដែលគេរៀបចំឲ្យអ្នកចូលរួមហ្នឹង ឬមួយក៏លោកមានរបបម្ហូបអាហារផ្សេងពីពួកគេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ ម្ហូបអាហារសល់ពីគេនុ៎ង គឺលើពួកខ្ញុំ អ្នកដាំហ្នឹង។ គេហូបរួចហើយ ខ្ញុំហូបក្រោយគេ។ អត់មានម្ហូបផ្សេងពីហ្នឹងទេ។ គេហូបអី យើងហូបនុ៎ង។ ប៉ុន្តែយើង គ្រាន់ហូបក្រោយគេ។ ពួកគេហូបចប់អស់ហើយ អ្នកសិក្សាចប់អស់ហើយ យើងហូបដែលគេទៅ លាងចានលាងឆ្នាំងទុកដាក់ស្រួលបួល ដើម្បីសម្អាតឆ្នាំងចានឲ្យបានស្អាត ទុកដាក់ស្រួលបួល ចាំត្រៀមដាំបាយស្ល តទៅមុខទៀត នៅពេលក្រោយទៀត។

**ស៖** ដើម្បីឲ្យច្បាស់ អ៊ីចឹងមានន័យថា លោកមិនដែលឃើញ ប៉ុល ពត ទេនៅបុរីកីឡា អ៊ីចឹងមែនទេ?

[០៩:៥៩:៥០]

**ឆ៖** បាទ ច្បាស់ អត់ដែលស្គាល់ទេ។ ឮតែឈ្មោះ តែអត់ដែលឃើញរូបរាងដូចម៉េចទេ អត់ដែល គេមិនឲ្យទៅជួប ឮតែឈ្មោះ។

**ស៖** ចុះ ខៀវ សំផន វិញ លោកធ្លាប់ឃើញទេ?

**ឆ៖** មិនដែលឃើញដែរ ឮតែឈ្មោះ។ ឮឈ្មោះ អ្នកធំៗ ឮតែឈ្មោះទាំងអស់ ប៉ុន្តែអត់ដែលឃើញរូបរាងដូចម្តេចទេ។ ពេលទៅណាមកណា គេអត់ដែលឲ្យយើងដឹងផង អត់ដែលឃើញ គេមិនឲ្យឃើញ។ ហើយខ្ញុំឆ្លើយត្រង់អ៊ីចឹងហ្មង អត់មានលាក់លៀមទេ ខ្ញុំដល់អ្នកស្បថសច្ចា អត់មានលាក់លៀមទេ។ អត់ឃើញ ថាអត់ឃើញ។

**ស៖** សូមអរគុណ គឺថាអរគុណច្រើន ដែលលោកប្រាប់យើងនូវការពិត យើងចង់បានព័ត៌មានពិត។ ចុះ នួន ជា វិញ តើលោកធ្លាប់ឃើញគាត់នៅបុរីកីឡាទេ?

**ឆ៖** បាទ អត់ដែលឃើញដែរ។ អ្នកធំៗ អត់ដែលឃើញទេ និយាយរួម អត់ដែលឃើញតែម្តង ព្រោះកន្លែងរៀនសូត្រ វាឆ្ងាយដែរ បុរីកីឡា ខ្ញុំនៅដាំបាយឯជើង សៀរៗស្រះឯជើងវិញ ហើយគេរៀនសូត្រនៅឯត្បូង។ ផ្ទះគេរៀនសូត្រនុ៎ង សាលាគេរៀនសូត្រនៅឯត្បូង តែខ្ញុំដាំបាយនៅកន្លែងបម្រើភ្ញៀវនៅជើងណោះ ដូច្នេះមិនដែលបានទៅជួបដូចម៉េចទេ។

[១០:០១:៣២]

**ស៖** បើតាមដែលខ្ញុំយល់អ្វីដែលលោកឆ្លើយនោះ គឺថាលោកមិនដែលធ្លាប់ភ្លក្សអាហារមុនពេលដែលគេយកទៅឲ្យភ្ញៀវទេ អ៊ីចឹងមែនទេ បានន័យថា លោកមិនដែលធ្លាប់ភ្លក្សអាហារ ថាតើវាពុល ឬក៏អត់ទេ អ៊ីចឹងមែនទេ?

**ឆ៖** អាហ្នឹង យើងខ្ញុំឆ្លើយមិនទាន់អស់។ ខ្ញុំបានភ្លក្ស ភ្លក្សហើយ បានឲ្យគេអ្នកយកទៅរៀប។ ខ្ញុំអ្នកដាំបាយ ខ្ញុំភ្លក្សខ្លួនខ្ញុំ។ ដាំបាយស្លហើយហ្នឹង ភ្លក្សហើយ បានដួសរៀបចំឲ្យគេយកទៅរៀបកន្លែងបម្រើភ្ញៀវហ្នឹង។ ត្រូវភ្លក្ស ភ្លក្សទឹក ភ្លក្សបាយទៀត គេឲ្យយើងទៅភ្លក្សទៀត បើងាប់យើង ងាប់ទៅមុនគេ។ អ៊ីចឹងទេគេថា បើស្លាប់យើង ស្លាប់ទៅ កុំឲ្យស្លាប់ភ្ញៀវគេ។ អ៊ីចឹងទេ ខ្ញុំបានភ្លក្ស។ ប៉ុន្តែភ្លក្សក៏មិនច្រើនដែរ ភ្លក្សបន្តិចៗទៅ ទឹកបន្តិច បាយបន្តិចទៅ សម្លបន្តិចទៅ ហើយបានគេដួសយកទៅរៀប។

**ស៖** តើអ្នកណាជាអ្នកប្រាប់ឲ្យលោកធ្វើដូច្នេះ ឬក៏ថាលោកជាអ្នកសម្រេចចិត្តធ្វើដូច្នេះដោយខ្លួនឯង?

**ឆ៖** ភ្លក្សបាយហ្នឹងគឺប៊ុកចំរើន ហ្នឹង តាចំរើន គាត់ឲ្យភ្លក្ស ប្រធាននៅនុំង គាត់ឲ្យភ្លក្ស។ ឈ្មោះ តាចំរើន អ្នកបញ្ជាឲ្យភ្លក្សបាយ។

**ស៖** តើមានតែលោកទេឬ ដែលជាអ្នកភ្លក្សម្ហូបអាហារទាំងនោះ ឬក៏មានអ្នកដទៃទៀត ចូលរួមភ្លក្សម្ហូបអាហារទាំងនោះដែរ?

**ឆ៖** បាទ ខ្ញុំភ្លក្សតែរយៈប៉ុន្មានខែដូចខ្ញុំថានោះ ហើយខ្ញុំ គេដកខ្ញុំចេញមកសហករណ៍ស្ទឹង ខ្ញុំមិនដឹងពីអ្នកណាគេភ្លក្សក្រោយទៀតទេ។ ខ្ញុំអត់ដឹងដែរ ភ្លក្សក្រោយ ពេលក្រោយខ្ញុំចេញហើយ ខ្ញុំអត់ដឹងពីណាគេមករៀបចំចំណិនអាហារឲ្យគេហូប ហើយគេភ្លក្ស ខ្ញុំអត់បានដឹងដែរ។ គេដកខ្ញុំទៅកាត់ព្រីក ដកទៅ ខ្ញុំទៅសហករណ៍ស្ទឹងបណ្តោយ អត់មាននៅកន្លែងទៀត គេដកអស់ហើយ។

[១០:០៣:៤២]

**ស៖** តើចំណីអាហារទាំងនោះ ពេលលោកភ្លក្សហើយ ធ្វើឲ្យលោកឈឺ ឬក៏ធ្វើឲ្យលោកពុលដែរឬទេ?

**ឆ៖** បាទ អត់ដែលពុល អត់ដែលឈឺផង។ ប៉ុន្តែគ្រាន់តែថាវាការពារ ក្រែងពីណាគេបំពុលភ្ញៀវងាប់ ភ្ញៀវគេ យើងក៏ត្រូវស្លាប់ខ្លួនដែរ អ្នកដាំស្ល។ អ៊ីចឹងទេ វាត្រូវឲ្យយើងភ្លក្សមុន បានឲ្យគេទៅហូបក្រោយ។ បើមិនភ្លក្សមុនទេ ក្រែងងាប់គេទៅ យើងក៏ត្រូវគេសម្លាប់យើងដដែល។ អ៊ីចឹងទេ គេឲ្យយើងអ្នកដាំស្លហ្នឹង ភ្លក្សឲ្យហើយ រៀបចំឲ្យស្អាត តាំងពីបាយ តាំងពីទឹក តាំងសម្ល។ មានអ្វីៗទាំងអស់ គឺត្រូវភ្លក្សមុនឲ្យហើយ គ្រប់បែបយ៉ាង គ្រប់មុខដែលវាដាំបានប៉ុណ្ណឹង គឺមានគ្រប់មុខ សម្លប៉ុន្មានមុខត្រូវភ្លក្ស។ ទាំងពីរមុខ បើថាពីរមុខ ភ្លក្សពីរមុខ។

**ស៖** តើលោកធ្លាប់និយាយជាមួយសិក្ខាកាម អ្នកដែលគេមករៀនសូត្រហ្នឹង ធ្លាប់បាននិយាយ

ជាមួយពួកអ្នកទាំងនោះទេ?

**ឆ៖** អត់ដែលបាននិយាយផង។ អត់ដែលបាននិយាយទេ។

**ស៖** តើលោកដឹងទេ បើមិនដឹងក៏ប្រាប់ថា មិនដឹងទៅ។ តើសិក្ខាកាមដែលមកចូលរួមរៀនសូត្រហ្នឹងមានឋានៈអ្វីដែរ ជាកងទ័ព ឬក៏ជាជនស៊ីវិល? ហើយមានឋានៈអ្វីដែរ?

**ឆ៖** បាទ ខ្ញុំឆ្លើយប្រាប់ត្រង់ មករៀនហ្នឹង ឮគេប្រាប់ថា មករៀនគ្រប់ខេត្ត មិនដឹងជាគេឋានៈអីទេ។ ប៉ុន្តែមកគ្រប់ ខេត្តនេះ ខេត្តនោះ មករួមចូលប្រាស្រ័យរួម មករៀនសូត្រហ្នឹង គ្រប់ខេត្ត។ តែមិនដឹងគេឋានៈជាអ្វីមួយ ខ្ញុំអត់ដឹង។ ប៉ុន្តែគេហៅមកៗ គ្រប់ខេត្ត គ្រប់ ខេត្តណាក៏ហៅមកដែរ មកមួយវគ្គៗ តែអ្នកធំអ្នកតូច ខ្ញុំអត់ដឹង។

[១០:០៥:០០]

**ស៖** តើលោកធ្លាប់ដែលឮគេនិយាយថា សិក្ខាកាមទាំងអស់ហ្នឹង រៀនសូត្រពីអ្នកណាដែរ? អ្នកណាជាអ្នកមកបង្រៀនសិក្ខាកាមទាំងនោះ?

**ឆ៖** បាទ អ្នកមករៀនសូត្រហ្នឹង ខ្ញុំឮគេនិយាយតៗមក គឺមាន ខៀវ សំផន ឧស្សាហ៍មកចូលបង្រៀន តែខ្ញុំមិនដែលឃើញ ដូចខ្ញុំឆ្លើយពីដើម អត់ដែលឃើញមុខរបៀបម៉េច ប៉ុន្តែឮគេថា តាខៀវ សំផន មកចូលបង្រៀននៅបុរីកីឡា។ ប៉ុន្តែគេរៀនរឿងមធ្យោបាយ គេរៀនយ៉ាងម៉េច ភារកិច្ចគេរៀនយ៉ាងម៉េច ខ្ញុំអត់បានដឹងដែរ ខ្ញុំ ដូចខ្ញុំរៀបរាប់ប្រាប់។ យើងអ្នកដាំស្លទេ យើងអត់ដឹង ប៉ុន្តែឮគេថា ពីអ្នកមករៀនអ៊ីចឹង គេប្រាប់តៗគ្នា ដឹងថា តាខៀវ សំផន អ៊ីចឹង។ ប៉ុន្តែយើងអត់បានឃើញរូបរាងគាត់ដូចម៉េចទេ តាហ្នឹង ខ្លួនប្រាណគាត់របៀបម៉េច ខ្ញុំអត់បានដែលឃើញទេ។

**ស៖** ចុះតើលោកធ្លាប់ដែលឮឈ្មោះអ្នកបង្រៀនដទៃទៀតដែរ ក្រៅពីគាត់?

**ឆ៖** បាទ ខ្ញុំចូលដល់រយៈពេល៣ខែហ្នឹង ឃើញតែតាហ្នឹងមួយ អត់ដែលបានឃើញក្រៅពីនុ៎ង។ ឮគេនិយាយតែ តាខៀវ សំផន ហ្នឹងមកបង្រៀនកន្លែងនុ៎ង ព្រោះខ្ញុំរយៈពេល៣ខែហ្នឹង វាយឺតយ៉ាវដែរ ខ្ញុំអត់បាននៅយូរអង្វែង។ អ៊ីចឹងទេ គេដកខ្ញុំចេញផុត ខ្ញុំអត់ដឹង។ បើដឹងឃើញ ដឹងប៉ុន្មានដងដែលគេចូលបង្រៀនវគ្គ គ្រប់តែវគ្គខ្ញុំបម្រើដាំបាយហ្នឹង គឺគេប្រាប់អ៊ីចឹង។ គេប្រាប់ថា មានតែ តាខៀវ សំផន មកចូលបង្រៀន។ កាលនុ៎ងគេហៅ "តាៗ"។

[១០:០៨:០៤]

**ស៖** លោកថា លោកជាអ្នកបម្រើម្ហូបអាហារទៅឲ្យអ្នកដែលមកចូលរួមរៀនសូត្រនោះ តើអ្នក

ដែលមកចូលរួមរៀនសូត្រដែលលោកត្រូវបម្រើម្ហូបអាហារហ្នឹង មានប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ ខ្ញុំអត់រាប់ផង។ អត់រាប់ចំនួនទេ ប៉ុន្តែគ្រាន់តែយើងដាំបាយមិនឲ្យខ្វះ រៀបចំឲ្យគេពេញមួយអាផ្ទះមូលគេហ្នឹង។ បុរីកីឡាមានផ្ទះមូលមួយសម្រាប់ទទួលគេឲ្យហូបបាយនុំង អាផ្ទះមូលនុំងមានកញ្ចក់ជុំវិញ។ ខ្ញុំអត់បានរៀបចំនួន ដឹងប៉ុន្មានៗ អត់បានរាប់ទេ អត់បានរាប់ ដឹងចំនួនគេប៉ុន្មានៗ អត់ដែលដឹងរាប់ផង អត់ដែលបានរៀបទេ។ ខ្ញុំឆ្លើយប្រាប់ត្រង់អ៊ីចឹងតែម្តង គ្រាន់តែដឹងថា រៀបតុឲ្យគេហូបទៅ គេហូបនៅសល់ប៉ុន្មាន អីប៉ុន្មានយើងអត់ដឹង ស្រាប់តែដាក់ឲ្យគេហូបទៅ អ្នករៀប ហើយខ្ញុំអ្នកដាំ អ្នកភ្លក្សបាយ។

**ស៖** តើលោកអាចប៉ាន់ប្រមាណ <មនុស្សចំនួនប៉ុន្មាននាក់ ដែលអាចអង្គុយនឹងតុគ្រប់គ្រាន់នោះ? តើតុទាំងអស់ហ្នឹង>អាច១០នាក់ <សម្រាប់១០០នាក់ ឬ១០០០នាក់?> ហើយសរុបចំនួនទាំងអស់ហ្នឹងមានប្រហែលប៉ុន្មាននាក់ដែរ? អ៊ីចឹងលោកអាចកំណត់ប៉ាន់ប្រមាណត្រួសៗបានទេ បើគិតពីមួយតុៗទៅ?

**ឆ៖** បាទ បើគិតជាត្រួសៗ ជាតុហ្នឹង គិតទៅទូទាំងប្រទេសតាមគ្រប់ខេត្ត ច្រើនដែរ ប្រហែលជារាប់រយនាក់ដែរ មិនតិចទេ ព្រោះគេហៅមករៀនសូត្រហ្នឹង បើតាមយើងមើលស្ទង់ត្រួសៗ ប៉ុន្តែអត់បានរាប់ដឹងចំនួនប៉ុន្មានទេ ប៉ុន្តែជារាប់រយដែរហើយ រាប់រយតុ -- រាប់រយនាក់។ មកពិសាបាយហ្នឹងរាប់នេះហើយ រាប់រយនាក់។

**ស៖** តើលោកមានបាន ដែលបានឃើញបន្ទប់គេបង្រៀនហ្នឹងដែរទេ?

[១០:០៩:៥៦]

**ឆ៖** បាទ ខ្ញុំទៅអត់ដល់បន្ទប់គេបង្រៀនទេ គ្រាន់មើលពីចម្ងាយ ពីកន្លែងដាំបាយទៅកន្លែងបង្រៀនប្រហែលជា៣០០ម៉ែត្រ ហ្នឹងបុរីកីឡាអង្កាល់នៅស្រឡះមិនទាន់មានផ្ទះជិតដូចឥឡូវទេ។ ខ្ញុំឆ្លើយប្រាប់ត្រង់ពីដើមមានតែប៉ុន្មានជួរ បុរីកីឡាឥឡូវផ្ទះជិតហើយ។ កាលនុំងមើលពីកន្លែងបាយយើងទៅ ឃើញប្រហែលជា៣០០ម៉ែត្រពីកន្លែងគេបង្រៀនបន្ទប់គេប៉ុណ្ណឹង ផ្ទះគេយ៉ាងម៉េចយ៉ាងម៉ាទៀត គេអត់ឲ្យយើងចូលផ្តេសផ្តាសទេជំនាន់នោះ អ្នកណានៅធ្វើអីធ្វើនុំង វាអត់ឲ្យយើងដើរឆ្វេចឆ្វាច។ អ្នកណាគិតបាយគិតបាយ អ្នកណាធ្វើអីធ្វើនុំង។ អ៊ីចឹងទេខ្ញុំ គឺខ្ញុំចំណាំបានតែប៉ុណ្ណឹង ប៉ុន្តែច្រើនដែរមនុស្សវាមកៗហូបមិនមែនតិចទេ ព្រោះ ពីព្រោះវាមកទូទាំងប្រទេស គ្រប់ខេត្ត ជំនាន់នុំងគ្រប់ខេត្ត វាមកច្រើនណាស់បង្រៀន។ ថាខ្ញុំអត់បានដឹងប៉ុន្មានៗ ខ្ញុំអត់ៗបានរាប់បានស្ថិតិអត់ដឹង។

**ស៖** តើលោកអាចប្រៀបធៀបពីទំហំបន្ទប់ដែលគេប្រើប្រាស់សម្រាប់ការបង្រៀនហ្នឹង ប្រៀបធៀបពីទំហំប្រហែលប៉ុន្មាន ប៉ុនប្រហែលបន្ទប់សវនាការនេះដែរឬ ក៏វាទំហំប្រហែលប៉ុន្មាន?

**ឆ៖** បាទ ខ្ញុំអត់ដែលបានចូលផង។ អត់ដែលបានចូលក្នុងបន្ទប់គេរៀនសូត្រផង។ ដល់អ៊ីចឹងយើងមិនដឹងគេបន្ទប់គេទំហំប៉ុនណា ធំប៉ុនណា អត់ដែលបានចូល គេមិនឱ្យយើងចូល ការងារភារកិច្ចខុសៗគ្នា គេអត់ឱ្យយើងចូលកាលហ្នឹង គេនិយាយភារកិច្ច អ្នកណាធ្វើអីធ្វើហ្នឹង។ អ៊ីចឹងទេខ្ញុំអត់ដឹងបន្ទប់គេទំហំប៉ុនណាទេ អត់ៗបានដឹងដែរ គេមិនឱ្យចូល ដើរលេងសេរីអាវ៉ាសែផងកាលនុ៎ង។ នៅត្រង់ណានៅត្រង់នុ៎ង ធ្វើអី ធ្វើនុ៎ង។ ឥឡូវដឹងយ៉ាងម៉េច គេរើគ្រវាត់ចោលដឹង កន្លែងគេរៀនសូត្រហ្នឹងខ្ញុំអត់ដឹងដែរ អត់ដែលដឹងដែរ មិនដឹងគេរើគ្រវាត់ចោលហើយមិនដឹង អីមិនដឹង កន្លែងវារៀនសូត្រនុ៎ង ព្រោះខ្ញុំអង្គាល់នុ៎ងខ្ញុំអត់ដែលចូលទៅនុ៎ងដែរ គេអត់ឱ្យចូល។

[១០:១២:១១]

**ស៖** តើលោកឃើញសិក្ខាកាមដែលគេមកហ្នឹង គឺកម្មាភិបាល ឬក៏ថាអ្នកបង្រៀនក៏ដោយ គេចូលមកកន្លែងបង្រៀន កន្លែងរៀនសូត្រហ្នឹងគេមកតាមរថយន្ត ឬយ៉ាងម៉េច ជិះឡានមក?

**ឆ៖** បាទ ជិះឡានមក ជិះឡានមកគ្រប់ខេត្ត គេសុទ្ធជិះឡាន។

**ស៖** តើឡានទាំងនោះជាឡានប្រភេទអ្វីដែរ?

**ឆ៖** បាទ ឡានកាលនុ៎ងគេហៅឡានអាកាម៉ាស់ៗ អាម៉ាស់ ឈ្មោះគេឮគេហៅអាកាម៉ាស់អាម៉ាស់ មិនដឹងឡានម៉ាស់ម៉េច មិនដឹងមកពីប្រទេសណា អត់ដឹងដែរ។ ប៉ុន្តែគេថាអាកាម៉ាស់ឡាននុ៎ងអាកាម៉ាស់ ឈ្មោះអាម៉ាស់។ កាលហ្នឹងប្រើតែអាកាម៉ាស់ហ្នឹងដឹក ដឹកមនុស្ស។

**ស៖** តើលោកឃើញសិក្ខាកាមដែលមករៀនសូត្រហ្នឹង ហើយនិងអ្នកដែលមកបង្រៀនហ្នឹង គេមកហ្នឹងមានទាំងកងការពារ ឬក៏ថាមានអង្គរក្សមកជាមួយផងទេ?

**ឆ៖** តាមខ្ញុំមើលឃើញទៅ អត់មានអង្គរក្សមកទេ។ មកផ្ទាល់ៗតែម្តង អត់មានកងការពារអីអត់មានទេ។ ប៉ុន្តែគ្រាន់ថាភ្ញៀវ មិនដឹងភ្ញៀវហ្នឹងអ្នកធំអ្នកតូច ខ្ញុំអត់ដឹង តែអត់មានកងការពារអីមកទេមកចូលរៀនទាំងអស់គ្នាតែម្តង អ្នកណាមកនុ៎ង។ ឱ្យតែមកដល់កន្លែងនុ៎ង គឺគេឱ្យទៅរៀនកន្លែងនុ៎ងហើយ គ្មានអ្នកការពារអី គ្មានកងការពារទេ។ គ្រាន់តែគេៗឱ្យចូលរៀនទាំងអស់គ្នា ឱ្យតែមានមកពីខេត្តណាៗ គឺឱ្យចូលទាំងអស់ តែគ្នានុ៎ង។ ហ្នឹងតាមខ្ញុំមើលឃើញ។

[១០:១៤:២៨]

**ស៖** នៅពេលដែលលោកនៅទីនោះ តើលោកបានឃើញការបង្រៀនហ្នឹងដោយផ្ទាល់ខ្លួនលោកដែរឬទេ ឬក៏លោកឮពីអ្នកដឹកនាំលោក ឬក៏យ៉ាងណាទេ ពេលនៅបុរីកីឡានោះ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់! កុំអាលទាន់ឆ្លើយ!

**2-TCW-913៖**

**ឆ៖** បាទ ខ្ញុំអត់បានចូលរៀន ហើយខ្ញុំក៏មិនដឹង គេរៀនមានផ្នែកគេយ៉ាងម៉េចយ៉ាងម៉ា ខ្ញុំអត់ដឹងដែរ ហើយខ្ញុំមិនបានចូលរួមដែរ។ អត់ដែលគេឲ្យចូលរៀនផង ព្រោះយើងវាតូចតាច។ យើងដូចថាកម្មករមកដាំបាយដាំអី គេមិនឲ្យយើងចូលរៀនទេ។ ហើយគេមកហ្នឹង មិនដឹងគេថ្នាក់ប៉ុនណា គេចូលរៀន យើងអត់ដឹងដែរ។ អ្វីដែលគេមកហ្នឹង សុទ្ធតែគេអ្នកគ្រាន់បើដែរមិនដឹង បានគេឲ្យមករៀនសូត្រ។ តែយើងតូចតាច គេមិនឲ្យទៅជិតគេ អត់ឲ្យដឹង។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ខ្ញុំសូមបង្ហាញឯកសារមួយឲ្យសាក្សីពិនិត្យមើល គឺឯកសារ E319/23.3.38.1។ ឯកសារនេះគឺថាមានឈ្មោះសាក្សីនៅទីនេះ <ដែលវាមិនគួរបង្ហាញជាសាធារណៈនោះទេ។ ប៉ុន្តែ>ខ្ញុំមានឯកសារ<ចម្លង>ជាភាសាខ្មែរ <>គឺថាសុំការអនុញ្ញាតដើម្បីឲ្យគាត់ពិនិត្យមើល។

[១០:១៦:១៤]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ខ្ញុំឃើញលោកកំពុងតែអានឯកសារនេះ។ អ៊ីចឹងបើលោកអានមើល អានសិនទៅ។ ថាតើលោកស្គាល់ឯកសារនេះដែរឬទេ? បើលោកស្គាល់ តើឯកសារនេះ ជាឯកសារអ្វីដែរ?

**2-TCW-913៖**

**ឆ៖** បាទ ឯកសារ គឺឯកសារពេលដែលខ្ញុំមកដល់ភ្នំពេញ វាឲ្យខ្ញុំធ្វើប្រវត្តិរូប។ ចំពោះប្រវត្តិរូបបងប្អូនខ្ញុំ ឈ្មោះខ្ញុំ ម៉ែឪខ្ញុំទាំងអស់ វាឲ្យរៀបរាប់ ពីប្រវត្តិរូបរបស់ឪពុកម្ដាយខ្ញុំ ទាំងអស់ហ្នឹង នៅក្នុងឯកសារហ្នឹង ជាក់ស្ដែងពិតមែន។ ព្រោះឯកសារនេះ គឺវាមកដល់ភ្នំពេញហ្នឹង វាឲ្យធ្វើប្រវត្តិរូប ហ្នឹង

ប្រវត្តិរូបរបស់ខ្ញុំមែន ខ្ញុំជឿ។ វាឲ្យធ្វើរៀបរាប់តាំងពីយើងកើតមក ដឹកក្តី យើងធ្វើអីខ្លះស្អីខ្លះ វាឲ្យធ្វើដាក់នៅក្នុងហ្នឹងទាំងអស់។ ហ្នឹងវាឲ្យធ្វើប្រវត្តិរូបខ្ញុំហ្នឹង ប្រវត្តិរូបសង្ខេប។ អ្នកណាក៏ឲ្យធ្វើដែរ ឲ្យតែចូលមក។ មកប៉ុន្មាននាក់ វាឲ្យធ្វើទាំងអស់គ្នា។ ហ្នឹងប្រវត្តិរូបសង្ខេបរបស់ខ្ញុំហ្នឹង នៅភូមិអី ស្រុកអីហ្នឹង វាឲ្យធ្វើទាំងអស់។ ដូច្នេះទេ ខ្ញុំចំណាំរបស់ខ្ញុំពិតប្រាកដមែនហ្នឹង ធ្វើហ្នឹង មកដល់នេះ។ មកដល់ភ្នំពេញ វាឲ្យធ្វើហ្នុង ប្រវត្តិរូបនេះ។

[១០:១៨:២៥]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៨ នាទី ដល់ម៉ោង ១០:៣៣ នាទី)*

[១០:៣២:៤៧]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី ខ្ញុំគិតថា ប្រហែលជាលោកនៅមានប្រវត្តិរូបនៅឡើយនៅក្នុងដៃរបស់លោក

ដូច្នេះខ្ញុំចង់ដឹងថា នៅពេលដែលលោកនៅបុរីកីឡាហ្នឹង តើលោកត្រូវសរសេរប្រវត្តិរូបប៉ុន្មានដងដែរ?

**2-TCW-913៖**

**ឆ៖** បាទ ខ្ញុំនៅបុរីកីឡា មកដល់ទីក្រុងភ្នំពេញ ខ្ញុំធ្វើប្រវត្តិរូបតែម្ដងហ្នឹង។ អត់មានធ្វើពីរដង បីដងទេ ធ្វើតែម្ដងហ្នឹង។ ឆ្លើយប្រាប់លោកប្រធាន។

**ស៖** ខ្ញុំមានសំណួរបន្តិច នៅខាងលើខាងស្ដាំនោះ គឺគេសរសេរថា គឺឥឡូវហ្នឹងលោកមើលតាមដៃរបស់ខ្ញុំទៅ គឺថានៅខាងលើខាងស្ដាំហ្នឹង គេសរសេរថា "កងស-៧១"។ តើលោកអាចពន្យល់បានទេ តើវាមានន័យយ៉ាងម៉េចដែរ?

[១០:៣៤:៤៥]

**ឆ៖** បាទ គេឲ្យខ្ញុំសរសេរតាមគេហ្នឹង ខ្ញុំអត់ដឹង ខ្ញុំដឹងតែនៅក-៥។ ឯអាអង្គភាពស-៧១ ខ្ញុំគេឲ្យសរសេរ ចេះតែសរសេរតាមគេទៅ ខ្ញុំអត់ដឹង ខ្ញុំមិនដឹងដែរ។ ប៉ុន្តែគេអ្នកណាធ្វើប្រវត្តិរូប គេឲ្យសរសេរតាមអ៊ីចឹងតែម្ដង។ គេឲ្យសរសេរតាមគេហ្នឹង។

**ស៖** ហើយនៅខាងឆ្វេងផ្ដិតស្នាមមេដៃហ្នឹង គឺយើងឃើញឆ្នាំ គឺគេសរសេរថា "ឆ្នាំ១៩៧៦"។ អ៊ីចឹងមានន័យថា លោកបំពេញប្រវត្តិរូបហ្នឹងនៅឆ្នាំ១៩៧៦ មែនទេ គឺនៅទំព័រដដែលហ្នឹង នៅខាងក្រោម ខាងឆ្វេងស្នាមមេដៃហ្នឹង គឺគេសរសេរឆ្នាំ ១៩៧៦នេះ?

**ឆ៖** បាទ ខ្ញុំចេញមកពីសឹកពីលោកមក ខ្ញុំសឹកពីលោកមកហ្នឹង ដល់ខ្ញុំមកដល់ចូលភ្នំពេញ ប្រហែកវាឆ្លងឆ្នាំ។ អ៊ីចឹងទេគេឲ្យធ្វើ១៩៧៦ ឆ្លងឆ្នាំ ចូលដល់ឆ្នាំ១៩៧៦ អាហ្នឹងឆ្លងឆ្នាំ។ របៀបដូចថា ចុងឆ្នាំដើមឆ្នាំ យើងមកដល់ទៅវាត្រូវដល់ចុងឆ្នាំ ដើមឆ្នាំ ចូលដល់ឆ្នាំ១៩៧៦ គេឲ្យធ្វើតាមហ្នឹង។

**ស៖** ខ្ញុំដូចជាច្របូកច្របល់បន្តិចទាក់ទងទៅនឹងអ្វីដែលលោកធ្វើការពីខែមេសា ៧៥ រហូតដល់ ៧៦ គឺពេលដែលលោកធ្វើប្រវត្តិរូបនេះ។ ដូច្នេះខ្ញុំចង់សួរលោកបន្តិច តើលោកដឹងទេថា សាលាស-២០០ ហ្នឹងជាអ្វី?

**ឆ៖** ខ្ញុំអត់ដឹង។ ឮតែឈ្មោះ ប៉ុន្តែមិនដឹងជាសាលាសហ្នឹងរបៀបណាៗ នៅអីណាៗ ខ្ញុំអត់ដឹងផង ឮតែឈ្មោះ។ ពេលនុ៎ងឮតែឈ្មោះ ហៅសាលា ស-២០០ស្អី សាលាស។ ដូចស-៧១ ចិតអីឮតែឈ្មោះ គេឲ្យសរសេរតាមហ្នឹង ហើយខ្ញុំ អ៊ីចឹងទេយើងមិនដាក់នុ៎ង វាខុស។ គេឲ្យសរសេរអ៊ីចឹងទៅ។ ឲ្យសរសេរតាមវាហ្នឹង។

[១០:៣៧:២២]

**ស៖** លោកសាក្សី លោកចាំទេ ថាលោកបាននិយាយជាមួយបុគ្គលម្នាក់មកពីអង្គការមួយដែលគេហៅថា មជ្ឈមណ្ឌលឯកសារកម្ពុជា គឺនៅឆ្នាំ២០០៥។ ខ្ញុំគិតថា គឺជួបជាមួយមនុស្សឈ្មោះ ផាន់ សុជា។ តើលោកចាំទេថា លោកបានជួប ផាន់ សុជា មកពីមជ្ឈមណ្ឌលឯកសារកម្ពុជាមកជួបលោកនៅភូមិ ហើយបានសួរនាំលោកអំពីរបបកម្ពុជាប្រជាធិបតេយ្យ តើលោកចាំទេ?

**ឆ៖** ខ្ញុំអត់បានចាំផង អត់ដឹងពីណាមកសួរខ្ញុំផង ឬគេ -- អត់មានទេ។ ផាន់ សុជា អត់ដែលស្គាល់គ្នាដូចម៉េចផង។ អត់មានដែលស្គាល់គ្នាផង។

**ស៖** តើលោកចាំទេ នៅពេលដែលលោកមកតុលាការដើម្បីផ្តល់ចម្លើយហ្នឹង គឺមិនមែនមកទីនេះទេ ប៉ុន្តែនៅក្នុងបរិវេណតុលាការហ្នឹង នៅអគារផ្សេង គឺគេបានឱ្យលោកអាននូវការសម្ភាសដែលធ្វើនៅឆ្នាំ២០០៥ គឺបានន័យថា គេឱ្យលោកអានសិន មុននឹងអ្នកស៊ើបអង្កេត គេស្តាប់ចម្លើយលោក។ តើលោកចាំទេថា លោកមានបានអានឯកសារឆ្នាំ២០០៥?

**ឆ៖** បាទ អត់ដែលបានអានផង។ ២០០៥ អត់ដែលបានអានផង។

**ស៖** ឥឡូវនេះខ្ញុំជួយរំឭកលោកបន្តិច គឺប្រតិចារឹកដែលយើងមាន គឺឯកសារ E3/9086 ហើយនិងសំណួរ-ចម្លើយដែលលោកបានឆ្លើយនៅទំព័រខ្មែរមានលេខ 00977447, អង់គ្លេសនៅលេខ 00983502។ នៅពេលនោះគឺលោកនិយាយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា៖ “ខ្ញុំគិតថា ប្រហែលជា១ខែក្រោយពេលដែលខ្ញុំសឹក។ <នៅពេលដែលខ្ញុំសម្រេចចិត្តទៅទីក្រុងភ្នំពេញ> គឺគេឱ្យខ្ញុំដើរទៅវត្តអំពិលគឺទៅរៀនវគ្គនយោបាយ គឺថាមានក្រុមជាច្រើនដែលគេបង្កើតនៅវត្តអំពិល រៀននយោបាយ ផ្នែកនយោបាយ រៀនហ្នឹងប្រហែលជា៣ថ្ងៃ។ ហើយដើរទៅទៀត ហើយទៅដល់វត្តព្រះប្រនេន (គេថាវត្តព្រះទន្លេនៅស្វាយរៀង) ដែលទៅហ្នឹង គឺទៅរៀននយោបាយ។ ក្រោយពេលរៀននយោបាយចប់នៅវត្តព្រះប្រនេន គឺយើងដើរ<>ទៅស្វាយរមៀត នៅពានា។ <យើងវេទនាណាស់។> ទៅដល់ចូលសាលាស-២០០។ បាទ ពីដើមគេថាសាលាស-២០០នុំង។ <យើងរៀននៅ>សាលា២០០ហ្នឹងកន្លះខែ នៅក្នុងរបប ប៉ុល ពត ហ្នឹង។” នេះគឺជាអ្វីដែលលោកឆ្លើយនៅឆ្នាំ២០០៥។ តើអ្វីដែលខ្ញុំអានហ្នឹង ធ្វើឱ្យលោកអាចនឹកឃើញទេ? តើសាលាស-២០០ហ្នឹងជាសាលាអ្វីដែរ?

[១០:៤១:២៧]

**ឆ៖** ខ្ញុំៗបាទ ខ្ញុំឆ្លើយរៀបរាប់មិនអស់មុន ខ្ញុំប្រាប់ថា ពេលខ្ញុំផ្សឹកបានរយៈពេលតែមួយខែពីរខែវាឱ្យខ្ញុំមកធ្វើសហករណ៍នៅភូមិបឹង។ ដល់ធ្វើសហករណ៍ហើយ វាបញ្ជូនខ្ញុំមកទៀត ថាធ្វើរោងចក្រ។

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដូច្នេះខ្ញុំៗលឿនពេក ខ្ញុំអេបមក វានាំបណ្ដើរមកវត្តអំពិល មិនជាផ្នែកនយោបាយយើងនោះទេ។ អានេះជា មកវាឲ្យយប់ត្រង់ណា វាដេកត្រង់នុ៎ង។ អ៊ីចឹងទេវាឲ្យរៀបចំហ្នឹង ហើយមកពីវត្តអំពិលមក វត្តព្រះទន្លេនេះ វាឲ្យដេកពីរយប់បីយប់កើត អើ!មួយយប់ទៀត អត់មានរៀនសូត្រទេអានេះ គ្រាន់តែគេថាមកចត យើងដើរ ៗពីនុ៎ងមក ដើរពីភូមិខ្ញុំមក។ ដូច្នេះទេវាដើរឆ្ងាយណាស់ ពេលយប់ត្រង់ណា វាចតត្រង់នុ៎ង អត់មានផ្នែករៀននយោបាយទេ។ ហើយមកពីនុ៎ងទៀត មកដល់កាត់ស្វាយរៀង មកចូលហៅថា ភ្លេចហើយភូមិឃុំ ព្រះវត្ត – អីទេមកព្រៃវែងហ្នឹង មកចូលហ្នឹងក៏អត់បានរៀនអីធំដុំដែរ។ គ្រាន់តែវាមកវាចតៗហ្នឹង បានវាបញ្ជូនខ្ញុំមកដល់បុរីកីឡាហ្នឹង។ មានមែន ហ្នឹងប្រាប់លោកប្រធាន។ ប៉ុន្តែខ្ញុំវាភ្លេចត្រួសៗហើយ។ ហើយមក ចេះមកទៅ មកយប់ត្រង់ណាវាឲ្យដេកត្រង់នុ៎ង យប់ត្រង់ណាវាឲ្យដេកត្រង់នុ៎ង។ ដើរៗទាល់ៗល្ងាច។ ហ្នឹងនិយាយអ៊ីចឹង មានចូលរៀនសាលាចូលរៀនអី ប៉ុន្តែគ្រាន់តែវាដើរមកយប់ត្រង់ណាវាឲ្យដេកត្រង់នុ៎ង។ វាប្រជុំប្រាប់យើងទៅ ឲ្យមានសណ្ដាប់ធ្នាប់អី កុំឆ្វេចឆ្វាចអ៊ីចឹង អាហ្នឹងវាមែន វាប្រជុំប្រាប់ហ្នឹង។ បើថាឲ្យបើកសាលាអីធំដុំ គ្មានទេ។ មកវត្តព្រះទន្លេអ៊ីចឹងដែរ វត្តព្រះទន្លេ គឺវាមកចតត្រង់ហ្នឹង គឺវាហៅយើងប្រជុំណែនាំយើងទេ អត់បានរៀនសូត្រធំដុំទេ។ ហើយបានវាបញ្ជូនមកព្រៃវែង។ ដល់ចូលព្រៃវែងមកភ្នំពេញតែម្ដង។ ហ្នឹងខ្ញុំមិនបានលើកអស់ត្រង់ហ្នឹង កន្លែងហ្នឹងប៉ុន្តែឲ្យចូលរៀនសាលាអី អត់បានចូលរៀនធំដុំទេ។

[១០:៤៣:៣៣]

ពេលនុ៎ងសុទ្ធតែពួក ដូចគេថាសុទ្ធតែពួកប្រជាជនមកពីស្រុក មកពីស្រែមកទាំងអស់គ្នា។ មកទៅ យប់ត្រង់ណាដេកត្រង់នុ៎ង។ ចូលកន្លែងនុ៎ង វាប្រជុំណែនាំយើង ប្រាប់យើង។ ហ្នឹងខ្ញុំជម្រាបប្រាប់លោកប្រធាន។ បើថាឲ្យរៀនរយៈពេលបួនប្រាំថ្ងៃ គ្មានទេ។ គ្រាន់ថាបើនេះ បានឈប់សម្រាក៥ថ្ងៃ ៦ថ្ងៃ បានឲ្យចេញទៀត អ៊ីចឹងមាន គេប្រជុំប្រាប់យើង។ ខ្ញុំរៀបរាប់មិនអស់វគ្គសាមុន នុ៎ងដែលមកពីផ្ទះភូមិខ្ញុំមក ៗរៀបរាប់មិនអស់ តាមដំណាក់ៗកាល។ ឥឡូវហ្នឹងរៀបឲ្យអស់សេចក្ដីតែម្ដង។ បើថាឲ្យប្រជុំគ្មានទេ ប៉ុន្តែវានាំយើងដើរៗ គ្មានទំនេរទេ បែកជើងបែកដៃអស់ហើយ ដើរនុ៎ង។ បាតជើងបាតអីដាច់ដៃដាច់ជើងអស់ហើយ ដើរទម្រាំបានមកដល់ស្វាយរមៀត ពានា ស្វាយរមៀតហ្នឹង។

**ស៖** ឥឡូវនេះខ្ញុំសូមអានបន្តទៀត ហើយខ្ញុំនឹងសួរលោកបន្ថែមអំពីសាលាស-២០០ហ្នឹង ដើម្បីឲ្យយើងអាចយល់ថា លោកប្រាប់អ្វីទៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ នៅទំព័របន្ទាប់ គឺគេសួរអំពីភូមិ៖ “ថាតើស-២០០ហ្នឹងភូមិណា? ហើយលោកឆ្លើយថា៖ នៅខេត្តព្រៃវែង មិនដឹង<ភូមិ ឃុំ> ស្រុកណាទេ

ខ្ញុំអត់ដឹងដែរ ហើយ សុជា បានសួរថា៖ គេបង្រៀនស្អីនៅស-២០០ហ្នឹង? លោកឆ្លើយថា៖ គេបង្រៀនយើងឲ្យមានការលត់ដំ តាំងចិត្ត កុំឲ្យមានការលោភលន់ សួនតួបុគ្គលអីចឹង។ គឺគេបង្រៀនយើងថាចូលទៅដល់បក្សយើង គេថាបក្សយើង។ គាត់សួរថា៖ ពូ ពីនេះទៅប៉ុន្មាននាក់? ហើយលោកឆ្លើយថា៖ អូ! ច្រើនណាស់។ គឺលោកថា ទាហានច្រើនណាស់ទៅ ទៅពីភូមិនេះទៅច្រើនណាស់ ខ្ញុំមិនចំណាំទេ។ ខេត្តស្វាយរៀង ទៅគ្រប់ស្រុក។ ភូមិត្រស់ទៅបីបួននាក់ទៅ។ ហើយ សុជា បានសួរថា៖ ហើយនៅរស់ប៉ុន្មាននាក់ពូ? លោកឆ្លើយថា៖ ងាប់អស់រលីង សល់តែខ្ញុំម្នាក់ឯងហ្នឹង។ ហ្នឹងទៅជាមួយគ្នាហ្នឹង ងាប់អស់រលីង។ សុជា សួរថា៖ ចុះនៅសាលាស-២០០ ហ្នឹងគេឲ្យរៀនបានប៉ុន្មានខែ? លោកឆ្លើយថា អត់ដល់២ខែទេ ប្រហែលជា១ខែ។ បន្ទាប់មកទៀតយើងចេញទៅវត្តព្រះទន្លេ នៅជាប់ស្រុកព្រៃវែងហ្នឹង។" ចំពោះសាលាស-២០០ហ្នឹង តើអ្នកណាដែលទៅរៀនជាមួយលោក? តើព្រះសង្ឃដទៃទៀតទៅរៀនជាមួយលោកដែរ ឬមួយក៏គេមានរៀនទាំងបុរស ទាំងនារីនៅសាលាស-២០០នេះ?

[១០:៤៦:៣៩]

**ឆ៖** បាទ សាលាស-២០០ហ្នឹង ខ្ញុំប្រាប់លោកប្រធាន ព្រោះពួកខ្ញុំទៅហ្នឹងអត់មានដឹងថា មកពីខាងណា មកណាទេ ប៉ុន្តែពួកហ្នឹងដែលគេហៅទៅ ចតនៅកន្លែងនុ៎ង គេប្រជុំឲ្យយើងរៀបរយយើងមានសណ្តាប់ធ្នាប់ កុំឲ្យដើរឆ្វេចឆ្វាចអីហ្នឹង។ តែទៅហ្នឹង មិនទៅជារៀនអីគគ្រឹកគគ្រេងអី មានសៀវភៅមានប៊ិកទេ គ្រាន់តែវាប្រជុំយើង ថាមួយថ្ងៃអីចឹង ហើយវាឲ្យសម្រាកនៅរយៈពេលប៉ុន្មានៗ ឲ្យសម្រាកសិន ទម្រាំមេគេហៅមកភ្នំពេញទៀត។ ហ្នឹងសម្រាកមែន សម្រាកនៅយូរ។ សម្រាកនៅកន្លែងពានាស្វាយរមៀតហ្នឹង។ បើថាឲ្យរៀនអីធំដុំអត់មានទេ។ យើងទៅកន្លែងវត្តស្វាយរមៀតនោះ គឺគ្មានលោកទេ គេផ្សឹកអស់គ្នា ផ្សឹកទាំងអស់ ដូចគ្នា មានតែវត្តទទេ។ អីចឹងទេគេនាំយើងចូលទៅសម្រាក ចតនៅនុ៎ង ដេកនៅនុ៎ង ទម្រាំគេរៀបចំឲ្យមកដល់ភ្នំពេញ។ អីចឹងទេគ្មានលោកទេកន្លែងនុ៎ង គ្មានទេ សឹកអស់ជំនាន់ខ្ញុំដូចគ្នា។ អ្វីដែលខ្ញុំឃើញជាក់ស្តែង គឺអត់មានលោក មានអីទេ នៅក្នុងវត្តនោះ ប៉ុន្តែគេឲ្យយើងទៅសម្រាកនុ៎ង។ សម្រាកហើយហ្នឹង គេប្រជុំឲ្យយើងទេ អត់មានបញ្ហារៀនអីធំដុំទេ គ្រាន់តែប្រជុំថាកុំឲ្យយើងដើរឆ្វេចឆ្វាច ទៅណេះ មកណេះ នៅឲ្យនឹងស្ងៀមកន្លែងហ្នឹង។ ហ្នឹងបាទ ខ្ញុំជម្រាបត្រង់ប៉ុណ្ណឹង។

[១០:៤៨:០៧]

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំសួរលោកឲ្យច្បាស់បន្តិច នៅស-២០០ តើលោកមានស្គាល់អ្នក

ណាម្នាក់ដែលជាព្រះសង្ឃ ហើយត្រូវគេផ្សឹកដែរឬទេ? ឬមួយក៏មានតែលោកម្នាក់ទេ ដែលជាអតីតព្រះសង្ឃដែលទៅទីនោះ?

**ឆ៖** បាទ មានតែម្នាក់ខ្ញុំ អតីតព្រះសង្ឃ ព្រោះមកចម្រុះ អត់មានទេ អត់មានអីនេះ ក្រៅពីខ្ញុំទេ មានតែខ្ញុំម្នាក់ឯង ក្រៅពីនុំងគេអត់បានមក។ នៅស្រុកនានាមកជាមួយ តែខ្ញុំអត់ស្គាល់ឈ្មោះគេ ទើបនឹងថ្មីៗអ៊ីចឹង គេហៅណេះពីរនាក់ បីនាក់ចូលទៅកន្លែងនុំង កន្លែងវត្តនោះ តែខ្ញុំអត់ស្គាល់ ទាន់ស្គាល់ឈ្មោះគេទេ ព្រោះយើងវាថ្មីទែង យើងមក គេរើសឯណេះពីរបីនាក់ ឯណោះពីរបីនាក់ តែមកខាងខ្ញុំតែម្នាក់ឯងទេ។

**សៈ** អរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំសូមបន្តទៅចំណុចមួយទៀត ទាក់ទងទៅនឹងអ្វីដែលកើតឡើងចំពោះលោកក្រោយពេលចេញពីបុរីកីឡា។ ខ្ញុំចង់ដឹងថា ហេតុអ្វីបានជាលោកចាកចេញពីបុរីកីឡា? មានអ្វីកើតឡើងចំពោះលោកដែរ?

[១០:៤៩:៣១]

**ឆ៖** បាទ តែខ្ញុំដឹងខ្លួនខ្ញុំ ព្រោះខ្ញុំនៅនុំងវារយៈពេលប៉ុន្មានខែនេះ ដល់ពេលគេដកខ្ញុំដកកាត់ព្រឹកចេញពីបុរីកីឡា ខ្ញុំកំពុងសកអំពៅ ភ្ញាក់ឡើងសកអំពៅ គេហៅខ្ញុំមកនៅកន្លែងនោះ គេដកខ្ញុំតែម្តង។ ដកខ្ញុំទៅកន្លែងសហករណ៍ស្ទឹងនេះ កន្លែងអាបង្គោលអង់តែនវិទ្យុ។ ពេលទៅ គេឱ្យនៅធ្វើស្រែ កាន់ក្របីមួយនឹម។ ហើយគេថា ឱ្យថែរក្សាទៅ មើលក្របីទៅ ភ្ជួរទៅ តែបើបាត់ក្របីគឺខ្ទាំង។ បើបាក់នង្គ័លគឺខ្ទាំង។ គេនិយាយតែអ៊ីចឹងតែម្តង គំរាមកំហែងយើងអ៊ីចឹង។ ដូច្នេះយើងប្រយ័ត្នខ្លួន និយាយពីថ្នម ភ្ជួរខ្លាចបាក់ផាលនង្គ័ល ខ្លាចបាត់ក្របី។ ទៅនៅរយៈពេលនុំង ប្រហែលជាមិនដល់មួយខែទេ ខ្ញុំភ្លេចដែរ។ ទៅនៅនោះ ខំថែរក្សាអារឿងក្របី កុំឱ្យបាត់ក្របី កុំបាក់នង្គ័ល យើងអ្នកភ្ជួរ។ ហើយនង្គ័ល ផ្ទៀង ម្យ៉ាងទៀតអាផ្ទៀងដើមអម្ពិលទឹក វាចំណាប់អីវា មិនមែនដូចផ្ទៀងដើមត្រាចដើមអីណា។ ហើយយើងប្រយ័ត្នខ្លាចតែបាក់ តែបាក់ៗ គេហៅខ្ទាំងតែម្តង សុទ្ធតែខ្ទាំង។ អ៊ីចឹងទេខ្ញុំនៅនុំង អត់បានទាន់ដល់គ្រោះថ្នាក់ទេ ខ្ញុំគេដកខ្ញុំចេញទៅទៀត។

**សៈ** ខ្ញុំចង់សួរលោកបន្តទៀត តើពេលណាដែលគេនាំលោកទៅត្រពាំងក្រឡឹង នៅខេត្តកំពង់ស្ពឺនោះ?

**ឆ៖** បាទ ហ្នឹងវាដកខ្ញុំចេញពីនុំង ខ្ញុំនៅមើលក្របីមើលគោ អំ មើលក្របី ភ្ជួរស្រែនោះ ថ្ងៃមួយនោះ គឺគេផ្ញុំកញ្ចែ តម្រង់ជួរ គេហៅឈ្មោះខ្ញុំទៅត្រពាំងក្រឡឹង។ គេហៅឈ្មោះខ្ញុំ គេហៅអ្នកណាមាន

ឈ្មោះ មកឈរមួយកន្លែង។ ដូច្នេះបានឈ្មោះឈរមួយកន្លែងទៅ ខ្ញុំ ប៉ុន្តែខ្ញុំមិនចំណាំមិត្តភក្តិនុំងដែរ មកឈរបានមួយកន្លែងទៅ បានទៅ គេយកឡានមកដឹក។ យកឡានមកដឹក រហូតដល់ត្រពាំងក្រឡឹង។ ទៅត្រពាំងក្រឡឹងនុំង គេឲ្យធ្វើផ្លូវរទេះភ្លើងថ្មី ត្រង់ហ្នឹង អាទំនប់ខាងជើងផ្លូវជាតិលេខ៤ហ្នឹង គេឲ្យធ្វើនុំង។

**ស៖** លោកដឹងទេថា ហេតុអីបានជាគេយកលោកទៅទីនោះ?

[១០:៥២:០៥]

**ឆ៖** ខ្ញុំដឹងខ្លួនតិចៗដែរ។ គេដឹងថា បូព៌ា អ្នកដឹកនាំបូព៌ាហ្នឹង អ្នកដឹកនាំបូព៌ាហ្នឹង ខ្ញុំដឹងខ្លួនៗឯងថាអ៊ំ បែបនេះហើយ គេថាបូព៌ាហ្នឹងក្បត់អស់ហើយ។ អ៊ីចឹងទេឲ្យតែនៅបូព៌ា សុទ្ធខ្មាំងទាំងអស់។ ដឹងតិចៗ ល្មៀងហ្នឹង គេថាឲ្យតែបូព៌ាក្បត់ហើយ ពេលនោះ។ ឥឡូវពេលនុំង ឬអ៊ីចឹងទេ គេត្រូវឲ្យតែនៅបូព៌ា នៅស្វាយរៀង ព្រៃវែង គេប្រមូលយកមកលត់ដំហ្នង គេថាយកមកដុតដំ។ គេមិនថាលត់ដំ គេថា ដុតដំ ហ្នឹងភាសាគេហ្នឹង។ ដុតដំធ្វើឲ្យយើងបាក់កម្លាំង ស្គមរីងរៃ ដើម្បីនឹងវាធ្វើទារុណកម្មយើងហ្នង។ ខ្ញុំដឹងហ្នឹង ត្រួសៗ។

**ស៖** តើគេមាននិយាយអ្វីអំពីលោក ទាក់ទងទៅនឹងវៀតណាមទេ? តើគេមានហៅលោកអ្វី និយាយអ្វីទាក់ទងជាមួយនឹងវៀតណាមទេ?

**ឆ៖** បាទ គេនិយាយ។ គេនិយាយទាក់ទងជាមួយវៀតណាម គេថាឲ្យតែនៅស្វាយរៀង បូព៌ាហ្នឹង ទាំងអស់ សុទ្ធក្បាលយួនខ្លួនខ្មែរ។ ហ្នឹងគេនិយាយអ៊ីចឹង ខ្ញុំដឹងហ្នង។ គេនិយាយក្បាលយួនខ្លួនខ្មែរ គេហៅខ្ញុំតែក្បាលយួនខ្លួនខ្មែរទាំងអស់។ គេដកខ្ញុំចេញពីសហករណ៍ស្ទឹងហ្នឹង ទៅដល់ហ្នឹងគេលត់ដំ គេថា ដុតដំវា ធ្វើឲ្យវែកដី លើកផ្លូវរទេះភ្លើងថ្មីឲ្យទ្រុឌទ្រោមកម្លាំង។ គេហៅពួកខ្ញុំតែអាក្បាលយួនខ្លួនខ្មែរ អ៊ីចឹងតែម្តង គេនិយាយអ៊ីចឹង ខ្ញុំឆ្លើយត្រង់ប្រាប់លោកប្រធាន។ គេអត់ហៅវៀតណាមទេ គេហៅយួន។

**ស៖** ខ្ញុំគិតថា ឥឡូវហ្នឹងខ្ញុំចង់សួរអំពីការធ្វើការនៅ<សហករណ៍>ស្ទឹង។ អ៊ីចឹងបានន័យថា ក្រោយពេលចេញបុរីកីឡា លោកទៅស្ទឹងហ្នឹង ស្ទឹងនៅខាងក្រៅទីក្រុងភ្នំពេញហ្នឹង មែនទេ?

[១០:៥៤:១៧]

**ឆ៖** បាទ នៅកន្លែងនុំងមែន។ នៅសហករណ៍ស្ទឹង ដូចខ្ញុំរៀបរាប់ថាឲ្យ គេឲ្យខ្ញុំកាន់ក្របីឡើងធំៗ ក្របី ឲ្យកាន់ភ្ជួរស្រែ។ ភ្ជួរស្រែ នង្គ័ល គេឲ្យនង្គ័ល ហើយនិងក្របីហ្នឹងសម្រាប់ភ្ជួរស្រែ គេស្ទូង។ ហើយខ្ញុំចេះតែខំភ្ជួរហើយ ព្រោះគេនិយាយខ្សឹបៗ គេថាតែបាក់ជ្រលួញនង្គ័ល គឺខ្មាំង។ បើបាត់ក្របី គឺ

ខ្លាំង។ ដូច្នេះខ្ញុំប្រយ័ត្ន ភ័យខ្លួន។ ខំហើយ ថែទម្រាំគេដកចេញខ្ញុំពីនុំង ខ្ញុំរួចខ្លួន។ ទៅដល់នោះ លើកដីម្តង ទៅដល់ត្រពាំងក្រឡឹង។ គេដកពីហ្នឹងទៅ ធូរខ្លួនបន្តិច លែងធ្វើស្រែ លែងភ្ជួរ គេឲ្យទៅលើកដី ធ្វើផ្លូវរទេះភ្លើងថ្មី គេថាធ្វើរទេះភ្លើងថ្មី គឺលើកធំ។ ហើយឥឡូវថ្នល់ហ្នឹង មិនដឹងយ៉ាងម៉េច គេឈូសឆាយគ្រវាត់ចោលអស់ហើយមិនដឹង អត់ដែលទៅឃើញដែរ។ ហ្នឹងទៅដល់នុំង លើកថ្នល់នុំង។

**ស៖** នៅពេលដែលលោកនៅសហករណ៍ស្ទឹង តើលោកមានដឹងអំពីការសម្លាប់ ឬក៏ការបាត់ខ្លួនណាទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ឆ្លើយ! កុំអាល់ទាន់ឆ្លើយតប!

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន គឺខ្ញុំសូមជំទាស់ទៅនឹងសំណួរមួយនេះ។ រាល់ហេតុការណ៍ដែលកើតឡើងនៅទីតាំងដែលគេសួរសាក្សីហ្នឹង គឺវាស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះនេះ។ ខ្ញុំបញ្ជាក់ឲ្យបានលម្អិតបន្តិចត្រង់ចំណុចនេះ។ ខ្ញុំសូមយោងទៅលើដីកាបំបែកកិច្ចដំណើរការនីតិវិធីទាំងពីរគឺ <E301 និង> E315។ សាក្សីមួយនេះមិនស្ថិតនៅក្នុង<ក្រុម>កំណត់គោលដៅ<ណាមួយនោះទេ។ គាត់មិនមែនជា>ចាម <មិនមែនជា>វៀតណាម <>ហើយគាត់ក៏មិនមែនជាអតីត<ទាហាន> ឬក៏អ្នករដ្ឋការលន់ នល់ ដែរ។ អ្វីដែលកើតឡើង គឺវាមិនស្ថិតនៅក្នុងមន្ទីរសន្តិសុខទាំងបួនដែលជាផ្នែកនៃសវនាការទី២នេះដែរ។ ហើយវាអាចថា គាត់ពាក់ព័ន្ធទៅនឹងការបោសសម្អាតនៅភូមិភាគបូព៌ា ព្រោះគាត់មកពីខាងបូព៌ា។

[១០:៥៦:៥០]

ក៏ប៉ុន្តែ នៅក្នុងឯកសារ <E301/9/1.1> នៅជើងទំព័រលេខ៩ គឺទាក់ទងទៅនឹងកថាខណ្ឌ២ គឺមានជើងទំព័រជាច្រើន ដែលដកស្រង់ចេញពីដីកាដំណោះស្រាយ គឺជើងទំព័រលេខ៩បាននិយាយថា៖ “បន្ថែមពីលើផ្នែកទាំងអស់ដែលមាននៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២នេះ អង្គជំនុំជម្រះកត់សម្គាល់ថា អង្គហេតុបន្ថែមទៀត ទាក់ទងទៅនឹងការបោសសម្អាតភូមិភាគបូព៌ា ត្រូវបានចែងនៅក្នុងផ្នែកនៃដីកាដំណោះស្រាយ ទាក់ទងទីតាំងសម្លាប់មនុស្សស្ទឹងតូច។ បន្ទាប់ពីមានសំណើ ដោយមានសំអាងហេតុ អង្គជំនុំជម្រះពង្រីកវិសាលភាពនៃសំណុំរឿង០០២/០២ ដោយបញ្ចូលបន្ថែមនូវអង្គហេតុ

ទាក់ទងទៅនឹងការបោសសម្អាតនៅភូមិភាគ<ឧត្តរ និងភូមិភាគបូព៌ា> ដោយគោរពទៅតាមសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានសម្ភារៈ ក៏ដូចជាពេលវេលាគ្រប់គ្រាន់។”

ដូចដែលបានសម្រេចរួចទៅហើយ អ្វីចឹងគឺថាសាក្សីនេះ គឺថា ដូចជាមិនមានអ្វីក្រោយពេលដែលគាត់ចាកចេញពីបុរីកីឡា គឺមិនមានអ្វីដែលស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះនេះឡើយ។ ដូច្នេះការសាកសួរនានា អំពីទីតាំងនៅកំពង់ស្ពឺនេះ គួរតែត្រូវបានហាមឃាត់ដោយអង្គជំនុំជម្រះ។

[១០:៥៨:៣៩]

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន គឺថាជំហររបស់ខ្ញុំ គឺថា -- <ខ្ញុំមិនមានឱកាសក្នុងការសិក្សារឿងហ្នឹងនៅពេលនេះទេ ប៉ុន្តែ>វិសាលភាព ឬក៏សេចក្ដីសម្រេចស្ដីពីវិសាលភាពនៃសំណុំរឿង០០២/០២ហ្នឹង ដូចដែលមេធាវីការពារក្ដីបានទទួលស្គាល់ហើយ គឺរួមបញ្ចូលទាំងការបោសសម្អាតភូមិភាគបូព៌ា។ គាត់ធ្វើការនៅក-៥ នៅស-៧១ <ដែលជាផ្នែកនៃអង្គភាព ស-៧១> ដែលភស្តុតាងបានបង្ហាញថា គឺជាក្រុមគោលដៅ ហើយសហការីរបស់គាត់ ដែលមកពីភូមិភាគបូព៌ាដែរនោះ គឺស្ថិតនៅក្នុងវិសាលភាព។ ដោយសារតែនេះគឺជាផ្នែកនៃសំណុំរឿង០០២/០២ នៃការបោសសម្អាតភូមិភាគបូព៌ា។ ហើយការជម្លៀសដោយបង្ខំ<ដំណាក់កាលទី៣ គឺមិនត្រូវបានរាប់បញ្ចូលនោះទេ។ នេះមិនមែន>ជាផ្នែកមួយនៃការជម្លៀសដោយបង្ខំដំណាក់កាលទី៣<នោះទេ។ ហើយដូចអ្វីដែលអង្គជំនុំជម្រះបាននិយាយ លោកអាចពន្លាតដោយបញ្ចូលភស្តុតាងមួយចំនួននៃការជម្លៀសដោយបង្ខំដំណាក់កាលទី៣។> វាមិនមែនជាផ្នែកនៃការជម្លៀសដោយបង្ខំទេ។ វាគ្រាន់តែជាផ្នែកនៃបោសសម្អាតកម្មាភិបាលភូមិភាគបូព៌ាប៉ុណ្ណោះ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតឆ្លើយតបដោយខ្លី ប្រសិនបើយើងអនុញ្ញាតឲ្យមានការសួរសំណួរបែបនេះ វានឹងមានការរំលោភបំពាន<ទៅលើសេចក្ដីបង្គាប់របស់អង្គជំនុំជម្រះ។ ប្រសិនបើអង្គជំនុំជម្រះអនុញ្ញាតឲ្យមានការពន្លាតនោះ គឺថាយ៉ាងហោចណាស់ គួរតែមានសំណើដ៏សមហេតុផលមួយ។ យើងគួរតែមានពេលវេលា និងការសម្របសម្រួលគ្រប់គ្រាន់ ដើម្បីរៀបចំខ្លួន>។

[១១:០០:០៩]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យសួរដេញដោលហៀរផុតពីវិសាលភាពនៃអង្គហេតុដែលបាន

កំណត់នៅក្នុងការបំបែកកិច្ចដំណើរការនីតិវិធីទេ ហើយពេលវេលាដូចជិតអស់ហើយ។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន តើខ្ញុំជិតអស់ពេលវេលាហើយឬ? ខ្ញុំគិតឃើញថា យើង<បាន>ចាប់ផ្ដើម<នៅ> ម៉ោងប្រាំបួនកន្លះឯណោះ ហើយយើងមានពេលដល់ទៅពីរវគ្គ។ <លោកប្រធាន យើងឯកភាពថា យើងមិនសួរសំណួរក្រៅវិសាលភាពបានទេ។ ជំហររបស់យើង គឺថាការបោសសម្អាត-->

**ប្រធានអង្គជំនុំ៖**

ពីរវគ្គសវនាការ យើងបានជួសជុល១០នាទីរួចហើយអម្បាញ់មិញ ហើយវគ្គនេះយើងជួសជុល ១០នាទីទៀតចប់ហើយ។ អំមិញដល់ម៉ោងប្រាំបួន -- ម៉ោងដប់ ម្ភៃនាទី ទើបយើងសម្រាក ប៉ុន្តែទោះបី យ៉ាងណាក៏ដោយសូមសួរតាំងសំណួរឲ្យមានប្រសិទ្ធភាព ហើយក្នុងអង្គហេតុដែលវាច្បាស់លាស់នៅ ក្នុងកិច្ចបំបែកកិច្ចដំណើរការនីតិវិធីដែលអង្គជំនុំជម្រះបានកំណត់។

**លោក នីកូឡាស គូមជែន៖**

សូមទោស បើសិនណាជាខ្ញុំយល់ខុស ការដែលយល់របស់ខ្ញុំគឺថាសាក្សីរូបនេះកំណត់ពេល១ថ្ងៃ គឺថាភាគីមួយៗមានពីរវគ្គ ហើយយើងបានចាប់ផ្ដើម<នៅ>ម៉ោងប្រាំបួនកន្លះ <យើងបានប្រើប្រាស់ ពេល>អស់មួយវគ្គទៅហើយ។

[១១:០១:៤០]

**ប្រធានអង្គជំនុំ៖**

ប្រាំបួនកន្លះ យើងធ្វើនីតិវិធីអស់១៥នាទីជារៀងរាល់សាកសួរដេញដោលភាគីណាក៏ដោយ។ អ៊ីចឹងនៅសល់តែ១៥នាទីទេ យើងជួសជុល១០នាទីរួចហើយ ភាគីទាំងពីរហ្នឹងនៅសល់តែយ៉ាងច្រើនតែ ៥នាទីទៀតទេ យើងនិងជួសជុលឲ្យ១០នាទីរហូតដល់ត្រឹមម៉ោងដប់មួយ សែសិបនាទី នៅរសៀលនេះ -- នៅព្រឹកនេះ។

**លោក នីកូឡាស គូមជែន៖**

អ៊ីចឹងមេធាវីការពារក្តីក៏មានតែមួយវគ្គដែរ អ៊ីចឹងទេលោកប្រធាន? <ខ្ញុំនឹងមានពេលសួរប្រាំ នាទីទៀត បើសិនដូច្នេះ-->

**ប្រធានអង្គជំនុំ៖**

ពីរវគ្គនៃថ្ងៃសវនាការ ចុះក្រែងពីរវគ្គអ្ហេ? ប្រាំបួន ដប់ប្រាំនាទីចាប់ផ្ដើម យើងជួសជុលអស់

ហើយ នៅសល់ ក្រែងពីរវគ្គតើអំមិញ មួយវគ្គជិតចប់ហើយ បញ្ចប់ហើយ ឥឡូវចូលវគ្គទី២ហើយនេះ។ យើងប្រឹងជួសជុល១០នាទីរួចហើយ យើងនឹងជួសជុល៥នាទី ឬ១០នាទីទៀតនៅវគ្គនេះ សម្រាប់វគ្គទី២ នេះ។

**លោក នីកូឡាស គូមជែន៖**

សូមទោសលោកប្រធាន។ ខ្ញុំយល់ច្រឡំ ខ្ញុំគិតឃើញថា <វគ្គនេះបញ្ចប់នៅ>ម៉ោងដប់មួយកន្លះ <ដូច្នេះ យ៉ាងហោចណាស់ ខ្ញុំមានពេលកន្លះម៉ោង។ ខ្ញុំនឹងប្រើប្រាស់ពេលប្រាំនាទី ប្រសិនបើវាអ៊ីចឹង នោះ។>

[១១:០២:៥៥]

**ប្រធានអង្គជំនុំ៖**

ត្រឹមត្រូវហើយ! ដល់ម៉ោងដប់មួយកន្លះ ហើយយើងនឹងថាបន្ថែមឲ្យរហូតដល់ម៉ោងដប់មួយ សែសិបនាទី គឺពីរវគ្គពេញនៅថ្ងៃនេះ នៅព្រឹកនេះគឺពីរវគ្គពេញសម្រាប់ភាគីទាំងពីរនេះ។

**លោក នីកូឡាស គូមជែន៖**

បាទ សូមទោសម្ដងទៀត។ ច្បាស់ហើយលោកប្រធាន យល់ហើយ សូមអរគុណច្រើន។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី យើងមានការជំទាស់ពីមេធាវីការពារក្ដី។ <ជំហររបស់យើង គឺថាវាស្ថិត> នៅក្នុងវិសាលភាព ក៏ប៉ុន្តែនៅត្រង់ទីតាំងនេះ <នៅក្នុងសហករណ៍ស្ទឹង គឺថាវាមានសារៈសំខាន់ណាស់ សម្រាប់ខ្ញុំ ក្នុងការសួរលោកអំពីរឿងនេះដំបូងគេ។> តើមានអ្នកដែលមកពីភូមិភាគបូព៌ាមកជាមួយ លោកដែរទេ? <តើក្រុមរបស់លោកហ្នឹង គឺ>មកពីបណ្ដាខេត្ត<ខុសៗគ្នា? តើលោកអាចពន្យល់បាន> ដែរឬទេ?

**2-TCW-913៖**

**ឆ៖** បាទ ពេលដើរមកជាមួយគ្នាហ្នឹងគេរើសខេត្តនេះពីរបីនាក់ ស្រុកនេះពីរបីនាក់អ៊ីចឹង អ៊ីចឹង ទេវាច្របូកច្របល់គ្នា ខ្ញុំអត់មានដែលស្គាល់គេផង។ មកថ្មីទែងអ៊ីចឹង គេរើសមក យើងមកពី ខ្ញុំនុំងមក ម្នាក់ឯង។ អ្ហ! ដល់មកទៅ វាមានស្រុកណា ស្រុកស្វាយទាប ស្វាយរំដួលអីចូលរួមគ្នាដើរមកជាមួយគ្នា ដើរច្រើនថ្ងៃណាស់ ដើរទម្រាំដល់ទីក្រុងភ្នំពេញ ដើរត្រង់ណា យប់ត្រង់ណាដេកត្រង់នុ៎ង។ ហ្នឹងឆ្លើយឲ្យ ច្បាស់លាស់អ៊ីចឹងតែម្ដង។--

**ស៖** <បាទ។ តាមចម្លើយរបស់លោក>--

[១១:០៤:២៣]

**ឆ៖** មនុស្សវាថ្មីទែង យើងមិនទាន់ស្គាល់គេផង។ អ៊ីចឹងទៅគេឲ្យចូលដើរមក ដើរជាមួយគ្នាមក ដើរអត់មានឡានអីជិះទេ ដើរថ្មើរជើងតែម្តង។

**ស៖** ឥឡូវខ្ញុំទុកសហករណ៍ស្ទឹងចោលសិន។ ខ្ញុំ<ចង់សួរលោក ថាតើលោកធ្លាប់ត្រូវបានគេបញ្ជូនទៅ>តំបន់កំពង់សោម<ដែរឬទេ>?

**ប្រធានអង្គជំនុំ៖**

អត់ទាន់សួរផង សួរស្អីគេឥឡូវហ្នឹង តំបន់កំពង់សោមមួយម៉ាត់ សួរអីគេឥឡូវ អត់ទាន់មានតាំងសំណួរផង។ ហើយតំបន់កំពង់សោមហ្នឹង វាស្ថិតក្នុងស្ថានភាពនៃ០០២/០២ ដែរឬទេ នៅក្នុងកិច្ចបំបែកដំណើរការនិតីវិធីដែរឬទេ? សូមប្រុងប្រយ័ត្នលើការលៀនចេញពីវិសាលភាពនៃដែនកំណត់នៅក្នុងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ដូច្នេះ តើគេមានបានបញ្ជូនលោកទៅកំពង់សោមដែរឬទេ?

**2-TCW-913៖**

**ឆ៖** បាទ លោកប្រធាន ចេញទៅពីត្រពាំងក្រឡឹង គេបញ្ជូនទៅកំពង់សោម ហៅតំបន់ស្ទឹងហាវ។ ចេញពីត្រពាំងក្រឡឹងទៅ ឡើងទៅកំពង់សោមហ្នឹង តំបន់ស្ទឹងហាវ ត្រង់នុំង គេដាក់ឈ្មោះ ស្ទឹងហាវៗ គេឲ្យខ្ញុំទៅធ្វើផ្លូវរទេះភ្លើងថ្មីនោះ ហើយធ្វើលូ ដាក់លូកន្លែងនោះ។ គេដកពីត្រពាំងក្រឡឹងទៅទៅកន្លែងនុំងទៀតហើយ ទៅដល់ម្តុំស្ទឹងហាវនោះ។

[១១:០៦:៣៥]

**ស៖** <ក្រុម>ដែលលោកធ្វើការជាមួយនៅស្ទឹងហាវ គឺសុទ្ធតែជាអ្នកដែលមកពីភូមិភាគបូព៌ា ឬក៏មកពីខាងណាដែរ? តើក្រុមដែលលោកធ្វើនៅស្ទឹងហាវហ្នឹង មានសមាសភាពមកពីខាងណាខ្លះដែរ?

**ឆ៖** មកពីបូព៌ាទាំងអស់ គេដកឲ្យទៅនៅបូព៌ា វាធ្វើឲ្យយើងធ្វើការធ្ងន់ៗ បាក់កម្លាំង។ ហ្នឹងចេញពីបូព៌ាទាំងអស់។ ប៉ុន្តែខ្ញុំអត់ស្គាល់ឈ្មោះ វាច្រើនពេក។ ដល់ទៅនៅរស់នៅជាមួយគ្នាហ្នឹង វាច្រើនអត់ស្គាល់ឈ្មោះគេទេ អត់បានរៀបរាប់ប្រាប់ឈ្មោះគេ អត់ដឹង។ អ៊ីចឹងទេ ហ្នឹងមកពីស្វាយរៀងទាំងអស់ ព្រៃវែង កំពង់ចាម ចូលទៅនោះ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** តើមានអ្វីកើតឡើងទៅដល់លោក និងអ្នកដែលមកពីភូមិភាគបូព៌ានៅឯស្ទឹងហាវនោះ?

**ឆៈ** បាទ ខ្ញុំស្ដាប់មិនទាន់សួរ មួយសាទៀត។ ខ្ញុំស្ដាប់អត់ច្បាស់។

**សៈ** តើលោកអាចជម្រាបជូនតុលាការបានទេថា មានអ្វីកើតឡើងចំពោះរូបលោកដែរ ឬក៏កើតឡើងចំពោះអ្នកដែលមកពីភូមិភាគបូព៌ានោះដែរ នៅពេលដែលលោក ហើយនិងអ្នកទាំងនោះធ្វើការនៅឯស្ទឹងហាវ?

[១១:០៧:៥៤]

**ឆៈ** បាទ មានសកម្មភាព គ្នាខ្ញុំទាំងអស់នៅនុ៎ង ៥០នាក់មានសកម្មភាព។ វាឲ្យបាយហូបមិនគ្រប់គ្រាន់ ដូច្នេះទេ ឲ្យបាយពួកខ្ញុំហូបមិនគ្រប់គ្រាន់ ខ្ញុំវាបាក់កម្លាំង កំហែងខ្លាំង ម៉្លោះហើយធ្វើការធូន់មិនបាន ម៉្លោះខ្លះឈឺ ខ្លះខ្វះស្បៀងហូបចុក ចេះតែដើររុករកផ្លែឈើ ផ្លែព្រៃហូប ដូច្នេះវាចោទយើង។ ដល់ចោទយើងទៅ យើងត្រូវមានកម្លាំងមួយសាមគ្គីគ្នាតស៊ូ ដេញចាប់អាមេប្រធានដាំបាយនោះ។ ដល់ចាប់អាមេប្រធាននោះ ឈ្មោះ ហឿន។ ចាប់ទៅ ស្រាប់តែទាហានវានៅជើងភ្នំ ចាប់បានហើយ យើងយកបញ្ជូនទៅអាកន្លែងទាហាន ព្រោះយើងឲ្យបាយស៊ីមិនគ្រប់គ្រាន់ ថាអាហ្នឹងម៉េចក៏ខ្លួនវា វាហូបគ្រប់គ្រាន់ ឲ្យខ្លួនឯងប្រជាជន កម្មករមិនឲ្យហូបគ្រប់គ្រាន់ អ៊ីចឹងទេចាប់។ ដល់ចាប់ទៅ ទាហានគេនាំបណ្ដើរ ហឿន ទៅតែម្ដងទៅកន្លែងទាហានគេនុ៎ង។ ស្អែកឡើងបានគេមកនាំពួកខ្ញុំទៅ ទៅប្រជុំដោះស្រាយបញ្ហាចាប់ ហឿន ហ្នឹង។ ដល់ទៅដល់ទៅ ហឿន នៅនុ៎ងមែន នៅអាកន្លែងទាហានគេនុ៎ង ប៉ុហឿន ហ្នឹង។ ហើយគេឲ្យខ្ញុំអង្គុយកៅអីស្រួលបួល ៥០នាក់ អង្គុយកៅអីស្រួលបួលអ៊ីចឹង ប៉ុន្តែមិនមែនកៅអីអ៊ីចឹងទេ កៅអីឈើធម្មតា ឲ្យអង្គុយក្រោមផ្ទះគំរូនោះ សម្រាប់ឲ្យគេហៅប្រជុំៗ គេថាទៅប្រជុំដោះស្រាយបញ្ហាឲ្យជ្រះស្រឡះឲ្យចេញ ព្រោះចាប់មេដាំបាយនៅនោះ ហើយ មេហឿន ហ្នឹងប្រធានរោងកន្លែងធ្វើការនៅម្ដុំស្ទឹងហាវហ្នឹង។ អ៊ីចឹងទេ ខ្ញុំក៏ព្រមព្រៀង គេហៅឈ្មោះខ្ញុំ មាន៥០នាក់គេហៅឈ្មោះ ហៅឈ្មោះ៥០នាក់ នាំគ្នាទៅពេលថ្ងៃត្រង់ គេថាងូតទឹកឲ្យស្រួលទៅ សម្លៀកបំពាក់ឲ្យស្អាតទៅ ប៉ុន្តែខោខ្មៅ អាវខ្មៅទេ ហើយក្រមាខៀវ។ ទៅៗ ៥០នាក់ ឈ្មោះនេះ ឈ្មោះនោះ ខ្ញុំអត់បានចាំគ្រប់គ្នាទេ។ ដល់ពេលទៅដល់នោះ គេប្រជុំៗ ស្រាប់តែអាម៉េច្រេវច្រាវៗ គេថា កុំរត់! កុំរត់! កុំរត់! ហើយខ្ញុំថា ចុយ! មានខ្មាំងឯណា អាហឿន ហ្នឹង ពួកហ្នឹងសុទ្ធតែចាប់ មិនឲ្យឯងហូបបាយគ្រប់គ្រាន់តើ! មានអីទៅជាអាហឿន ត្រូវវិញ អាអ្នកដាំបាយ មកខុសយើង។ មកខុសយើង គេចងយើងតែម្ដង ៥០នាក់ ចងក្រឹបៗ ខ្ញុំចងទៅ ប៉ុន្តែខ្ញុំភ្លេចហើយថ្ងៃខែខ្ញុំ ខ្ញុំអត់បានចំណាំ នាឡិកាខ្ញុំ គេដកទៅ ចង ប៉ុន្តែខ្ញុំដឹងតែរយៈ

ជប់--

[១១:១០:១៦]

**ស៖** បាទ សូមអរគុណ។ ខ្ញុំនឹងសួរសំណួរពីរបីបន្តពីរឿងនេះ។ ទី១ លោក<បានលើកឡើងថា ទៅ>កន្លែងកងទ័ព។ ដើម្បីសួរឲ្យបានច្បាស់ តើកន្លែងកងទ័ពនេះ ជាកន្លែងកងទ័ពរបស់ខ្មែរក្រហម ឬក៏មិនមែនទេ នៅពេលដែល<លោកបាននាំ> ហឿន ទៅ?

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ លោកប្រធាន។ អង្គជំនុំជម្រះបានសម្រេចច្បាស់ហើយ គឺថាវាស្ថិតនៅខាងក្រៅវិសាលភាពមែនទែននៃសវនាការវគ្គទី២នេះ។ អ៊ីចឹងខ្ញុំសូមជំទាស់ឡើងវិញ។ ហើយខ្ញុំក៏សូមលើកឡើងអំពីការកត់សម្គាល់ជាមួយសាក្សីមុននោះផងដែរ។ ឥឡូវនេះយើងនិយាយអំពីវគ្គមួយ គឺតួនាទីរបស់ជនជាប់ចោទ។ អ៊ីចឹងខ្ញុំឃើញថា មានការសួរមិនជាប់ពាក់ព័ន្ធតាំងពីដំបូង<អំពី នួន ជា និង ខៀវ សំផន>។ អ៊ីចឹងខ្ញុំ<មិនយល់ថា តើហេតុអ្វីបានជា>សួរសាក្សីរូបនេះ អំពីតួនាទីរបស់ជនជាប់ចោទ<។ សាជាថ្មីម្ដងទៀត មួយគឺជាការជំទាស់ មួយទៀតគឺការកត់សម្គាល់ឡើងវិញអំពីភាពពាក់ព័ន្ធ។>

**លោក នីកូឡាស គូមជែន៖**

ចាប់តាំងពីផ្ដើមសវនាការនេះគឺ២ឆ្នាំហើយ សេចក្ដីសម្រេចគឺថា នៅពេលដែលកោះហៅសាក្សីមកផ្ដល់សក្ខីកម្ម ទោះបីជាផ្ដល់សក្ខីកម្មទៅលើភស្តុតាងណាក៏ដោយ នៅក្នុងផ្នែកណាមួយក៏ដោយ រាល់ភស្តុតាងពាក់ព័ន្ធ គឺថាអង្គជំនុំជម្រះនឹងទទួលយកបាន។ យើងមាននិយាយគ្នាអំពីការបោសសម្អាតនៅភូមិភាគបូព៌ា គឺជាផ្នែកមួយនៃសំណុំរឿង០០២/០២។ សាក្សីរូបនេះ ឥឡូវនេះ និយាយអំពីការចាប់ខ្លួនគាត់ ហើយនិង<អ្នកផ្សេងទៀតចំនួន>៥០នាក់ ដែលទាំងអស់នោះគឺមកពីភូមិភាគបូព៌ា មកពីខេត្តព្រៃវែង ស្វាយរៀង។ អ៊ីចឹងត្រង់ចំណុចនេះច្បាស់ហើយ ការកំណត់គោលដៅ ការបោសសម្អាត ការសម្លាប់អ្នកដែលមកពីភូមិភាគបូព៌ា គឺវាស្ថិតនៅក្នុងវិសាលភាពនេះហើយ។ អ៊ីចឹងការយល់របស់យើងគឺថាតាំងសំណួរបែបនេះ គឺវាសមស្របទៅនឹងសេចក្ដី<សម្រេច>របស់អង្គជំនុំជម្រះហើយ។

[១១:១២:២២]

**ប្រធានអង្គជំនុំ៖**

យោង១សេចក្ដីសម្រេចត្រង់ណាមួយឥឡូវនេះ? ចង្អុលសេចក្ដីសម្រេចមើល? ព្រះរាជអាជ្ញាចង្អុលសេចក្ដីសម្រេចតុលាការមើល កន្លែងកថាខណ្ឌណាមួយដែលចង្អុលបង្ហាញឲ្យសួរវីករាលដាល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

គ្រប់ទីកន្លែង គ្រប់អង្គហេតុទាំងអស់ ឲ្យតែពាក់ព័ន្ធនឹងបូព៌ា។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំបានយោងទៅឧបសម្ព័ន្ធនៃសេចក្ដីសម្រេចរបស់លោកប្រធាន--

**ប្រធានអង្គជំនុំ៖**

កុំអាល! កុំអាលទាន់! កុំអាលទាន់! យើងចង់សួរព្រះរាជអាជ្ញា! ឲ្យព្រះរាជអាជ្ញាឆ្លើយវិញ ព្រោះគាត់ថានៅក្នុងវិសាលភាព។ ឥឡូវ សូមសហព្រះរាជអាជ្ញាអន្តរជាតិឆ្លើយ។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ខ្ញុំអត់មានសេចក្ដីសម្រេចអំពីវិសាលភាពនៃការជំនុំជម្រះនៅក្នុងដៃទេពេលនេះ ក៏ប៉ុន្តែច្បាស់ណាស់ ផ្នែកមួយនៃវិសាលភាពពាក់ព័ន្ធទៅនឹងការបោសសម្អាតកម្មាភិបាល ជាពិសេសការបោសសម្អាតកម្មាភិបាលភូមិភាគបូព៌ាតែម្ដង។ ចំណុចនេះ តាមការយើងខ្ញុំយល់ឃើញនេះ គឺ <មនុស្ស>ទាំង៥០នាក់ <មកពីភូមិភាគបូព៌ា ដែលបង់ក>ក្រមាខៀវនេះ <គឺជាគោលដៅសម្លាប់>នៅសម័យកម្ពុជាប្រជាធិបតេយ្យ<>។

[១១:១៣:៤៤]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំបានយោងទៅឧបសម្ព័ន្ធដែលភ្ជាប់ទៅនឹងសេចក្ដីសម្រេចគឺ<E301/9/1.1>, ERN អង់គ្លេស 00981687 កថាខណ្ឌ២ និយាយអំពីការស្វែងយល់អំពីអង្គហេតុពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋរួម អនុផ្នែក៣ និយាយអំពីមន្ទីរសន្តិសុខ ហើយទីតាំងឧក្រិដ្ឋកម្មដែលក្នុងនោះ រួមទាំងការបោសសម្អាតផ្ទៃក្នុងការអនុវត្តពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទល្មើសដែលបានកំណត់នេះ។ ដូច្នេះការបោសសម្អាតកម្មាភិបាលភូមិភាគបូព៌ានេះ គឺវាត្រឹមត្រូវហើយ ប្រសិនណាជាពួកគេនោះ ត្រូវបានឃុំខ្លួននៅស-២១ នៅក្រាំងតាចាន់ នៅភ្នំក្រោល និងអូរកន្សែង។ ការបោសសម្អាតជាទូទៅ នៅភូមិភាគបូព៌ា គឺថាវាមានកម្រិតរបស់វា។ មានការយោងទៅលេខយោងជើងទំព័រលេខ៩។ លេខជើងទំព័រយោងលេខ៩ និយាយអំពីទីតាំងភូមិសាស្ត្រជាក់លាក់មួយនៅភូមិភាគបូព៌ា គឺទីតាំងឧក្រិដ្ឋកម្មស្ទឹងតូច ហើយ<នៅក្នុងដីកាដំណោះស្រាយ កថាខណ្ឌ២៨៣, ៣០០> និយាយអំពីដំណាក់កាលនៃការផ្លាស់ប្ដូរទីលំនៅ ដំណាក់កាលទី៣។ ឥឡូវនេះសាក្សីនិយាយពីអ្វីដែលបានកើតឡើងនៅកំពង់ស្ពឺ <និងឡើងទៅទិសខាងជើង គឺ> កំពង់សោម។ អ៊ីចឹងមើលទៅ គឺមិនស្ថិតនៅក្នុងទីតាំងភូមិសាស្ត្រនៃលេខយោងជើងទំព័រនេះទេ គឺ<វា

មិនយោងទៅលើ>អនុផ្នែកត្រង់កថាខណ្ឌ៣។ <មានន័យថា>សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះច្បាស់លាស់ហើយ <ហើយគឺវា>មិនស្ថិតនៅក្នុងវិសាលភាពនេះទេ។ អ៊ីចឹងការបោសសម្អាតនៅភូមិភាគបូព៌ាតែវា<មិន>ស្ថិតនៅក្នុងវិសាលភាព<នេះទេ។ វាគ្របដណ្ដប់តែក្រុមកំណត់គោលដៅ> ដូចជាចាមជនជាតិវៀតណាម ហើយនិងមន្ត្រីរដ្ឋការ លន់ នល់ តែប៉ុណ្ណោះ។

[១១:១៦:១៦]

**លោក នីកូឡាស គូមជែន៖**

នៅត្រង់ទំព័រដដែល ដែលមេធាវីការពារក្ដីបានលើកឡើងនេះ គឺតុលាការបាននិយាយថា ផ្នែកមួយនៃវិសាលភាពពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួម។ លេខ៣ ពីមន្ទីរសន្តិសុខ និងទីតាំងឧក្រិដ្ឋកម្មរួមទាំងការបោសសម្អាតផ្ទៃក្នុង។ សហឧក្រិដ្ឋកម្មរួមតម្រូវឱ្យស្វែងរកផែនការរួម គោលនយោបាយស្ដីអំពីផែនការរួម ដែលមានចេតនារួម។ <មេធាវីការពារក្ដី បើ>តាមដែលខ្ញុំយល់ គឺថានៅទូទាំងរឿងក្ដីនេះទាំងមូល គឺថាមិនមានការកំណត់គោលដៅទៅលើអ្នកដែលមកភូមិភាគបូព៌ា ដោយសារតែអ្នកទាំងនោះមកពីភូមិភាគបូព៌ាទេ។ អ៊ីចឹងជំហររបស់មេធាវីការពារក្ដី គឺចោទថាអ្នកភូមិភាគបូព៌ាហ្នឹង គឺក្បត់ទាំងស្រុងតែម្ដង។ បញ្ហានៅក្នុងរឿងក្ដីនេះ ច្បាស់លាស់ណាស់ហើយ ថាតើអ្នកដែលមកពីភូមិភាគបូព៌ានោះ <គឺជាក្រុមដែលកំណត់គោលដៅ ដោយគ្មានការរើសអើង? តើ>វាជាផ្នែកមួយនៃការបោសសម្អាតដែលពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួមហ្នឹង<ដែរឬទេ?>

<នៅក្នុងដីកាដំណោះស្រាយ> កថាខណ្ឌ១៩៩ <ដល់>២០៣ ទោះបីជាទីតាំងឧក្រិដ្ឋកម្មដែលសាក្សីរូបនេះនឹងនិយាយប្រាប់ មិនមែនជាផ្នែក<>នៃមូលដ្ឋាន<ឧក្រិដ្ឋកម្ម>នៃការចោទប្រកាន់<ចំពោះឧក្រិដ្ឋកម្មជាក់លាក់នេះ ក៏>វាផ្នែកមួយសហឧក្រិដ្ឋកម្មរួម <និងបញ្ហាគោលនយោបាយ គឺថាវាជាប់ពាក់ព័ន្ធផ្ទាល់ជាមួយនឹងរឿងក្ដី ដែលខ្ញុំយល់ថា>មេធាវី <>មិនជំទាស់ដែរ ចំពោះការកាប់សម្លាប់កម្មាភិបាល<បូព៌ា>ជាច្រើននៅឯស-២១ <និងនៅកន្លែងផ្សេងទៀត។> គេកាប់សម្លាប់អ៊ីចឹង ដោយ-សារថា កម្មាភិបាលដែលមកពីភូមិភាគបូព៌ាហ្នឹង គឺសុទ្ធតែពួកកម្មាភិបាលក្បត់។ <ដូច្នេះ វាជាប់ពាក់ព័ន្ធទៅនឹងគោលនយោបាយ ក្នុងការកំណត់គោលដៅអ្នកដែលមកពីភូមិភាគបូព៌ា។ វាគឺជាផ្នែកនៃសហឧក្រិដ្ឋកម្មរួម។>

[១១:១៨:០៧]

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំក៏ភ្លេចលើកផងដែរ គឺថា វាស្ថិតនៅក្នុងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះមែន គឺលទ្ធភាពនៃការពង្រីកវិសាលភាព។ និយាយឲ្យចំពាក្យពេចន៍នេះតែម្ដង គឺថាក្រោយពីការស្នើសុំប្រកបដោយហេតុផល អង្គជំនុំជម្រះអាចនឹងពង្រីកវិសាលភាពសំណុំរឿង០០២/០២ ដើម្បីបញ្ចូលនូវអង្គហេតុទាំងឡាយដែលពាក់ព័ន្ធទៅនឹងការបោសសម្អាត<ផ្ទៃក្នុង នៅក្នុងភូមិភាគឧត្តរ និង>ភូមិភាគបូព៌ា <ដែលជាកម្មវត្ថុ[។ល។] ពាក់ទៅនឹងសិទ្ធិរបស់ជនជាប់ចោទ>។ អ៊ីចឹងសេចក្ដីសម្រេចនេះ បានកំណត់ច្បាស់លាស់ចំពោះកម្រិតនូវអ្វីដែលកើតឡើងចំពោះកម្មាភិបាលមកពីភូមិភាគបូព៌ា ហើយវាមិន<ទូលំទូលាយ និងពង្រីកវិសាលភាព ដូចទៅនឹង>ក្រុមគោលដៅទាំងបីទៀត ផ្សេងទៀតនោះទេ។ អ៊ីចឹងសេចក្ដីសម្រេចនេះ ច្បាស់លាស់ហើយ។

**លោក នីកូឡាស គូមជែន៖**

គឺថា មេធាវីការពារក្ដីនិយាយអំពីការបន្ថែមការចោទប្រកាន់ ដែលពាក់ព័ន្ធទៅនឹង<ទីតាំងជាក់លាក់មួយចំនួន ដែលវាជាផ្នែកនៃ>មូលដ្ឋានឧក្រិដ្ឋកម្មនេះ។ យើងខ្ញុំនិយាយអំពីគោលនយោបាយ និងចេតនានៃសហឧក្រិដ្ឋកម្មរួម ហើយការកំណត់គោលដៅនេះ វាជាគោលនយោបាយជាតិ ហើយវាអាចមានភរវនីយហេតុត្រឹមត្រូវផងដែរ <ពីព្រោះវាកើតឡើងនៅក្នុងតំបន់មួយ ដែលយើងមិនមានភស្តុតាងច្រើននោះទេ គឺនៅ>កំពង់សោមនេះ <បានបង្ហាញ>ឲ្យឃើញថា គោលនយោបាយ<ជាតិមួយ>នេះ <គឺកំណត់គោលដៅអ្នកដែលមកពីភូមិភាគបូព៌ា ដោយមិនគិតថាមានមូលហេតុណាមួយ ឬក៏មិនមាននោះទេ និងការកំណត់គោលដៅអ្នកមកពីភូមិភាគបូព៌ា ដោយមិនរើសអើង។> អ៊ីចឹងខ្ញុំសូមលើកឡើង<បញ្ហានេះ ដើម្បីឲ្យអង្គជំនុំជម្រះសម្រេច។> អ៊ីចឹងបើយើងសល់ពេលប្រហែលជា១៥នាទីទៀត ដើម្បីឲ្យសាក្សីរៀបរាប់អំពីបញ្ហាដែលកើតឡើង<>។

[១១:១៩:៥៨]

**ប្រធានអង្គជំនុំ៖**

មានអីទៀតទេ វ៉ិចទ័រ កូប៉េ?

អញ្ជើញ! ឡើងសេរីមើល៍!

**លោក វ៉ិចទ័រ កូប៉េ៖**

វាពិតហើយថាជាផ្នែកមួយនៃសហឧក្រិដ្ឋកម្មរួម។ វាជាបញ្ហាផ្លូវច្បាប់ហើយ គ្មានអ្នកណាអាចប្រកែកបានទេ។ <អ៊ីចឹងអ្វីដែលសហព្រះរាជអាជ្ញា យល់ថាវាស្ថិតនៅក្នុងវិសាលភាព គឺគ្រាន់តែ

និយាយថា វាគឺជាផ្នែកនៃ>សហឧក្រិដ្ឋកម្មរួម។ <វាមិនអាចទៅរួចនោះទេ>។ ប៉ុន្តែរឿងនេះគឺរឿងច្បាស់ គឺថាសម្រាប់មេធាវីការពារក្តី គ្រាន់តែថាតើការចោទប្រកាន់ចោទអំពីអ្វី។ អ៊ីចឹងហើយ<គឺអត់មានការលើកឡើងអំពីអ្វី ដែលបានកើតមានឡើងនៅ>កំពង់ស្ពឺ ឬនៅកំពង់សោម <ពាក់ព័ន្ធនឹងទៅនឹងអ្នកដែលមកពីភូមិភាគបូព៌ានោះទេ>។ ហ្នឹងច្បាស់លាស់ហើយ។

**លោក នីកូឡាស គូមជែន៖**

សូមបន្ថែមចំណុចតូចមួយទៅលោកប្រធាន។ សាក្សីរូបនេះមានឈ្មោះនៅក្នុងបញ្ជីសាក្សី តាំងពីមុនយើងចាប់សំណុំរឿង០០២/០២ទៅទៀត។ អ៊ីចឹងមេធាវីការពារក្តីមានចម្លើយរបស់សាក្សីមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា <ខ្ញុំគិតថា យើងមានវាទាំងអស់គ្នា ប៉ុន្តែនៅពេលក្រោយមក ក៏មានកំណត់ហេតុស្តាប់ចម្លើយផ្សេងទៀតដែរ។ ដូច្នេះពួកគាត់បានកត់សម្គាល់នូវ>ភស្តុតាងដែលនឹងត្រូវផ្តល់ដោយសាក្សីរូបនេះ។ <ជាថ្មីម្តងទៀត ខ្ញុំគិតថា> បញ្ហាដែលមេធាវីការពារក្តីប្រឹងការពារនោះ គឺដើម្បី<ប្រកែកតវ៉ានោះ គឺ>គោលនយោបាយ<>ជាតិ <និងចេតនាក្នុង>ការកំណត់គោលដៅទៅលើកម្មាភិបាលភូមិភាគបូព៌ា <ដោយមិនរើសអើង។ យើងសូមនិយាយថា វាច្បាស់ណាស់ គឺវាពាក់ព័ន្ធទៅនឹងបញ្ហាទាំងអស់នេះ>។

**ប្រធានអង្គជំនុំ៖**

មានអីទៀតទេ? ភាគីទាំងសងខាងមានអីទៀតទេ? បើមានអញ្ជើញ ឥឡូវផ្តល់សេរីភាពក្នុងការជជែកបញ្ហាហ្នឹងឲ្យបានដាច់ស្រេចពេលនេះ។

[១១:២២:២៩]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:២៥:០២]

**ប្រធានអង្គជំនុំ៖**

បាទ ប្រគល់ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីចេញសេចក្តីសម្រេចផ្ទាល់មាត់ លើបញ្ហានេះ ដើម្បីឲ្យបានច្បាស់លាស់។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះសូមរំឭកថា ទីតាំងឧក្រិដ្ឋកម្មដែលបានសួរនៅក្នុងសក្ខីកម្មនេះ គឺមិនចូលទៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២ទេ។ ដូច្នេះសហព្រះរាជអាជ្ញា មិន

ចាំបាច់សួរលម្អិតទៅលើប្រធានបទនេះទេ។ ក៏ប៉ុន្តែអង្គជំនុំជម្រះសូមរំឭកផងដែរថា ខ្លួនអនុញ្ញាតឲ្យសួរសាក្សីដើម្បីបង្ហាញអំពីគោលនយោបាយដែលកើតមាននៅថ្នាក់ជាតិ។ ជាពិសេសគោលនយោបាយដែលកំណត់គោលដៅជាក់លាក់ទៅលើក្រុមមួយចំនួន ជាពិសេសក្រុមដែលត្រូវបានគេចាត់ទុកថា ជាខ្មាំងផ្ទៃក្នុង ជាពិសេសគឺអ្នកមកពីខាងភូមិភាគបូព៌ា។ សហព្រះរាជអាជ្ញា បើលោកចង់សួរមួយសំណួរពីរសំណួរទៀត អាចសួរបាន ក៏ប៉ុន្តែកុំសួរលម្អិតពេក។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី សូមសួរពីរបីសំណួរទៀត ឆាប់ៗទេ។ លោកថា លោកហ្នឹងគេឲ្យពាក់ក្រមាបង់កក្រមាខៀវ តើក្រមាខៀវនេះបានមកពីណា?

[១១:២៦:៣២]

2-TCW-913៖

**ឆ៖** បាទ ក្រមាខៀវហ្នឹងគឺ ហឿន ចែកឲ្យ មួយៗម្នាក់។ ឲ្យយកទៅហ្នឹងដើម្បីគេថាឲ្យស្លៀកពាក់អាវខ្មៅខោខ្មៅ យកក្រមាខៀវទៅផង។ ដល់ទៅដល់អាកន្លែងនោះ ស្រាប់វានាំគ្នាប្រជុំទៅ ហើយឃើញទាហានវាព័ទ្ធជុំវិញអស់ ដល់ប្រជុំទៅ ស្រាប់គេអាមេច្រៃវច្រាវ គេថាកុំរត់! កុំរត់! គេយកអាក្រមាខៀវចងពួកខ្ញុំ ៥០នាក់គ្រប់គ្នា។ ចងគ្រប់គ្នាទៅ ហើយខ្ញុំថា ឯងមានពាក់ព័ន្ធមានខ្មាំងឯណា ឥឡូវមកចាប់គ្នាឯងមនុស្សស្លូតត្រង់។ នឹកក្នុងចិត្តអីចឹងថា ខ្លួនខ្ញុំវាស្លូតត្រង់ អង្កាល់នុំងខ្ញុំអាយុនៅក្មេងដែរជំនាន់នុំង អាយុទើប២០ជាង។ អីចឹងទៅ ឯងមិនដែលធ្វើអីឲ្យខុសឆ្គង គ្រាន់តែរឿងអាវ៉ាវ បាយហូបប៉ុណ្ណឹង ចាប់ អាប៊ុហឿន មកវាធ្វើបាបយើងពេក មិនឲ្យបាយ ឲ្យបាយយើងមិនគ្រប់គ្រាន់អីចឹង ខ្ញុំថាចាប់ហើយឲ្យកែប្រែ ទៅជាមិនកែប្រែ គេយកយើងជាខ្មាំងសត្រូវវិញ។ រួចខ្លួន អាហឿន។ គេយកខ្ញុំដើម្បីចងខ្ញុំ ដើម្បីសម្លាប់ខ្ញុំតែម្តង ៥០នាក់ ចងរយៈពេល១៣ថ្ងៃ ១៣យប់។

**ស៖** លោកសាក្សី ខ្ញុំគិតថា នេះគឺជាសំណួរចុងក្រោយរបស់ខ្ញុំហើយ ព្រោះខ្ញុំអស់ពេលហើយ តើលោកអាចពន្យល់អង្គជំនុំជម្រះឲ្យបានច្បាស់ជាងនេះ បន្តិចបានទេ ថាក្រោយពីលោក ហើយនិងអ្នកដទៃទៀត ៤៩នាក់ទៀត រួមទាំងលោកគឺ៥០នាក់ត្រូវបានគេចាប់ចង<នឹង>ក្រមាពណ៌ខៀវនោះរៀបរាប់ឲ្យបានច្បាស់លាស់បន្តិចមើល។

[១១:២៨:០០]

**ឆ៖** បាទ រៀបរាប់ឲ្យខ្លីៗទៅ គឺពេលគេចាប់ខ្ញុំចង ហើយគេទុកឲ្យខ្ញុំហ្នឹងបាក់កម្លាំង គេឲ្យ

ដំឡូងមើម មួយមើមពេលព្រឹក មួយមើមពេលល្ងាច អាដំឡូងមីយើងហ្នឹង អាដំឡូងសៀមហ្នឹង។ គេឱ្យយើងហូបមួយពេលហ្នឹង ឱ្យទឹកផឹកទៅ។ ដល់នេះ ខ្ញុំរាប់ថ្ងៃគឺ១៣ថ្ងៃ ១៣យប់។ វាសួរចម្លើយខ្ញុំ វាវៃធ្វើបាបខ្ញុំហ្នឹង។ ហើយយកដល់ពេលអាថ្ងៃ យប់ថ្ងៃ០៧ មករាហ្នឹង ខ្ញុំឆ្លើយឱ្យត្រង់តែម្តង យប់ថ្ងៃ០៧ មករា ខ្ញុំចំណាំបាន ថ្ងៃ០៧ មករាហ្នឹង វាថាឥឡូវហ្នឹងដោះស្រាយមិនចេញទេ កន្លែងហ្នឹង យកឱ្យបក្សយើងដោះស្រាយនៅភ្នំពេញ។ តែខ្ញុំ គេថា សុំចងជើង ចងដៃថែមមួយជាន់ទៀត។ ព្រឹកស្អែកហ្នឹង រទេះភ្លើងមកហើយ យើងការពារឡើងជិះរទេះភ្លើង លោតទម្លាក់ពីលើរទេះភ្លើង។ អ៊ីចឹងទេ គេចងពួកខ្ញុំថែមមួយជាន់ទៀត ចងជើងចងដៃទៅ។ ដល់ពេលនេះមិនឃើញស្អីមក ស្រាប់តែយប់ ប្រហែលជាយប់ម៉ោង អើ!យើងស្ទង់មើល ប្រហែលពាក់កណ្តាលអធ្រាត្រ ៥០នាក់ហ្នឹង គេយក១០ៗនាក់ចេញ មួយសា១០នាក់ មួយសា១០នាក់ យកទៅ។ ហើយខ្ញុំមិនដឹងគេយកទៅណា ដល់អ៊ីចឹងគេថា ឱ្យជិះរទេះភ្លើងឥឡូវរទេះភ្លើង អត់ឃើញមកផង។ អ៊ីចឹងទេ ឆ្ងល់ខ្លួនឯង។ ទៅមួយស្របក់អ៊ីចឹងមកវិញ យក១០នាក់ទៀត ទៅមួយស្របក់ទៀត យក១០នាក់ទៀត។ ដល់ពួកខ្ញុំនៅចុងក្រោយ១០នាក់ វាយកទៅដែរ ដល់ទៅប្រហែលជាបីបួនរយម៉ែត្រពីកន្លែងនុ៎ង បណ្តើរមកទុកនៅកន្លែងហ្នឹងវិញ។ ខ្ញុំឆ្ងល់ ម៉េចបានយកទៅហើយយកទុកវិញ។

[១១:២៩:២៦]

ដល់ព្រឹកឡើងតើ ម៉ោងប្រហែលម៉ោងប្រាំពីរព្រឹក វានាំយកទៅកំពូលភ្នំវៃពួកខ្ញុំចោលតែម្តង។ វៃចាក់ វៃចាក់ ខ្ញុំប្រាប់ថា វៃចាក់ វៃចាក់ ពួកខ្ញុំងាប់រលេពល ខ្ញុំក៏វាវៃងាប់ដែរ ប៉ុន្តែវាមិនដឹងម៉េច ដូចសាដង្ហើមឡើងវិញ។ ខ្ញុំប៉ុន្មានចំពុះទុង ហើយក្បាលខ្ញុំប៉ុន្មានដំបង។ វៃទៅខ្ញុំរស់រានមានជីវិត ខ្ញុំអើតឡើងពីកន្លែងមនុស្ស១០នាក់ងាប់ហ្នឹង មើលឃើញ អាប៊ុកាន មួយទៀត ឈ្មោះអាប៊ុកាន អានោះ។ អាប៊ុកកាន នោះធ្ងើងមកទៀត ផុសធ្មើបមក ឡើងមក ខ្ញុំថាមក កាន។ ដល់មកអ៊ីចឹង ស្រាប់តែគេឡើងជ្រោងដៃជាប់ចំណង ទាំងជើងទាំងអីអ៊ីចឹង។ ហើយខ្សែភ្លើងអគ្គិសនី មកមួល មួលខ្ញុំម្ខាងម្នាក់ វាមួលខ្ញុំមុន ខ្ញុំមួលឱ្យវាមុន។ មួលរួចទៅ បានខ្ញុំពពោកដី កន្លែងឈាម កន្លែងវៃឈាមហូរហ្នឹង ពពោកដី អានុ៎ងពពោកខ្ញុំ ខ្ញុំពពោកវា ផឹកទឹកនោមឯង ខ្ញុំរស់រានមានជីវិត ទាល់ឥឡូវសព្វថ្ងៃហ្នឹង និយាយឱ្យខ្លីៗអ៊ីចឹង។ ហើយខ្ញុំក៏ឡើងទៅរកខោអាវស្លៀកពាក់កន្លែងការដ្ឋានខ្ញុំនុ៎ង ស្រាប់វារត់បាត់អស់ហើយ។ ដល់រត់បាត់អស់ ខ្ញុំចូលអង្ករ យកអង្ករពួកវារត់នោះ ចោលអង្ករ ចោលស្អីៗនុ៎ង ខ្ញុំទៅយកអង្ករ យកឆ្នាំងដាំបាយហូប បានខ្ញុំរស់រានមានជីវិត ខ្ញុំនៅនឹងរូងភ្នំ រយៈពេលប្រហែលមួយខែជាង បានខ្ញុំចេញមកផ្ទះស្រុក

កំណើតខ្ញុំវិញ។ ហ្នឹងរាយប្រាប់លោកប្រធានអ៊ីចឹង។

**លោក នីកូឡាស គូមជែន៖**

អ៊ីចឹងខ្ញុំអស់សំណួរហើយ ហើយយល់ឃើញថា សហមេធាវីនាំមុខ ក៏មានសំណួរខ្លះផងដែរ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ លោកប្រធាន គឺលោកមេធាវី ហុង គឹមសួន គាត់មានសំណួរមួយចំនួនតូច ដើម្បីសួរទៅកាន់សាក្សី។ សូមលោកប្រធានអនុញ្ញាត។

[១១:៣១:១៥]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

សូមអញ្ជើញ!

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** បាទ ខ្ញុំសូមអរគុណ និងសូមគោរពលោកប្រធាន និងលោកស្រី លោកចៅក្រម ព្រមទាំងអង្គសវនាការជាទីគោរព។ ដើម្បីឱ្យឆាប់សាកសួរ ខ្ញុំសួរបន្តពីសហព្រះរាជអាជ្ញាបន្តិច។ លោកបានជម្រាបគាត់ថា លោកអត់ដែលស្គាល់អង្គការមួយ ឈ្មោះអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាទេ កាលពីឆ្នាំ២០០៥។ ប៉ុន្តែខ្ញុំសួរអ៊ីចេះវិញ សួរថាកាលពីឆ្នាំ២០០៥ មានក្រុម មួយក្រុមដែលគេទៅសួរលោកទៅដល់ផ្ទះលោកនៅភូមិបឹងហ្នឹងដែរទេ?

[១១:៣២:០៣]

**2-TCW-913៖**

**ឆ៖** បាទ ខ្ញុំឆ្លើយហួស កន្លែងហ្នឹងពី ២០០៥ទៅមែន ថ្ងៃនុ៎ងទៅកំពុងភ្លៀង ខ្ញុំឡើងពីធ្វើស្រែទៅសម្អាសខ្ញុំកំពុងភ្លៀង ប៉ុន្តែទៅហ្នឹង អត់អញ្ជើញខ្ញុំមកហ្នឹងទេ គ្រាន់តែទៅ គាត់ថត គាត់អីហើយ ឱ្យខ្ញុំឆ្លើយនុ៎ង ហើយខ្ញុំឆ្លើយតាមតែហ្នឹង ខ្ញុំអត់មានឆ្លើយខុសពីហ្នឹងទេ ប៉ុន្តែខ្ញុំអត់ចំណាំឈ្មោះគាត់ ខ្ញុំភ្លេច។ គាត់ទៅពីរនាក់ កូនឡានតូចមួយ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងមុនពេលដែលលោកអញ្ជើញមកដល់ថ្ងៃនេះ មកសវនាការនេះ លោកបានអានអាឯកសារដែលអង្គាល់ពួកក្រុមហ្នឹង ទៅសាកសួរលោកឡើងវិញដែរទេ?

**ឆ៖** បាទ នេះ អានហ្នឹង គាត់យកទុកខ្ញុំមួយហ្នឹង គាត់ទុកខ្ញុំមួយ។ គាត់យកទៅថ្មីហ្នឹង ប្រវត្តិរូបហ្នឹង។ ប្រាប់លោកប្រធាន។

**ស៖** បាទ អរគុណ។ អម្បាញ់មិញ លោកសហព្រះរាជអាជ្ញាសួរលោកទាក់ទងជាមួយនឹងការធ្វើការងាររបស់លោកនៅពហុកីឡដ្ឋាន យើងហៅបុរីកីឡានោះ។ លោកថា លោកអត់បានដឹង ឬក៏អត់បានឃើញថ្នាក់ដឹកនាំ។ អ៊ីចឹងការរំឭកចងចាំរបស់លោកឡើងវិញ តើលោកមានបាននិយាយទាក់ទងអំពីការឃើញ ឬដឹងពីថ្នាក់ដឹកនាំលោក ខៀវ សំផន ឬលោក ប៉ុល ពត ឬលោក នួន ជា ដែរទេ នៅក្នុងការសម្ភាសនោះ?

**ឆ៖** បាទ ខ្ញុំអង្គាល់សម្ភាសនុ៎ង ខ្ញុំ មានអត់ អត់មានគាត់សួរអីដល់ថ្នាក់ឃើញអ៊ីចឹង ខ្ញុំអត់ដែលដឹងដែរ។ ខ្ញុំឆ្លើយត្រង់ អត់មានដែលឃើញទេ ខ្មែរក្រហម ប៉ុល ពត, អៀង សារី គ្រាន់តែឮតែឈ្មោះ។

**ស៖** មកទាល់ហ្នឹងថ្ងៃនេះវាមានរយៈពេល១១ឆ្នាំទៅហើយ អ៊ីចឹងការចងចាំរបស់លោកជាមួយនឹងការសម្ភាសជាមួយក្រុមហ្នឹង តើលោកនៅចាំបានច្រើន ឬក៏តិច ឬក៏ភ្លេចខ្លះដែរទេ?

[១១:៣៤:០៩]

**ឆ៖** បាទ ខ្ញុំចាំវាតិច ភ្លេចច្រើនដែរ ឆ្លើយប្រាប់ត្រង់អ៊ីចឹង វាភ្លេច ដូចថាវាល្ងើដែរ ក្រោយគេវៃខូចខួរក្បាលអីទៅ គេវៃរយៈរយាយក្បាលអស់ ខ្ញុំមិនបានរៀបរាប់បានក្បោះក្បាយ ចាំវាតិច ភ្លេចវាច្រើន។ ជួនណានិយាយទៅវាហួសទៅ ជួនណាអី ប៉ុន្តែការពិត ខ្ញុំនិយាយតាមតែដំណើរខ្ញុំ គាត់សួរខ្ញុំ វាក់ ២០០៥ ខ្ញុំទើបនឹកឃើញ វាភ្លេច។ គាត់ទៅកាត់ខែភ្លៀវហ្នឹង ទៅសួរខ្ញុំ ខ្ញុំស្មានថាឡានស្អី។ ដល់ទៅសួរទៅ ចំផ្ទះខ្ញុំតែម្តង។

**ស៖** បាទ សូមអរគុណ។ លោកប្រធាន សូមអនុញ្ញាតរំឭកឯកសារការសម្ភាសរបស់គាត់ដែលមានលេខ E305/13.23.377 និងលេខមួយទៀត ឯកសារតែមួយ គឺលេខ E3/9086 ហើយនៅត្រង់ចំណុចភាសាខ្មែរ ERN 00977451 ហើយក្នុងនេះលេខ ERN ជាភាសាអង់គ្លេស 00983507។ ក្នុងនេះខ្ញុំបាទមិនមានជាភាសាបារាំងទេ។ ចំណុចនេះខ្ញុំចង់រំឭកសាក្សីទាក់ទងជាមួយនឹងការសាកសួរ គាត់ឆ្លើយទាក់ទងជាមួយនឹងទំព័រទី១៣ ភាសាខ្មែរដែលលេខ ERN 00977451 ថាសំណួរសួរថា៖ “ទាំងអស់ពីណាខ្លះពូស្គាល់ដែរទេ? ហើយលោកសាក្សីឆ្លើយថា៖ មកតាំងពីខេត្ត មកពីក្រចេះ រតនគិរី មណ្ឌលគិរី គ្រប់ខេត្តឱ្យតែកម្មាភិបាលស្រុក។ ហើយសំណួរមកខាងក្រោមទៀត គេសួរអំពី៖ ចុះអ្នកធំគេនៅភ្នំពេញពីណាគេចូលប្រជុំ? ហើយគាត់ឆ្លើយថា៖ ខៀវ សំផន ហើយនិង ប៉ុល ពត។ ថ្ងៃណាខៀវ

សំផន ៗទៅ ថ្ងៃណាប៉ុល ពត ៗទៅ។” អ៊ីចឹងចំណុចនេះ តើលោកសាក្សីមានការចងចាំឡើងវិញទេ ថាបានឆ្លើយនឹងសំណួរហ្នឹងទេ?

[១១:៣៦:២៣]

**ឆ៖** បាទពេលនុ៎ងខ្ញុំសួរគេ ដល់សួរគេទៅ គេសួរថា ថ្ងៃហ្នឹងពីណាគេមកបង្រៀន? គេនុ៎ង គេប្រាប់ថា ខៀវ សំផន។ ថ្ងៃណាគេមកបង្រៀន ថ្ងៃក្រោយទៀត គេថា ប៉ុល ពត តែខ្ញុំអត់បានទៅឃើញផ្ទាល់។ អត់ដែលបានទៅឃើញផ្ទាល់ជាក់ស្ដែងទេ គ្រាន់តែថា សួរគេទៅ។ ហ្នឹងខ្ញុំនៅបុរីកីឡាហ្នឹង ខ្ញុំអ្នកដាំបាយ បម្រើភ្ញៀវហ្នឹង។

**ស៖** សូមអរគុណ។ ចុះដែលលោកសួរគេ ឬក៏គេប្រាប់លោកហ្នឹង មានគេប្រាប់ថា មានលោក នួន ជា ក៏ចូលរួមក្នុងការប្រជុំ ឬរៀនហ្នឹងដែរទេ?

**ឆ៖** ទេ ពេលនុ៎ងអត់ដឹង មានលោក នួន ជា ចូលទេ មានតែ ខៀវ សំផន។ ជាក់ស្ដែង ខៀវ សំផន ចូលជាងគេ ឧស្សាហ៍ចូល។ ប៉ុល ពត ក៏មិនដែលសូវចូលដែរ បើ ខៀវ សំផន ចូលគ្រប់ឲ្យតែពេលសិក្ខាកាមរៀន ប៉ុល ពត -- ប៉ុល ពត អត់ដែលមកទេ នួន ជា មិនដែលមកទេ មកតែ ខៀវ សំផន ឧស្សាហ៍មក។ ប៉ុន្តែខ្ញុំអ្នកបម្រើភ្ញៀវ ខ្ញុំសួរគេទៅ គេប្រាប់អ៊ីចឹង។

**ស៖** បាទសំណួររបស់ខ្ញុំចង់សួរទាក់ទងជាមួយនឹងការស្គាល់ ឬការឃើញ។ លោកដែលលោក នួន ជា ឬ ខៀវ សំផន ទេនៅក្នុងបុរីកីឡា ទោះឃើញជិតក៏ដោយ ឃើញឆ្ងាយក៏ដោយ? បាទ ខ្ញុំបាទសូមរំឭក--។

**ឆ៖** បាទ អត់ដែលឃើញទេ អត់ដែលឃើញទេ។ អត់ដែលឃើញមុខផ្ទាល់ទេ ឮតែសំឡេង ឮឈ្មោះ។

[១១:៣៧:៥៣]

**ស៖** បាទ ខ្ញុំបាទសូមអនុញ្ញាតបង្ហាញសំណួរនៅក្នុងបន្ទាត់ និងទំព័រដដែល លេខ 00 – ERN 00977451 ភាសាខ្មែរ និង00983507 ភាសាអង់គ្លេសដដែល ត្រង់សំណួរនៅខាងក្រោម ទាក់ទងជាមួយនឹងសំណួរសួរថា តើលោក -- គេសួរថា “ខៀវ សំផន រាងគាត់ម៉េចដែរ? ហើយលោកឆ្លើយថា៖ រាងរៅស សខ្ពស់ សក់អញ្ចាញ។ អ្នកសួរថា ចុះ នួន ជា? នួន ជា ខ្មៅល្មមទេ ក្បាលរាងប៉ែកបន្តិច ប៉ុល ពត ប្រហែលគ្នា ពីរនាក់ហ្នឹង។ ចុះមានដឹងពីឋានៈរបស់គាត់ទេឮ នួន ជា, នួន ជា? លោកឆ្លើយថា បាទ នួន ជា ប្រធាន, ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋ។” សំណួរខ្ញុំសួរថាតើខ្ញុំអានអម្បាញ់មិញនេះ ជា

ចម្លើយរបស់លោកកាលគេសាកសួរ ឬក៏លោកភ្លេច?

**ឆ៖** បាទ សូមឆ្លើយ រឿងពាក្យថា ខៀវ សំផន វាងសក់យ៉ាងម៉េច នួន ជា យ៉ាងម៉េចនេះ អានេះគឺគេៗនិយាយប្រាប់ខ្ញុំដែរ គេប្រាប់ហើយ យើងថាតាមតែគេហ្នឹង គេឃើញអាម៉េច យើងថាតាមនុ៎ង។ តែដូចខ្ញុំរៀបរាប់អីចឹង។ បើ ខៀវ សំផន ឧស្សាហ៍ចូលទៅបង្រៀន ហើយគេប្រាប់ខ្ញុំថា ខៀវ សំផន មកចូលបង្រៀនហើយ។ អីចឹងទេខ្ញុំអត់ដឹង ប៉ុន្តែគេមិនហៅដាច់សាច់ ខៀវ សំផន អីចឹងទេគេថាកម្មាភិបាលចូលបង្រៀនហើយ ឈ្មោះ ខៀវ សំផន។ ហ្នឹងឆ្លើយត្រង់អីចឹងតែម្តង ប៉ុន្តែបើឲ្យខ្ញុំដឹងអី ច្បាស់លាស់ ទៅឃើញនុ៎ង អត់ច្បាស់។ អត់ដែលឃើញច្បាស់លាស់រឿងគាត់របៀបម៉េចៗទេ។

**លោក ហុង គីមសួន៖**

បាទ សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយបាទ។ សូមអរគុណ។

[១១:៣៩:៥៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយដល់ពេលសម្រាកថ្ងៃត្រង់ហើយ ហើយមុននឹងសម្រាកអង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីថា សវនាការបន្ទាប់ពីស្តាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCW -- 2-TCCP-235 ដោយមូលហេតុថា សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន កាលពីព្រឹកមិញថាគាត់មានបញ្ហាសុខភាព ប៉ុន្តែព័ត៌មានថ្មីចុងក្រោយនេះ បានន័យថា ឥឡូវនេះមានព័ត៌មានថ្មីបន្ថែមទៀត គាត់បានចាកចេញកន្លែងដែលគាត់ស្នាក់នៅៗសណ្ឋាគារនោះហើយ ហើយអត់ដឹងដំណឹងថាទៅណាទេ ទាក់ទងតាមទូរស័ព្ទហ្នឹងគឺមិនទទួលទេ។ ហើយអង្គភាពគាំពារសាក្សី និងអ្នកជំនាញកំពុងតែព្យាយាមក្នុងការទាក់ទងជាមួយគាត់ ហើយនិងផ្តល់ព័ត៌មាននៅពេលក្រោយ។ អីចឹងលទ្ធភាពចំពោះមុខនេះ គឺការប៉ាន់ប្រមើលមើល គឺគាត់មិនអាចមកផ្តល់សក្ខីកម្មនៅថ្ងៃស្អែកបានទេ។ អីចឹងសូមភាគីជ្រាប និងឲ្យដឹងព័ត៌មានអំពីការដែលអង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់ ធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-235 បន្ទាប់ពីស្តាប់សក្ខីកម្មសាក្សីរូបនេះចប់។

បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ ហើយអង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់

សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក ហើយនិងអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងមួយកន្លះសៀល។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៤១ នាទី ដល់ម៉ោង ១៣:៣១នាទី)*

[១៣:៣០:៥៤]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីតាំងសំណួរដេញដោលមួយចំនួនចំពោះសាក្សីរូបនេះ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ លោកសាក្សី ខ្ញុំជាចៅក្រម ឡាវែន៍។ ខ្ញុំមានសំណួរប្រហែលជាពីរ<ប្រធានបទ>ទេដើម្បីសួរលោក។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** សំណួរដំបូងខ្ញុំចង់ដឹងថា ពេលដែលលោកធ្វើការនៅ ក-៥ នៅបុរីកីឡា មានតែលោកទេក្នុងក្រុមគ្រួសារលោកដែលធ្វើការនៅហ្នឹង ឬក៏លោកមាន<បងប្រុសម្នាក់>ធ្វើការនៅទីនុំងដែរ?

**2-TCW-913៖**

**ឆ៖** បាទលោកប្រធាន ខ្ញុំសូមឆ្លើយ មានតែខ្លួនខ្ញុំម្នាក់ធ្វើការនៅនុ៎ង មកពីស្រុកមកមានតែម្នាក់ទេ បងប្អូនអត់មានទេ លោកប្រធាន ទទេ អត់មាន មានតែខ្ញុំម្នាក់ឯងគត់ សឹកពីលោកមក គេហៅមកចូលហ្នឹង។

[១៣:៣២:៥៥]

**ស៖** ខ្ញុំសួរសំណួរនេះ ពីព្រោះថា នៅក្នុងប្រវត្តិរូបដែលគេបង្ហាញជូនលោកព្រឹកមិញនោះ គឺ E319/23.3.38.1 នៅទំព័រចុងក្រោយគឺ ERN ជាភាសាអង់គ្លេស 00983490, ជាភាសាខ្មែរ 00977436។ នៅចំណុចទី១១ លោកថា [redacted]និង [redacted] បានចូលទៅខាងយោធា ហើយទទួលបន្ទុកខាងចិញ្ចឹមទានៅ ក-៥។ អ៊ីចឹងតើលោកមានបង ឬក៏ប្អូន ឈ្មោះ [redacted] ទេ បងប្រុសរបស់លោកឈ្មោះអីដែរ?

**ឆ៖** បាទ បងប្អូនខ្ញុំបង្អស់មានតែខ្ញុំបងគេ លោកប្រធាន។ ហើយ[redacted]ស្លាប់ហើយ។ [redacted]ហ្នឹងប្អូនខ្ញុំ ខ្ញុំបងគេបង្អស់។ អត់មានបងខ្ញុំទេ មានតែខ្ញុំ បងគេបង្អស់។

**ស៖** អ៊ីចឹងមុនពេលបងលោកស្លាប់ហ្នឹង គាត់ត្រូវជាបងរបស់លោកហើយអ៊ីចឹង គាត់មានធ្វើការនៅជាមួយលោក នៅក-៥ ទេ?

**ឆ៖** *(ឮមិនច្បាស់)* ស្លាប់នោះ អត់មានធ្វើការជាមួយគ្នាផង ទទេ មកតែខ្លួនឯង ប្អូនខ្ញុំស្លាប់ជំនាន់ លន់ នល់ ប្អូនខ្ញុំស្លាប់ជំនាន់ លន់ នល់។ តែខ្ញុំនៅរស់ ខ្ញុំមកធ្វើអត់មានបងប្អូនមកជាមួយទេ អត់បានមកនៅជាមួយគ្នាផង។ ខ្ញុំបងគេបង្អស់។

**ស៖** ឥឡូវខ្ញុំចង់ត្រឡប់មកសួរលោក អំពីស្ថានភាពនៅពេលដែលលោកបួសជាព្រះសង្ឃលោកអាចប្រាប់បានទេ គេនិយាយយ៉ាងម៉េចខ្លះនៅពេលដែលគេបង្ខំឱ្យលោកផ្សឹកនោះ?

[១៣:៣៥:៥១]

**ឆ៖** បាទ គេនិយាយឱ្យបង្ខំឱ្យផ្សឹកជាព្រះសង្ឃហ្នឹង គឺគេថារបបយើងបដិវត្តហ្នឹង គឺគ្មានពីណានៅមានលោក មានអីទៀតទេ ចាប់ផ្ដើមសឹកទៅ។ បើថាមិនសឹកទេ គេឱ្យក្របីមួយនឹមធ្វើស្រែរបស់ខ្លួន ធ្វើស្រែហូបខ្លួនឯងទៅ។ អាហ្នឹងនយោបាយរបស់គេ គេប្រាប់ខ្ញុំអ៊ីចឹង។ តែគេថា បង្ខិតបង្ខំម៉្ងៃៗទៀត ម៉្ងៃៗទៀត មកដេញដោលឱ្យខ្ញុំផ្សឹក។ ហើយសឹកហ្នឹងគ្មានមានអាចារ្យ មានធ្វើបុណ្យអីទេ សឹកហ្នឹង បកចីពរធម្មតាតែម្ដង។ ផ្សឹកទាំងអស់គ្នាមួយវត្តនោះ ផ្សឹកម៉្ងៃនុ៎ងអស់រលីង។ អត់មានបង្ខិតបង្ខំអីថា អ្ហេ! សឹកម៉េចៗទេ គេត្រូវតែឱ្យសឹកតែម្ដង ចង់ មិនចង់ ត្រូវគេឱ្យសឹកតែម្ដង។ គេថា យើងបើនៅ

ទេ គេរកក្របីឲ្យមួយនឹមម្នាក់ ឲ្យធ្វើស្រែភ្ជួររហូប ធ្វើស្រែយកស្រូវហូបខ្លួនឯងទៅ គេថាអ៊ីចឹង។ ដូច្នេះ យើងរស់នៅម៉េចនឹងបាន។ បើពេលគេប្រចំយើងសឹកហើយ យើងទូទាំងប្រទេសគេផ្សឹកទាំងអស់ គ្មាននៅវត្តណាមួយផង។ បញ្ហារឿងលោកសង្ឃ គេបំបាត់ភស្តុតាង គេមិនឲ្យយើងជឿព្រះពុទ្ធសាសនាតែម្តង ជំនាន់នុ៎ង។ គេនិយាយអ៊ីចឹងតែម្តង គេឲ្យយើងសឹកជាបន្ទាន់ អត់ឲ្យនៅរួញរាទេ។

**ស៖** តើពេលដែលគេបង្ខំឲ្យសឹកហ្នឹង មានគ្នាប៉ុន្មាននាក់ដែរ ដែលជាព្រះសង្ឃហ្នឹង? គឺព្រះសង្ឃនៅកន្លែងហ្នឹង គេផ្សឹកម្តងទាំងអស់គ្នាតែម្តង ឬក៏គេផ្សឹកបន្តិចម្តងៗ?

**ឆ៖** បាទ ព្រះសង្ឃនៅក្នុងវត្តខ្ញុំបាទហ្នឹង គឺគេផ្សឹកម៉្ងៃហ្នឹង ទាំងអស់តែម្តង ១៩អង្គផ្សឹកទាំងអស់។ តែខ្ញុំរៀបរាប់មិនបានអស់ ភិក្ខុមិនដឹងប៉ុន្មាន សាមណេរមិនដឹងប៉ុន្មាន ប៉ុន្តែមាន១៩អង្គក្នុងវត្តនុ៎ងផ្សឹកទាំងអស់។ ហើយទៅបួសអង្គាល់នុ៎ង គឺទៅបួស គេចពីធ្វើទាហានជំនាន់ លន់ នល់ បានគេ ម្តាយឪពុកឲ្យទៅបួសទៅ ក្រែងវាបានរស់រានមានជីវិតខ្លះ ព្រោះតែនេះ ប៉ុល ពត វាចាប់ឲ្យធ្វើទាហានតែម្តង។ អ៊ីចឹងទេគេច ដូចខ្ញុំហ្នឹង ប្អូនខ្ញុំទៅមួយហើយ ខ្ញុំនៅមួយ ម៉ែ ម្តាយឪពុកខ្ញុំថា មិនបាច់ទៅនេះទេ តែនេះគេហៅធ្វើទាហានទៀតហើយ។ អ៊ីចឹងទេហ្នឹង គឺមកបួសទៅ គេចក្រែងរួចខ្លួន អត់រួចទៀត នៅតែផ្សឹកដដែល។

[១៣:៣៨:២៩]

**ស៖** នៅពេលដែលគេផ្សឹកលោកនោះ តើមានអ្នកណាខ្លះមានវត្តមាននៅទីនោះ? មានមេឃុំ មេភូមិ មេស្រុក មេតំបន់អីទេ ឬក៏មានឈ្លប មានអ្នកកាន់អាវុធអីនៅពេលដែលលោក គេបង្ខំលោកផ្សឹកហ្នឹង?

**ឆ៖** បាទ ពេលគេបង្ខំឲ្យខ្ញុំផ្សឹក គឺមានគេហៅគណៈឃុំ គណៈឃុំក្រសាំង។ គណៈឃុំក្រសាំងហ្នឹងឈ្មោះ តាសំអ៊ាត ហើយនិងគណៈឃុំត្រស់ហ្នឹង ពីររូបហ្នឹង ឃុំត្រស់តែមួយ ប៉ុន្តែដល់ជំនាន់នុ៎ង គេបែងចែកជាពីរឃុំ ឃុំត្រស់ផង ឃុំក្រសាំងផង ដំបូងតែឃុំត្រស់តែមួយទេ។ តែនេះទៅ បែបជាមនុស្សច្រើនដឹង គេបែកជាឃុំក្រសាំងមួយ។ ហើយអ៊ីចឹងហ្នឹង ពីរនាក់ហ្នឹងទៅបណ្តេញឲ្យខ្ញុំសឹកក្នុងវត្តនុ៎ង។ តាសំអ៊ាត និង តាយ៉ង – ណុប យ៉ង។ ឈ្មោះ ណុប យ៉ង នៅឃុំត្រស់។ តាសំអ៊ាត នៅឃុំក្រសាំង។ គេដើរទៅទាំងពីរនាក់ហ្នឹង គេ ដើម្បីគេដេញលោកគ្រប់វត្តទាំងអស់ ឲ្យសឹក។ មេឃុំ ហ្នឹងៗត្រឹមគណៈឃុំទេ បណ្តេញឲ្យសឹកហ្នឹង គណៈឃុំក្រសាំង និងគណៈឃុំត្រស់។

**ស៖** តើគណៈឃុំទាំងពីរហ្នឹង ពេលដែលគាត់មកហ្នឹង <តើមាន>ឈ្លបកាន់អាវុធអី ហែហម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

គាត់មកទេ?

**ឆ៖** បាទ មាន។ មានកាំភ្លើងខ្លី មកប្រចំឲ្យលោកសឹក។ ហើយអ្នកទាំងពីរនាក់ហ្នឹង សុទ្ធតែអ្នកធ្លាប់បួស ធ្លាប់រៀនដែរ សុទ្ធតែសង្គ្រាជវត្តពីដើម។ តែគាត់ ដល់គាត់យល់ជ្រៅទៅ គាត់ធ្វើបាបព្រះសង្ឃ។ ខ្ញុំដឹងក្ដីមក គាត់ហ្នឹងសុទ្ធតែអ្នកបួស ៗយូរអង្វែងណាស់ គាត់ធ្វើសង្គ្រាជ កាន់កាប់វត្តមួយៗយូរឆ្នាំ។ ប៉ុន្តែដល់ពេលចុងក្រោយ គាត់ទៅជាភ្លេចប្រវត្តិគាត់អ្នកបួសអ្នករៀន គាត់មកបណ្ដេញពួកខ្ញុំផ្សឹក។ ពេលខ្មែរក្រហមចូលស្រុក គាត់ភ្លេចហ្នុង ភ្លេចគាត់អ្នកធ្លាប់បួសពីដើម។ ហ្នឹងពីរនាក់ហ្នឹង ហើយគេឲ្យធ្វើសុទ្ធមេឃុំ តាយ៉ង និង តាសំអ៊ាត។

[១៣:៤០:៥៧]

**ស៖** តើលោកដឹងថា មានរឿងអ្វីកើតឡើងចំពោះព្រះសង្ឃផ្សេងទៀតទេ នៅក្នុងវត្តជាមួយលោកហ្នឹង? ក្រោយមកទៀតហ្នឹង លោកមានបានធ្លាប់ជួបពួកគាត់ទេ?

**ឆ៖** បាទ ដល់ពេលសឹកហើយ គឺបែកជួរគ្នាទៅ។ ខ្លះទៅភូមិនេះ ខ្លះទៅភូមិនោះទៅ។ ទៅរស់រានតាមភូមិគ្រប់កន្លែងអស់ទៅ អត់មានសកម្មភាពកើតឡើងទេ សឹកក្រោយ។ អត់មានសកម្មភាពថាមានទំនាស់ទាស់ទែងជាមួយព្រះសង្ឃនានាដែលបានផ្សឹក អត់ដែលមានទេ។ ផ្សឹកទាំងអស់គ្នា គឺបែកគ្នាខ្លះទៅផ្ទះគេ ភូមិនេះភូមិនោះទៅ គ្រប់គ្នាទៅ។ តែខ្ញុំមកកន្លែងផ្ទះខ្ញុំទៅ ចប់គ្នាត្រឹមហ្នឹង គ្មានអ្វីគួរឲ្យទាស់ទែងគ្នាទេ ពេលសឹកហើយ ចប់ត្រឹមហ្នឹងហ្នុង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកសាក្សី។ ខ្ញុំអស់សំណួរហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ យើង ដូចដែលខ្ញុំបានបញ្ជាក់ពីព្រឹកមិញអ៊ីចឹង គឺយើងមិនដឹងថាហេតុអ្វីបានជាយើងកោះហៅសាក្សីម្នាក់នេះ<នៅក្នុងវគ្គនេះទេ។ ដូច្នេះ យើងពុំមានសំណួរនោះទេ>។

**ប្រធានអង្គជំនុំ៖**

បាទ ផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តី ខៀវ សំផន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះ។ សូមជម្រាបសួរលោកសាក្សី។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក គង់ សំអុន៖**

**ស៖** តនឹងសំណួរលោកចៅក្រម ឡាវែន៍ សួរអម្បាញ់មិញនេះ ទាក់ទងនឹងពេលលោកបួស។ លោកថា គេផ្សឹកលោក ប៉ុន្តែឯកសារ E319/23.3.38.1, ERN ជាភាសាខ្មែរ 00977432, ជាភាសាអង់គ្លេស 00983485។ ខ្ញុំសុំដកស្រង់៖ “ម្តាយឪពុកឲ្យសឹកមកវិញ ដើម្បីចូលរួមប្រទេសធ្វើបដិវត្តន៍រំដោះប្រទេសជាតិមាតុភូមិ។” អានេះជាសម្រង់ដែលដកចេញពីប្រវត្តិរូបផ្ទាល់របស់រូបលោក។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់ថា តើវាមានភាពខុសគ្នានេះយ៉ាងម៉េចដែរ? លោកអាចបញ្ជាក់បានទេ?

[១៣:៤៣:៤៨]

2-TCW-913៖

**ឆ៖** បាទ លោកប្រធាន ខ្ញុំបញ្ជាក់បាន។ ខ្ញុំរៀបរាប់ឲ្យលោកប្រធានជ្រាបស្តាប់បាន។ ពេលនោះបើយើងដាក់ក្នុងប្រវត្តិរូបថា គេផ្សឹក គេអីហ្នឹង យើងសុទ្ធគ្រោះថ្នាក់ទាំងអស់។ ដូច្នេះយើងធ្វើរលូនតាមហ្នឹង កុំដាក់ថាគេផ្សឹកយើង ផ្សឹកអីទេ។ ហ្នឹងពួក ពេលជំនាន់នុ៎ង យើងចេះតែដាក់ព្រាវអត់បានទេក្នុងប្រវត្តិរូប។ យើងដាក់តាមរបៀបរបបយើងធ្វើ កុំឲ្យគេខឹងយើងបាន។ ដូច្នេះខ្ញុំត្រូវភូតថា ឥឡូវខ្ញុំគ្មានពីណាផ្សឹកខ្ញុំទេ ខ្ញុំមកនេះធម្មតា រស់នៅធម្មតា។ ប៉ុន្តែការពិត ខ្ញុំរាយការណ៍ប្រាប់លោកប្រធានត្រង់អ៊ីចឹង។ ហ្នឹងរៀបរាប់ប្រាប់អ៊ីចឹង។ បើយើងដាក់ពាក្យពិបាកៗ យើងក៏អត់បានរស់យូរដែរ។ ចប់ត្រឹមនុ៎ងតែម្តង ថាគេផ្សឹកជាលោក ជាអីហ្នឹង ហើយគេមិនដឹងថានេះទេ ដល់មកធ្វើប្រវត្តិរូប គេមិនដឹងថាយើងហ្នឹងបួសរៀនដែរហ្នឹង។ ដល់ថាផ្សឹកស្អីហ្នឹង វាមានពាក្យធ្ងន់ធ្ងរ។ អ៊ីចឹងទេយើងអត់ដាក់ក្នុងប្រវត្តិរូបម៉ាកហ្នឹងទេ។ ដាក់ចៀសពាក្យថាគេបណ្តេញ គេផ្សឹក គេអីហ្នឹង។ អ៊ីចឹងខ្ញុំជម្រាបលោកប្រធានជាក់ស្តែងអ៊ីចឹងតែម្តង។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងមានន័យថា លោកកុហកគេពេលនោះ?

**ឆ៖** កុហកបានរស់ លោកប្រធាន។ ពេលហ្នឹងបើមិនកុហក អត់បានទេ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងតួនាទីរបស់លោក លោកបានបញ្ជាក់ពីខាងដើម ជាពិសេសព្រឹកមិញលោកថាលោកជាចុងភៅម្នាក់ នៅពេលដែលលោកមកដល់ក-៥។ ខ្ញុំចង់សួរបញ្ជាក់

បន្ថែមថា ក្រៅពីការងារដាំស្ល នៅពេលដែលលោកស្ថិតនៅក្នុងក-៥ហ្នឹង លោកមានធ្វើកិច្ចការអីផ្សេងទៀតទេ?

[១៣:៤៥:២៩]

**ឆ៖** បាទខ្ញុំទៅដល់ក-៥ដំបូង ខ្ញុំគេគ្មានឲ្យយើងធ្វើអីទេ។ គេឲ្យតែចិញ្ចឹមមាន់ ចិញ្ចឹមទា ចិញ្ចឹមជ្រូក ហើយនិងសកអំពៅ ដាំអំពៅ។ តែដល់ក្រោយមក គេដឹងចិត្តយើងរាងប្រឹងបាន ដូចគេថាយើងគេទុកចិត្តយើង បានគេឲ្យមករៀបចំដាំបាយ ដាំសម្លទទួលភ្ញៀវហ្នឹង។ ហើយគ្មានការងារក្រៅពីហ្នឹងទេ ដូចមានតែប៉ុណ្ណឹង។ ឲ្យដាំបាយបម្រើភ្ញៀវ ភ្ញៀវគេមករៀនប៉ុន្មានៗហ្នឹង លើយើងអ្នកគិតគូរ ហើយនិងភ្លក្សបាយ ដូចខ្ញុំឆ្លើយពីព្រឹក លោកប្រធានប៉ុណ្ណឹងតែម្តង ឆ្លើយប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ លោកបញ្ជាក់ពីខាងដើមថាលោកមកនៅក-៥ តែ៣ខែទេ។ ហើយអ៊ីចឹងលោកអាចបែងចែកពេលវេលាដាច់ដោយឡែកពីគ្នាបានទេ ថាពេលវេលាដែលលោកចិញ្ចឹមជ្រូក ដាំអំពៅ ហើយនិងពេលវេលាដែលធ្វើចុងភៅហ្នឹងរយៈពេលពីគ្នាប៉ុន្មានដែរៗ រយៈពេលប៉ុនណាៗដែរក្នុងផ្នែកនីមួយៗ?

**ឆ៖** បាទ ខ្ញុំដូចខ្ញុំជម្រាបប្រាប់អ៊ីចឹង មកដល់ខ្ញុំចិញ្ចឹមទា ចិញ្ចឹមមាន់ ហើយនិងថែរក្សាដូចថាដំណែដំណាំ និងដាំអំពៅហ្នឹងអស់រយៈពេលប្រហែលជាក្រែលខែដែរ ទម្រាំគេទុកចិត្តយើងបានគេឲ្យបម្រើ ឲ្យដាំបាយហ្នឹង ខ្ញុំរៀបរាប់ប្រាប់លោកគ្រូអ៊ីចឹងហ្នូង មិនមែនមកដល់ថាគេឲ្យធ្វើភ្លាមទេ ការងារអ្វីគេដឹងថា គេទុកចិត្តយើង ថាយើងអាចថាបម្រើបានត្រឹមត្រូវ បានគេឲ្យទៅធ្វើ។ អ៊ីចឹងទេមកដំបូងគេឲ្យយើងនៅរៀបចំបោសផ្ទះសម្បែង--

**ស៖** បាទ សូមកាត់លោក។ ខ្ញុំចង់បញ្ជាក់ពីពេលវេលាថាតើលោក ពេលដែលលោកនៅចិញ្ចឹមជ្រូក ចិញ្ចឹមមាន់ ចិញ្ចឹមទាហ្នឹង ជាការងារនៅក្នុងក-៥ហ្នឹងដែរ ឬក៏ការងារផ្សេងទេ?

[១៣:៤៧:៣៤]

**ឆ៖** បាទ នៅក្នុងក-៥ដដែល នៅក្នុងបុរីកីឡាដដែល គេឲ្យៗចិញ្ចឹមតាំងវា--

**ស៖** បាទៗសូមអរគុណ។ លោកអាចបញ្ជាក់ពេលច្បាស់លាស់បានទេ ថាលោកទៅចិញ្ចឹមជ្រូកហ្នឹងរយៈពេលប៉ុន្មានខែ ទៅដាំអំពៅរយៈពេលប៉ុន្មាន ហើយទៅធ្វើចុងភៅរយៈពេលប៉ុន្មាន? លោកអាចបញ្ជាក់ការងារមួយៗដាច់ដោយឡែកពីគ្នាបានទេ ឬក៏ការងារហ្នឹងធ្វើក្នុងពេលតែមួយទាំងអស់តែម្តង?

**ឆ៖** បាទ ខ្ញុំធ្វើការងារហ្នឹងចែកពេលវា គឺថាការងារបន្ទាប់បន្សំ ឆ្លៀតម៉ោងពេល បើថាឥឡូវដាំអំពៅ ឬមួយឲ្យចំណីសត្វអ៊ីចឹងឆ្លៀតពេលការងារបន្ទាប់បន្សំ គេថាការងារបន្ទាប់បន្សំ។ ហើយបើការងារដាំបាយដាំទឹក អាហ្នឹងវាមូលហេតុធំចម្បង។ ដូច្នេះទេអាហ្នឹងការងារបន្ទាប់បន្សំ ប៉ុន្តែនៅតែក្នុងបុរីកីឡាដដែល។

**ស៖** បាទ អ៊ីចឹងមានន័យថា ការងារទាំងអស់ហ្នឹងគឺលោកធ្វើក្នុងពេលតែមួយទៅជាមួយគ្នា អត់មានការបែងចែកពេលវេលាខុសគ្នាទេ វាអាចខុសគ្នាក្នុងថ្ងៃណាមួយអ៊ីចឹងទៅ ប៉ុន្តែគិតជាខែ គិតអីគឺអាចធ្វើស្របគ្នា។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ស្របគ្នាធ្វើ បាទស្របគ្នាជាមួយគ្នា។ គ្រាន់ចែកពេលវេលា។

**ស៖** បាទ អរគុណ។ ទាក់ទងទៅនឹងការងារចុងភៅ លោកបានបញ្ជាក់ថាអ្នកដាំបាយផ្សេង ហើយមានអ្នកខាងលើកម្ហូបនោះផ្សេង អ្នករកបន្លែ ឬក៏សាច់ត្រីអីហ្នឹងផ្សេង។ លោកអាចបញ្ជាក់ថាក្រុមនីមួយៗហ្នឹងមានមេក្រុមទទួលខុសត្រូវដោយឡែកពីគ្នា ឬមួយក៏ឋិតនៅក្រោមការគ្រប់គ្រងរួមរបស់ តាចំរើន ហ្នឹងតែម្នាក់ទេ?

[១៣:៤៩:៣៨]

**ឆ៖** បាទ ខុសគ្នាតាមផ្នែកៗរបស់គេ អ្នកដាំបាយផ្សេង អ្នកបម្រើ អ្នករៀបផ្សេង។

**ស៖** បាទ អរគុណ។ លោកអាចបញ្ជាក់ឈ្មោះអ្នកជាមេក្រុមនីមួយៗហ្នឹងបានទេ?

**ឆ៖** បាទ ខ្ញុំនៅចាំតែម្នាក់ឈ្មោះ ម៉ន នៅចាំតែម្នាក់ទេ ក្រៅពីនោះ ខ្ញុំអត់ចាំ ខ្ញុំភ្លេចអស់រលីង--

**ស៖** អាហ្នឹងក្រុម ក្រុមៗអីដែរ លោកអាចបញ្ជាក់បានទេ ម៉ន ហ្នឹង?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**2-TCW-913៖**

**ឆ៖** ដឹកត្រី ដឹកបន្លែ ដឹកម្ហូបម្ហាទាំងអស់លើខ្ញុំចំណាំ ឈ្មោះ ម៉ន ម្នាក់ទេ ក្រៅពីនោះខ្ញុំភ្លេចអស់ហើយ មិនសូវចាំគេដែរ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** គាត់អ្នកដឹក ឬមួយក៏ជាមេក្រុមខាងដឹក?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**2-TCW-913៖**

**ឆ៖** គាត់ដាក់ដឹក គាត់ជាតែកុងឡានអ្នកដឹក ដូចគេថាភស្តុភារ។ ដឹកតាំងពីស្បៀងអាហារគ្រប់បែបយ៉ាង គេតែប្រាប់ទៅ គាត់ទៅដឹកហើយ--

[១៣:៥០:៥២]

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ អរគុណ។

**ឆ៖** --ដើម្បីផ្គត់ផ្គង់ក្នុង--

**ស៖** លោកបញ្ជាក់ពីឈ្មោះ តាចំរើន ថាជាមេផ្ទាល់របស់លោក លោកស្គាល់មេរបស់ តាចំរើន ហ្នឹងទៀតទេ?

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ ខ្ញុំអត់ស្គាល់ទេ។ អត់មានសួរដេញដោលថាគេជាមេណាទេ ប៉ុន្តែគ្រាន់តែដឹងថា នៅក្នុងអង្គភាពហ្នឹង មានតែ តាចំរើន ទេអ្នកគ្រប់គ្រងក្នុងបរិវេណបុរីកីឡា។

**ស៖** បាទ សូមអរគុណ។ លោកដឹងការងារប្រចាំថ្ងៃរបស់គាត់ធ្វើអីខ្លះទេ តាចំរើន ហ្នឹង?

**ឆ៖** បាទ គាត់គ្រប់គ្រងនៅបរិវេណបុរីកីឡាហ្នឹង គាត់គ្រប់គ្រងតាំងពីពួកខ្ញុំ តាំងពីកម្មករទាំងអស់ដែលនៅនុ៎ង គាត់នៅមើលការខុសត្រូវនុ៎ង។ ហ្នឹង តាចំរើន គាត់នៅត្រួតត្រានឹងបុរីកីឡាហ្នឹង គាត់នៅក្តោបក្តាប់ពួកខ្ញុំ ពួកអ្នកទាំងឡាយទាំងពួងទាំងអស់នៅនុ៎ង គាត់គ្រប់គ្រងទាំងអស់មួយនុ៎ង គេហៅប្រធានមន្ទីរបុរីកីឡានោះ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងពេលដែលលោករៀបម្ហូប លោកបានបញ្ជាក់អំពីខាងដើមពីរឿងភ្លក្សម្ហូបអីនេះ លោកអាចបញ្ជាក់បានទេថា នៅពេលដែលលោកដាំស្លរួច លោករៀបដួសដាក់ចានដើរឲ្យគេហើយ បានលោកភ្លក្ស ឬមួយក៏លោកធ្វើយ៉ាងម៉េច លោកអាចបញ្ជាក់បានទេ?

[១៣:៥២:៤៦]

**ឆ៖** បាទ ពេលខ្ញុំដាំបាយហើយអស់ ឆ្អិនរួចស្រេច តាំងពីម្ហូបអាហារ សម្លស្អីហ្នឹង បានគេឲ្យដើរភ្លក្សសិន បានគេដើរដួសពីក្រោយ។ ដំបូងគេឲ្យយើងភ្លក្សសិន ភ្លក្សក្នុងឆ្នាំង ឆ្នាំងសម្ល ឆ្នាំងបាយរួចបានគេឲ្យ គេមកដួសរៀបក្នុងតុឲ្យគេហូប។

**ស៖** បាទ សូមអរគុណ។ លោកមានឆ្លើយប្រាប់ទៅគេវិញពីរស់ជាតិម្ហូបដែលបានភ្លក្សនោះទេ?

**ឆ៖** ការពិតគេអត់ដែលសួរដេញដោលទេ។ គេមកគិតតែគេហូបទៅ ហូបគ្រឹបៗទៅ គេអត់មានសួរដេញថា រស់ជាតិឆ្ងាញ់មិនឆ្ងាញ់ គេអត់ដែលសួរយើងទេ។

**ស៖** ខ្ញុំនិយាយពីលោកផ្ទាល់ខ្លួនឯងដែលភ្លក្សម្ហូបហ្នឹង លោកមានដែលប្រាប់ទៅ តាចំរើន ឬក៏អ្នកណាដែលជាអ្នកទទួលបន្ទុកទៅលើម្ហូបហ្នឹង ពីរស់ជាតិម្ហូបហ្នឹង ទៅគេវិញទេ?

**ឆ៖** បាទ គេមិនដែលសួរខ្ញុំ ខ្ញុំក៏មិនដែលប្រាប់គេដែរ។ គេគ្រាន់ថា ឲ្យយើងយកចិត្តទុកដាក់ចំពោះភ្ញៀវ ធ្វើម៉េចឲ្យបានសមរម្យ សមគួរឲ្យគេហូប ប៉ុន្តែខ្ញុំមិនដែលរាយការណ៍ទៅប្រាប់គេ គេក៏មិនដែលសួរខ្ញុំដែរ។ អ៊ីចឹងបានថា ពេលនោះគេទទួលខុសត្រូវ គេឲ្យយើងទទួលខុសត្រូវហើយ បើថាឆ្ងាញ់មិនឆ្ងាញ់ ក៏វាលើយើងទាំងអស់។ ប៉ុន្តែគេមុននឹងដួសយកមករៀបចំ គេភ្លក្សសិន ឲ្យខ្ញុំភ្លក្សសិន។ តាំងពីសម្លបាយ ម្ហូបអាហារគ្រប់មុខ គេឲ្យខ្ញុំភ្លក្សសិន បានគេដួសយកមករៀបចំបម្រើភ្ញៀវ។

**ស៖** បាទ សូមអគុណ--

[១៣:៥៤:៣០]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សុំទោសៗ នេះមិនមែននិយាយអំពីការតេស្តម្ហូបអាហារ <ប៉ុន្តែគឺជា>ការដាក់ថ្នាំពុល<ឬ>? ខ្ញុំស្តាប់អត់ទាន់ច្បាស់។ តើលោកចង់និយាយពីការភ្លក្សអាហារ ឬក៏និយាយពីការដាក់ថ្នាំពុល?

**លោក គង់ សំអុន៖**

មិនមានព័ត៌មានពីការដាក់ថ្នាំពុលទេ គឺនិយាយពីការភ្លក្សម្ហូបអាហារ ក្រែងលោបង្ការមានថ្នាំពុល។ ដូច្នេះវាខុសគ្នាអ៊ីចឹង បានខ្ញុំចង់សួរបញ្ជាក់ពីបញ្ហានេះ។ ហើយខ្ញុំគិតថា សំណួររបស់ខ្ញុំច្បាស់លាស់ហើយចំណុចនេះ។ បើចង់ឲ្យខ្ញុំសួរបញ្ជាក់ចំណុចណាទៀត អាចអញ្ជើញមានប្រសាសន៍បាទ។

បាទ អរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោកសាក្សី ខ្ញុំសួរបន្តទៀត លោកអាចបញ្ជាក់បានទេ រយៈពេលពីលោកភ្លក្ស លោកដើរភ្លក្សគ្រប់ហើយ ហើយពេលដែលគេដួសហ្នឹង រយៈពេលប៉ុន្មានដែរ ខុសគ្នាប៉ុន្មាន? ប៉ុន្មាននាទី?

**2-TCW-913៖**

**ឆ៖** បាទ ខ្ញុំឆ្លើយ ឲ្យតែយើងបានដាំផ្អិនរួចសព្វគ្រប់ហើយហ្នឹង យើងភ្លក្សហើយ គឺគេនៅអែបនុំង គេដឹងយើងភ្លក្សហើយ គេដួសហើយ គេយកទៅបម្រើហើយ យកទៅដាក់ក្នុងខ្ទះបាយហើយ ឲ្យភ្ញៀវហូប។ ដូច្នេះទេ អត់មានយូរទេ គ្រាន់តែយើងផ្អិនហើយ យើងភ្លក្ស ភ្លក្សហើយគេដួសចាត់ចែងតាមដំណើរការរបស់គេតែម្តង។

[១៣:៥៦:១៧]

**ស៖** លោកអាចបញ្ជាក់មុខម្ហូបដែលលោកភ្លក្សហ្នឹង មានម្ហូបស្អីខ្លះទេ?

**ឆ៖** បាទ ម្ហូបៗពិសេស ម្ហូបច្រើនតែសម្លស្ងោក្តោប ហើយត្រសក់លាយសាច់ជ្រូក សាច់ត្រីគ្មានខុសពីហ្នឹងទេ តែស្ងោក្តោប ត្រកួន។ ថ្ងៃណេះត្រកួនទៅ ថ្ងៃណោះស្ងោក្តោប ហើយស្លលាយត្រីទៅ។ ត្រីអង្កាល់នុំង មិនដឹងគេដឹកមកពីខាងណា ដូចខ្ញុំថាហ្នឹង ពេលនេះគេដឹកមកហើយ ត្រី សាច់អី ម្ហូបម្ហាសាច់ជ្រូកអីគេដឹកមក មិនដឹកពីកន្លែងណា អត់នៅធ្វើកន្លែងហ្នឹងទេ។ អ្វីដែលខ្ញុំឃើញ គឺច្បាស់ គឺត្រឹមមក អត់មានដែលឃើញធ្វើកន្លែងហ្នឹងទេ សាច់គោ សាច់ជ្រូកអី អត់មានទេ អត់មានធ្វើកន្លែងនុំងទេ។ ធ្វើ មិនដឹងគេធ្វើពីកន្លែងណា គេដឹកមកហ្នឹង ដើម្បីដឹកឲ្យយើងស្លដាំហ្នឹង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរបញ្ជាក់លោកមួយសំណួរទៀតទាក់ទងចំណុចនេះ ពេលដែលលោកភ្លក្សម្ហូបទាំងអស់នុំង លោកមានការភ័យខ្លាចអីទេ?

**ឆ៖** បាទ ខ្ញុំពេលភ្លក្សម្តងៗ ខ្ញុំភ័យខ្លាចព្រឺខ្លួនដែរ។ ព្រឺខ្លួនត្រង់ថា គេប្រុងសម្លាប់យើងមិនដឹងបានគេឲ្យភ្លក្ស ឬមួយយ៉ាងម៉េច? គេឲ្យភ្លក្សហើយ បើយើងមិនភ្លក្ស ក៏នៅគង់តែគ្មានអនាគតទៅមុខគ្មានន៎ៃនេះទេ គឺសំខាន់ គឺគេឲ្យភ្លក្ស។ បើមុននឹងងាប់ភ្ញៀវ ឲ្យងាប់យើងមុន។ អ៊ីចឹងខ្ញុំភ័យបារម្ភ ភ័យព្រួយខ្លាំងតែម្តងពេលនុំង ប៉ុន្តែចេះតែធ្វើតាមដំណើរការគេឲ្យភ្លក្សទៅ។

**ស៖** បាទ សូមអរគុណ។ ម៉េចបានលោកភ័យខ្លាចត្រូវគេសម្លាប់លោក ដោយសារការភ្លក្សនេះទៅវិញ?

[១៣:៥៨:១៥]

**ឆ៖** បាទ ខ្ញុំភ័យខ្លាចដោយសារថា យើងមើលមិនឃើញ យើងមិនដឹង ក្រែងមានអ្នកណាមួយគេបំពុលហើយ គេធ្វើបាបយើង គេធ្វើឲ្យយើងស្លាប់ គេវៃយើងចោល ម្ល៉ោះហើយភ័យព្រួយបារម្ភជានិច្ចជាកាល គ្មានពេលទំនេរដែរ។ ភ័យ ចេះតែភ័យព្រួយភ័យ ភ័យព្រួយ ខ្លាចគេៗចង់សម្លាប់យើង គេធ្វើឲ្យយើងងាប់ ឲ្យយើងភ្លក្សទៅងាប់។ អ៊ីចឹងទេ ខ្ញុំភ័យរហូត ប៉ុន្តែចេះតែភ័យៗទៅ ចេះតែរួចខ្លួនទៅ។

**សៈ** បាទ សូមអរគុណ។ អ៊ីចឹងបានន័យថា តាំងពីលោកភ្លក្សម្ហូបហ្នឹង នៅធ្វើការនៅ ក-៥ ហ្នឹងរហូតដល់ចប់ការងារ មិនដែលមានករណីណាមួយទាក់ទងនឹងម្ហូបពុលទេ អ៊ីចឹងមែនទេ?

**ឆៈ** បាទ អត់ដែលមានម្ហូបអីពុលដល់ភ្ញៀវទេ ទទេ អត់មានពុល អត់មានប៉ះពាល់ទេ។

**សៈ** បាទ ទាក់ទងនឹងម្ហូបអាហារ លោកឆ្លើយពីព្រឹកមិញម្ដងហើយ តែដូចជាមិនសូវច្បាស់ ខ្ញុំចង់សួរបញ្ជាក់បន្ថែម ទាក់ទងលោកនិយាយថា នៅពេលដែលលោករៀបអាហារឲ្យទៅអ្នកដែលមករៀននោះរួចហើយ ក្រុមលោកបានហូបបាយក្រោយគេ។ ខ្ញុំចង់សួរលោកបញ្ជាក់ថា តើការហូបបាយក្រោយគេរបស់ក្រុមលោក ក្រុមចុងភៅហ្នឹង បាយដែលគេញ៉ាំសល់ ឬក៏មានចំណែកដែលលោកដួសទុកស្រួលបួល ហើយបានលោកទទួលទានអាហារទាំងអស់នោះ?

**ឆៈ** បាទ ហូបបាយដដែលភ្ញៀវហ្នឹង ក្រោយភ្ញៀវហ្នឹង គឺបាយយើងដួសពីឆ្នាំងអត់អស់ នៅទាំងសម្ល ទាំងបាយ។ ដូច្នេះដដែលគេ យើងអត់ដែលហូបទេ។ សម្រាប់យកឲ្យជ្រូក បាយសល់ពីនុំងប្រមូលយកឲ្យជ្រូកស៊ី។ តែបាយយើងនៅសល់ក្នុងឆ្នាំង ក្នុងឆ្នាំងសម្ល ឆ្នាំបាយ គឺយើងបបួលគ្នាហូបទៅ។ ហ្នឹងអ្នកចុងភៅហ្នឹង ហូបក្រោយគេហ្នឹង។ តែបាយវានៅមិនដដែលគេទេ។ បាយដដែលគេគឺសម្រាប់ទុកឲ្យជ្រូក។

[១៤:០០:៣៧]

**សៈ** បាទសូមអរគុណ។ ទាក់ទងទៅនឹងចំណុចនេះដែរគឺឯកសារ E319/23.3.39 ជាសក្ខីកម្មរបស់ត្រង់ចម្លើយលេខ២៦ លោកបានបញ្ជាក់ថា សុំដកស្រង់៖ "នៅបុរីកីឡា គឺលក្ខខណ្ឌការងារ និងម្ហូបអាហារធម្មតា។" សូមចប់ការដកស្រង់។ ខ្ញុំចង់សួរលោកបញ្ជាក់ថា តើលោកនៅគាំទ្រចំណុចនេះដែរទេ?

**ឆៈ** បាទ ឆ្លើយ -- ស្ដាប់អត់ទាន់អំមិញ។

**សៈ** បាទ អរគុណ។ ខ្ញុំបញ្ជាក់ជូន លោកបានឆ្លើយនៅក្នុងសក្ខីកម្មរបស់លោក ដែលឯកសារខ្ញុំអានអម្បាញ់មិញនេះថា លក្ខខណ្ឌការងារ និងម្ហូបអាហារនៅបុរិកីឡា ជាកន្លែងដែលលោកធ្វើការហ្នឹងគឺធម្មតាទេ។ ហើយខ្ញុំសួរថា តើលោកគាំទ្រថា លក្ខខណ្ឌការងារ និងម្ហូបអាហារធម្មតាអ៊ីចឹង ជាការត្រឹមត្រូវដែរឬទេ? លោកអាចបញ្ជាក់បានទេ?

**ឆៈ** បាទ បញ្ហាបម្រើភ្ញៀវ និងការងារខ្ញុំរស់នៅនុំង ខ្ញុំអត់បាច់ -- អត់បានគាំទ្រទេ។ ដូច្នេះទេខ្ញុំអត់មានជឿជាក់ទៅលើពួកវាទេ ប៉ុន្តែចេះតែគាំទ្រ រស់នៅ ចេះតែនៅទៅ--

**ស៖** លោកសាក្សី លោកស្តាប់សំណួរខ្ញុំឱ្យបាន។ នេះជាសម្តីរបស់លោក ដែលលោកនិយាយថា លក្ខខណ្ឌការងារ ហើយនិងម្ហូបអាហារនៅបុរីកីឡាជាធម្មតា។ បានន័យថា មិនមានអ្វីលំបាកលំបិនសម្រាប់លោកទេ។ តើលោកនូវប្រកាន់ជំហរអ៊ីចឹងទេ?

**ឆ៖** បាទ ខ្ញុំនៅប្រកាន់ជំហរប៉ុណ្ណឹង ដាក់ស្តែងប៉ុណ្ណឹង។ គ្មានអីឱ្យខុសពីហ្នឹងទេ ខ្ញុំនៅប្រកាន់ជំហរ។

[១៤:០២:៤៤]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះអរគុណលោកសក្សី។ សវនាការស្តាប់សក្ខីកម្មរបស់លោក ក្នុងឋានៈជាសាក្សីរហូតដល់ពេលនេះ បានដល់ទីបញ្ចប់ហើយ។ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ឥឡូវនេះលោកអាចវិលត្រឡប់ទៅកាន់លំនៅឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្តីសុខសេចក្តីចម្រើន។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនសាក្សីរូបនេះ វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ លោកសាក្សី អាចចាកចេញទៅបានហើយ។

*(សាក្សីចាកចេញពីបន្ទប់សវនាការ)*

បាទ ជាបន្តទៅទៀតនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-235។ មុននឹងចាប់ផ្តើមសក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ អង្គជំនុំជម្រះកត់សម្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ត្រូវបានស្តាប់ចម្លើយនៅក្នុងកិច្ចស៊ើបអង្កេតដែលកំពុងដំណើរការនៅក្នុងសំណុំរឿងផ្សេង។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកំណត់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះស្ថិតនៅក្នុងក្រុម “ក” នៃក្រុមទាំងបីប្រភេទនៅក្នុងអនុស្សរណៈរបស់ខ្លួន (ឯកសារ E319/35) ហើយបានស្នើថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះគួរប្រើរហស្សនាម ក្នុងគោលបំណងការពារនូវភាពសម្ងាត់នៃកិច្ចដំណើរការស៊ើបអង្កេត។

អង្គជំនុំជម្រះយល់ឃើញថា វិធានការមានកម្រិតបែបនេះ គឺត្រឹមត្រូវ សមស្របតាមករណីជាក់លាក់បែបនេះ។ ហើយការបង្គាប់នេះគឺត្រូវធ្វើឲ្យតុល្យភាពគ្នារវាងតម្រូវការនៃសាធារណភាពនៃការសវនាការជាមួយនឹងភាព ការការពារសុចរិតភាពការងារស៊ើបអង្កេត។ ហើយអង្គជំនុំជម្រះសូមរំឭកភាគីសូមឲ្យគោរពតាមសេចក្ដីណែនាំចុះនៅក្នុងឯកសារ E319/7 ក្នុងការប្រើប្រាស់ឯកសារដាក់បង្ហាញនៅក្នុងសំណុំរឿង ពីសំណុំរឿងផ្សេង។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-235 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១៤:០៧:០៨]

បាទ អង្គជំនុំជម្រះជូនភាគី និងសាធារណជនថា អង្គជំនុំជម្រះស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ គឺពាក់ព័ន្ធនឹងអង្គហេតុតួនាទីរបស់ជនជាប់ចោទ។

សួស្ដី លោកដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ តាមសំណើសុំរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ យើងនិងប្រើប្រាស់តែរហស្សនាមលោកតែប៉ុណ្ណោះ ហើយលោកដើមបណ្ដឹងរដ្ឋប្បវេណីមានរហស្សនាម 2-TCCP-235 ហើយជាទូទៅ និងតាមធម្មតាភាគី ទាំងអង្គជំនុំជម្រះផង គឺប្រើប្រាស់ហៅលោកតែក្នុងនាមលោកដើមបណ្ដឹងរដ្ឋប្បវេណីប៉ុណ្ណោះ។ អ៊ីចឹងសូមលោកយល់ថា អង្គជំនុំជម្រះនឹងមិនអនុញ្ញាតឲ្យភាគីពាក់ព័ន្ធរួមទាំងចៅក្រមនៃអង្គជំនុំជម្រះខ្លួនឯងប្រើនូវនាមត្រកូល និងនាមខ្លួនរបស់លោកជាសាធារណៈនៅក្នុងសវនាការនេះទេ។

ហើយមន្ត្រីរដ្ឋបាលតុលាការយកឯកសារ E3/9771 ទៅជូនដើមបណ្ដឹងរដ្ឋប្បវេណីពិនិត្យ។

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធានខ្ញុំសូមលើកដោយសង្ខេប។ ខ្ញុំគិតថាប្រហែលជាមានបញ្ហាបកប្រែក៏មិនដឹង ប៉ុន្តែខ្ញុំស្ដាប់ឮជាភាសាអង់គ្លេសថាលោកប្រធាន និយាយថាដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ និងថ្លែងសក្ខីកម្មអំពីចរិតលក្ខណៈរបស់ជនជាប់ចោទ។ <តើនេះគឺជាអ្វីដែលនិយាយជាភាសាខ្មែរ ឬថាតើវា> និយាយអំពីតួនាទី<>របស់ជនជាប់ចោទ? <នេះគឺជារឿងខុសគ្នា។>

**ប្រធានអង្គជំនុំ៖**

បាទ ខ្ញុំទំនងជាមិនខុសទេ ព្រោះខ្ញុំអានអក្សរ ប្រហែលជាខ្ញុំនិយាយច្បាស់ណាស់ខ្មែរ គឺតួនាទីរបស់ជនជាប់ចោទ។ ខ្ញុំព្យាយាមព្រាងជាឯកសារជាលាយលក្ខណ៍អក្សរ ក្នុងបំណងជៀសវាងការភ័ន្តច្រឡំដូច្នេះ។

[១៤:០៩:១២]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ដើមបណ្ដឹងរដ្ឋប្បវេណី ហើយតទៅនេះអង្គជំនុំជម្រះសូមឱ្យលោកបញ្ជាក់អំពីអត្តសញ្ញាណរបស់លោក ដែលមាននៅក្នុងឯកសារ E3/9771 មានលេខឯកសារ ERN ជាភាសាខ្មែរ 01043314, ERN ជាភាសាអង់គ្លេស 01055683 និងមិនមានជាភាសាបារាំងទេ។ សូមលោកដើមបណ្ដឹងរដ្ឋប្បវេណីពិនិត្យមើលកន្លែងដែលមាន*ហាយឡាយ*ពណ៌ទឹកក្រូច ថាតើនាមត្រកូល នាមខ្លួនរបស់លោក សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត មុខរបរ ឈ្មោះឪពុក ឈ្មោះម្ដាយ ឈ្មោះប្រពន្ធ និងចំនួនកូនរបស់លោកពិតជាត្រឹមត្រូវដែរឬទេ ការសរសេរហ្នឹង? លោកពិនិត្យមើលមើល៍!

ហើយដើមបណ្ដឹងរដ្ឋប្បវេណីគ្រាន់តែឆ្លើយថា ព័ត៌មានទាំងនេះ ពិតជាត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវត្រង់ចំណុចណាបានហើយ។ ដើមបណ្ដឹងរដ្ឋប្បវេណី មិនបាច់បញ្ជាក់ឱ្យបានច្បាស់លាស់ទេ គ្រាន់តែចំណុចណាត្រឹមត្រូវ ចំណុចណាមិនត្រឹមត្រូវបានហើយ ហើយបើត្រឹមត្រូវ សូមបញ្ជាក់ប្រាប់យើងមើល តើឯកសារដែលលោកមើលនេះ ចំណុចទាំងអស់ដែលមាន*ហាយឡាយ*ពណ៌ទឹកក្រូចហ្នឹង។ តើត្រឹមត្រូវឬទេ សរសេរអីចឹង?

**2-TCCP-235៖**

**ឆ៖** បាទ ត្រឹមត្រូវហើយលោកប្រធាន។

[១៤:១០:៤២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយលោកដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះកោះអញ្ជើញមកផ្ដល់សក្ខីកម្មនៅថ្ងៃនេះ ក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងកិច្ចដំណើរការចំពោះមុខអង្គជំនុំជម្រះ ហេតុដូច្នេះចុងក្រោយបង្អស់នៃការផ្ដល់សក្ខីកម្មរបស់លោក លោកអាចមានសិទ្ធិធ្វើសេចក្ដីថ្លែងរៀបរាប់អំពីស្ថាន-

ភាពទុក្ខសោកវេទនា និងស្ថានភាពអន្តរាយដែលកើតមានឡើងចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។ ហើយការណ៍នេះ អង្គជំនុំជម្រះនឹងរំឭកលោកសាជាថ្មីម្តងទៀតនៅចុងក្រោយបង្អស់នៃការផ្តល់សក្ខីកម្មរបស់លោក។

ហើយក្នុងឋានៈ -- ការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្តី។ សហមេធាវីនាំមុខរួមទាំងសហព្រះរាជអាជ្ញាមានរយៈពេលពីរវគ្គ នៃថ្ងៃសវនាការក្នុងការសួរដេញដោលសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ មេធាវីនាំមុខសូមផ្ទេរសិទ្ធិជូនដល់លោកមេធាវី វ៉ែន ពៅ ដើម្បីសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ ហើយខ្ញុំឆ្លៀតឱកាសនេះ ក៏សូមជម្រាបលោកប្រធានផងដែរថា ដើមបណ្តឹងរដ្ឋប្បវេណីប្រហែលជាត្រូវការទៅបន្ទប់ទឹកញឹកញាប់។ សូមអរគុណលោកប្រធាន។

[១៤:១២:០៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអ៊ីចឹងជាការព័ត៌មានល្អមួយ ដើមបណ្តឹងរដ្ឋប្បវេណី ប្រសិនបើលោកមានថា គិតថា លោកត្រូវការទៅបន្ទប់ទឹក លោកកុំអល់អែកអី លោកអាចជម្រាបមកយើងសុំទៅបន្ទប់ទឹក ហើយយើងនឹងអនុញ្ញាតភ្លាមណ៎ា។

បាទ ហើយអង្គជំនុំជម្រះអនុញ្ញាតតាមការស្នើសុំ។ សូមអញ្ជើញលោកមេធាវី វ៉ែន ពៅ!

**លោក វ៉ែន ពៅ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** ជម្រាបសួរពូដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំក្នុងនាមជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងជាមេធាវីផ្ទាល់របស់ពូ ខ្ញុំមានសំណួរមួយចំនួនដែលត្រូវសួរពូនៅពេលនេះ ដែលពាក់ព័ន្ធទៅនឹងបទ

ពិសោធន៍របស់ពូ ដែលពូបានឆ្លងកាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សំណួរដំបូងរបស់ខ្ញុំដែលសួរពូនៅនេះ ខ្ញុំចង់សួរពូថា តើមុនថ្ងៃ១៧ មេសា ១៩៧៥ តើពូនៅឯណា? ហើយពូធ្វើការអីដែរ?

**2-TCCP-235៖**

**ឆ៖** ខ្ញុំសូមគោរពលោកតុលាការទាំងអស់ និងមេធាវី។ នៅក្នុងរយៈកាលឆ្នាំ១៩៧០ ខ្ញុំបានបួសជាសាមណេរនៅវត្តច្រាប ក្នុងភូមិអូររំចេក ឃុំម្រោម ស្រុកបន្ទាយមាស ខេត្តកំពត។ ហើយបួសនោះ គឺនៅក្នុងវត្តជនបទ តំបន់ប្រទង់ប្រទាញរវាងរបបសាធារណរដ្ឋលន់នល់ ហើយនិងរបបអង្គការបដិវត្តន៍។

[១៤:១៤:១៩]

**ស៖** បាទ សូមអរគុណ។ ពូថា ពូបួស ថាតើពូបួសរហូតដល់ពេលណា? មានហេតុការណ៍អីកើតឡើងចំពោះពូទេ ឬក៏ពូបួសរហូត?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់! ចាំក្បាលមីក្រូហ្វូនឲ្យសញ្ញាភ្លើងក្រហមសិនណ៎ា ដើម្បីឲ្យសំឡេងរបស់លោកចូលទៅប្រព័ន្ធចែកចាយសំឡេង។ ជាពិសេសអ្នកបកប្រែ ទៅអ្នកបកប្រែដើម្បីបកប្រែភាសារបស់លោក ទៅជាភាសាបារាំង និងភាសាអង់គ្លេស ពីរភាសាផ្សេងទៀត។

អញ្ជើញឆ្លើយ!

**2-TCCP-235៖**

**ឆ៖** ដល់ពេលឆ្នាំ១៩៧១ កងឈ្លបរបស់អង្គការបដិវត្តន៍ គេបណ្ដេញឲ្យផ្សឹក រួចគេចាប់បញ្ជូនខ្ញុំឲ្យទៅធ្វើកងទ័ពរបស់អង្គការបដិវត្តន៍។

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** ពូៗអាចបញ្ជាក់បានទេ នៅពេលដែលគេផ្សឹកពូនោះ ថាតើពេលនោះពូមានអាយុប៉ុន្មានឆ្នាំដែរ?

[១៤:១៥:៣៥]

**ឆ៖** ប្រហែលជាអាយុ១៥ឆ្នាំ។

**ស៖** បាទ សូមអរគុណ។ ថាតើពេលគេផ្សឹកពូនៅវត្តហ្នឹង គេផ្សឹកលោកទាំងអស់នៅក្នុងនៅក្នុងវត្តហ្នឹង ឬក៏ផ្សឹក--? តើមានលោកប៉ុន្មានអង្គដែរនៅក្នុងវត្ត ពេលផ្សឹកនោះពូចាំបានទេ?

**ឆ៖** បាទ គេផ្សឹកទាំងអស់ លោកមិនតែវត្តហ្នឹងទេ វត្តណាដែលកងឈ្លបអង្គការបដិវត្តន៍ចូលដល់ គឺថាត្រូវគេផ្សឹកអ៊ីចឹង។

**ស៖** បាទ សូមអរគុណ។ នៅពេលដែលគេផ្សឹកពូហើយ តើគេបញ្ចូលពូទៅក្នុង ឱ្យពូធ្វើកងទ័ពនៅក្នុងកងពល ឬក៏វរសេនាតូច ឬក៏វរសេនាធំណាដែរ ពូចាំបានទេ ពេលនោះពូ?

**ឆ៖** បាទ ចាំបានទាំងអស់ នៅចាំបាន។ កាលនោះគឺគេបញ្ជូនខ្ញុំហ្នឹង គឺទៅនៅចន្លោះផ្លូវជាតិលេខ៤ លេខ៥ សមរភូមិវាយប្រយុទ្ធ ហើយនៅក្នុងកងពលទី១ កងពលធំទី១ វរសេនាធំ១៦ ហើយខ្ញុំរស់នៅក្នុងវរសេនាតូចលេខ១៨០។

**ស៖** បាទ សូមអរគុណ។ ចុះពូអាចបញ្ជាក់បានទេថា កងពលលេខ១ពូហ្នឹងស្ថិតនៅតំបន់ ឬក៏ភូមិភាគណាដែរ នៅពេលនោះ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

[១៤:១៧:២៤]

**2-TCCP-235៖**

**ឆ៖** ពេលនោះគឺបានន័យថា កងពលទី១ហ្នឹង គាត់បង្កើតជាដំបូង ដំបូងបង្អស់នៅក្នុង ខ្ញុំដឹងថាចន្លោះផ្លូវជាតិលេខ៤ លេខ៥ហ្នឹង នៅក្នុងហ្នឹង។ ធ្វើការប្រតិបត្តិការនៅក្នុងផ្លូវជាតិលេខ៤ លេខ៥ ហើយនិងក្រុងភ្នំពេញ តែប៉ុណ្ណឹង។ ប៉ុន្តែមិនដឹងថា កងពាយ័ព្យ និរតីអី អត់ទេ អត់ដឹងទេ គ្រាន់តែដឹងថានៅកងពលទី១ហ្នឹង។

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** បាទ សូមអរគុណ។ តើកងឯកភាពពូឈរជើងនៅផ្លូវជាតិលេខ៤ លេខ៥នោះ ពូអាចបញ្ជាក់បានទេ តើនៅថ្ងៃរំដោះ១៧ មេសា ឆ្នាំ១៩៧៥នុ៎ង ថាតើពូបានចូលរួមប្រយុទ្ធជាមួយនឹងគេវ៉ៃចូលទីក្រុងភ្នំពេញដែរទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

ឆ្លើយ!

**2-TCCP-235៖**

**ឆ៖** នៅចុងឆ្នាំ១៩៧៤ គឺថាអង្គការបានរៀបចំឲ្យមានការហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រ ដើម្បីវាយក្រុងភ្នំពេញផ្តាច់ព្រ័ត្រនៅដើមឆ្នាំ១៩៧៥ហ្នឹង។

[១៤:១៩:00]

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** ចុះពាក់ព័ន្ធនឹងថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ថាពូចូលរួមប្រយុទ្ធនុំងនៅច្រកខាងណាដែរ វ៉ៃចូលទីក្រុងភ្នំពេញនោះពូ?

**ឆ៖** នៅពេលនោះគឺខ្ញុំ មុខសញ្ញារបស់ខ្ញុំ នៅថ្ងៃ១៧ មេសា ហ្នឹងគឺនៅឈរជើងនៅពោធិ៍ចិនតុងហ្នឹងតែម្តង ព្រលានយន្តហោះពោធិ៍ចិនតុង។

**ស៖** សូមអរគុណ។ ពូអាចបញ្ជាក់បានទេ នៅថ្ងៃវ៉ៃចូលទីក្រុងភ្នំពេញហ្នឹង តើពូមានតួនាទីអីនៅក្នុងជួរកងទ័ពក្នុងដែរ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**2-TCCP-235៖**

**ឆ៖** ខ្ញុំគឺជាប្រធានក្រុមពិសេសសម្រាប់ស៊ើបការណ៍នៅក្នុងសមរភូមិ ប្រចាំនៅវរសេនាតូចលេខ១៨០ហ្នឹង។

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** សុំៗអរគុណ។ ពូៗ អាចរៀបរាប់បន្តិចទៀតបានទេ ពាក់ព័ន្ធនឹងថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ថ្ងៃរំដោះនុំង ថាតើពូចូលមកតាមច្រកពោធិ៍ចិនតុងនោះ ពូបានឃើញហេតុការណ៍អីខ្លះ ចំពោះការវាយប្រយុទ្ធគ្នាហ្នឹង? ពូអាចរៀបរាប់បានខ្លះទេ?

[១៤:២០:២៧]

**ឆ៖** ក្នុងពេលដែលចូល វាយលុកចូលរំដោះថ្ងៃ១៧ មេសាហ្នឹងគឺនៅខ្ញុំចូលទៅដល់ពោធិ៍ចិនតុងម៉ោងប្រហែលជាប្រាំមួយកន្លះព្រឹក ម៉ោងប្រាំពីរទៅដល់កន្លែងហ្នឹង។ ហើយពួកទាហាន លន់ នល់ទាហានជើងអាកាសហ្នឹង គាត់រៀបចំមានទាហានស្រីៗ ខាងពីឡុតហ្នឹង គេរៀបចំបាច់ផ្កាដើម្បីទទួល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ពួកមិត្តដែលចូលទៅហ្នឹង។ ហើយបន្ទាប់មក ក៏ម៉ោងប្រហែលជាប្រាំបួន ទៅប្រាំបួនជាងដប់ បានមេបញ្ជាការកងពលមកដល់គឺដូចជា តាម៉ុក, សៀ ម៉េត ហើយនិង មាស មុត អីហ្នឹងមកដល់។ មកដល់គេក៏ចាប់ផ្តើមបញ្ជា រឿងអ្វីផ្សេងៗទៀតខ្ញុំក៏មិនបានដែរ ពីព្រោះរវល់ទៅទាក់ទងរកបងប្អូននៅកន្លែងនោះ ដើម្បីប្រាប់ទៅពួកគេឲ្យដកខ្លួនចេញពីទីនោះ។

**ស៖** តើពូមានឃើញហេតុការណ៍អីកើតឡើងទេ នៅថ្ងៃនោះ នៅនឹងតារាងយន្តហោះពោធិ៍ចិនតុង ចំពោះទាហាន អតីតទាហាន លន់ នល់ ដែលថាពូថាយកផ្កាមកទទួល ឬក៏យ៉ាងម៉េចនោះ? ពូសង្កេតឃើញយ៉ាងម៉េចដែរ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**2-TCCP-235៖**

**ឆ៖** នៅពេលចូលដល់ពោធិ៍ចិនតុងនៅពេលនោះគឺឃើញថា មាននារីគ្នាយកបាច់ផ្កាមកដើម្បីទទួលការជ័យជម្នះ អបអរសាទរជាមួយកងទ័ពរបស់អង្គការបដិវត្តន៍ហ្នឹង។ ប៉ុន្តែមនុស្សមួយចំនួនក្នុងកងទ័ពហ្នឹង អ្នកខ្លះគឺមានការចិត្តអាក្រក់ខ្លាំងណាស់។ មានការវាយតប់ ឬក៏ទាញផ្កាបោះបោកចោលអីៗអីចឹងទៅ ហើយនិយាយភាសាអាក្រក់ៗ។ តែដោយឡែកខ្ញុំមួយគឺខ្ញុំដឹងថា ខ្ញុំពិបាកនឹងនិយាយណាស់ព្រោះអីពួកមួយចំនួនគឺថា មកដល់ពេលនោះគឺទាហាន លន់ នល់ គេមានស្រា មានអីឲ្យផឹកស៊ីអីចឹងទៅ។ ហើយពួកមិត្តកំពុងអត់អីចឹង វាចូលផឹកហើយ ផឹកសម្រាន្តហើយ ឲ្យទាហាន នល់ នល់ ប៉ុន្មានទាំងអស់អ្នកបើកយន្តហោះ អ្នកស៊ីនៅក្នុងហ្នឹងគឺមកអង្គុយមួយកន្លែង ផ្តុំគ្នា ដើម្បីចាំទទួលអង្គការ។ អាហ្នឹងដំបូងៗ។

[១៤:២៣:៤៦]

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** ចុះពូមានសង្កេតឃើញមានហេតុការណ៍អីកើតទៀតចំពោះទាហាន លន់ នល់ ដែលពូថាមកអង្គុយចាំទទួលអង្គការហ្នឹង គេមានយកទៅណាទេ? ពូមានដឹងទេ?

**ឆ៖** បាទ ដល់ពេល តាម៉ុក, តាម៉េត, តាមុត, អីមកដល់ហ្នឹង គេរៀបចំ។ គេឲ្យរៀបចំឡានអាឡាន ហ្សេ.អឹម.សេ ហ្នឹង ឲ្យឡើងទៅដើម្បីទៅជួបអង្គការ គឺក្នុងទាំងស្រីទាំងប្រុស។ ហើយមួយចំនួនទៅ ខ្ញុំក៏បានប្រាប់ថា កុំឲ្យទៅ ប៉ុន្តែខ្ញុំមិនបាននិយាយអីច្រើនទេ។ ប្រាប់ថាកុំឲ្យទៅ ទៅធ្វើអី កុំជឿ

គេ វាមិនបានទេ ទៅស្លាប់ហើយ។ អ្នកខ្លះក៏ជឿ អ្នកខ្លះក៏គេមិនជឿ គេទៅៗ ព្រោះ និយាយមិនទៅ គឺរថយន្តហ្នឹងបើកឆ្ពោះទៅលិចទៅ បីបួនប្រាំគ្រឿង មនុស្សណែនៗហ្នឹង ពួកអស់ហ្នឹង ទៅឆ្ពោះទៅលិចបាត់ទៅ ខ្ញុំក៏អត់ដឹងថាទៅណាដែរ។

**ស៖** បាទ សូមៗអរគុណ។ មុននេះបន្តិចពូបញ្ជាក់ថា ពូពេលមកដល់ពោធិ៍ចិនតុងហ្នឹងពូព្យាយាមទៅរកបងប្អូនពូ។ តើពូអាចបញ្ជាក់បានទេ ថាបងប្អូនពូជាអ្នកណា? ហើយគាត់ធ្វើការអីនៅក្នុងតារាងយន្តហោះហ្នឹង?

[១៤:២៥:២៨]

**ឆ៖** បាទ ខ្ញុំអរគុណលោកមេធាវីដែលបានរំឭកត្រង់ចំណុចនេះ គឺខ្ញុំគឺមានពាក់ព័ន្ធជាច្រើនបញ្ហាទាហាន លន់ នល់។ ពេលនោះបងបង្កើតរបស់ខ្ញុំម្នាក់ គាត់នៅជាពីឡុត ជាអ្នកបើកឧទ្ធម្ភាគចក្រអេលីកូ គឺឧទ្ធម្ភាគចក្រម្សាំង។ ខ្ញុំក៏ស្វែងរក ៗទៅក៏ជួប មានបងប្អូនគាត់ មានមិត្តភក្តិគាត់នៅពីរបីនាក់នៅហ្នឹង។ ពេលនោះខ្ញុំប្រាប់ថា បងអើយ ដោះខោអាវសម្លៀកបំពាក់យន្តហោះហ្នឹងចេញឱ្យអស់ហើយបើគេសួរថា បងជាក់ស៊ីក្លូជាក់អ៊ីចឹង។ បើឯងចេញពីទីនេះ ខ្ញុំជូនឱ្យរួចផុតពីរបង កន្លែងនេះ។ ហើយបានមិត្តភក្តិគាត់បីនាក់ ពីរនាក់ បីនាក់និងគាត់ហ្នឹង នាំគ្នាចេញទៅក្រៅ ដោះខោអាវ សម្លៀកបំពាក់ឱ្យស្លៀកខោស៊ីវិលធម្មតា ហើយឱ្យទៅ ថាទៅតាមក្រុមគ្រួសារស្រុកកំណើតនៅឯណា ទៅហ្នឹងវិញទៅ ហើយគេសួរថាយើងខ្ញុំជាកម្មករ ជាអីអ៊ីចឹងទៅ។ ហើយប្រាប់គាត់អ៊ីចឹងទៅក៏បាន។ ហើយមួយចំនួនទៀតក៏ខ្ញុំបានប្រាប់ដែរ ប៉ុន្តែដោយគាត់ ពួកគាត់អត់បានជឿ អត់បានជឿក៏ទៅឡើងឡាន ឡើងអីជាមួយគេទៅបាត់ខ្លួនរហូតហ្នឹង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់បន្តសំណួរទៀត ពាក់ព័ន្ធនឹងក្រោយពេលដែលពូ បានន័យថាក្រោយ១៧ មេសា ៧៥ ហ្នឹងពូរស់នៅភ្នំពេញបានដល់ពេលណា? ហើយមានហេតុការណ៍អីទេ ចំពោះកងឯកភាពពូ ឬក៏ចំពោះពូផ្ទាល់?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់! កុំអាលទាន់!

[១៤:២៧:៣៨]

**2-TCCP-235៖**

**ឆ៖** ប្រហែលជាថ្ងៃ៣០ មេសាហ្នឹង ខ្ញុំកងវរសេនាតូចលេខ១៨០របស់ខ្ញុំ ត្រូវអង្គការបញ្ជូនឱ្យ

ទៅក្រុងកំពង់សោម ទៅក្រុងកំពង់សោម។

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** អ៊ីចឹងបានន័យថា ប្រហែលជាខ្ទង់ថ្ងៃ៣០ ខែមេសា ឆ្នាំ១៩៧៥ កងឯកភាពរបស់ពូទាំងមូលហ្នឹងគេបញ្ជូនទៅក្រុងកំពង់សោម?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** តើៗគេបញ្ជូនពូទៅហ្នឹង តើពូនៅកន្លែងក្រុងកំពង់សោមហ្នឹងធ្វើការអី ឬក៏កងឯកភាពពូបន្តជាយោធាដដែល ឬយ៉ាងម៉េចបាទ នៅកំពង់សោម?

**ប្រធានអង្គជំនុំ៖**

សំណួរអំមិញមិនទាន់បានឆ្លើយទេ។ លោកឆ្លើយស្តាប់ខ្លួនឯង ក្បាលមីក្រូហ្វូនអត់បើកផង ភាគីផ្សេងទៀតម៉េចនឹងដឹង លោកសួរអ៊ីចឹងទៅ វាអត់ដឹងថាដល់កំពង់សោមតាមរបៀបណាទេ។ ឆ្លើយសំណួរទី១ សិន។

សួរឡើងវិញ លោកប្រយ័ត្នប្រយែងលោកមេធាវី សួរទៅលោកឮ លោកនៅជិតឮតែម្នាក់ឯងទេ ប្រព័ន្ធផ្សព្វផ្សាយរួមទាំងសាធារណជនអត់ឮចម្លើយផង ដែលលោកសួរសំណួរទី២ទៅ វាមិនដឹងថាទៅដល់កំពង់សោមតាមវិធីណា។

[១៤:២៩:០០]

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** ខ្ញុំសូមសួរពូម្តងទៀត ថាតើក្រោយមក បានន័យគេបញ្ជូនពូទៅកំពង់សោមហ្នឹងនៅពេលណា ពូអាចចាំបានទេ?

**2-TCCP-235៖**

**ឆ៖** ដូចខ្ញុំបញ្ជាក់អ៊ីចឹង ថ្ងៃទីប្រហែលខ្ទង់ខែមេសាហ្នឹង ថ្ងៃ៣០អីហ្នឹង គេបញ្ជូនទៅក្រុងកំពង់សោម តាមរយៈរថយន្ត ហ្សេ.អឹម.សេ តាមរយៈរថយន្ត ហ្សេ.អឹម.សេ ហ្នឹង។

**ស៖** អ៊ីចឹងបានន័យថាកងឯកភាព បានន័យថា កងពល បានន័យថាកងវរសេនាធំ១៨០លោកទាំងមូល ពូទាំងមូលដែលគេបញ្ជូនទៅទីនោះ?

**ឆ៖** បាទ គេបញ្ជូនមួយវរសេនាតូច គ្នាប្រហែលជា៤០០ ទៅ៥០០នាក់។

**ស៖** បាទ សូមអរគុណ។ តើនៅកំពង់សោមនោះ គេផ្តល់តួនាទី ឬការងារពូឲ្យធ្វើអីខ្លះនៅកំពង់

សោមពេលដែលគេបញ្ជូន បានន័យថា កងវរសេនាតូចពូទាំងមូលទៅទីនោះ?

**ឆ៖** នៅពេលដែលគេបញ្ជូនទៅដល់ហើយ កងវរសេនាតូចលេខ១៨០ហ្នឹង គឺបានន័យថា អង្គការហៅទៅ ជារំសាយៗ។ មួយចំនួនដូចជារូបខ្ញុំហ្នឹង ក៏ត្រូវគេបញ្ជូនទៅកងជើងទឹកសមុទ្រ ជើងទឹក។ ឯមួយចំនួនទៀត គឺមិនដឹងទៅណាមកណាទេ។

[១៤:៣០:៤៦]

**ស៖** បាទ សូមអរគុណ។ ពូថាគេបញ្ជូនពូទៅខាងកងជើងទឹកសមុទ្រ ថាតើគេឲ្យពូទៅឈរជើងនៅនឹងកំពង់ផែណាមួយ ឬក៏កោះណាមួយដែរ ឬក៏នៅក្នុងកំពង់សោមហ្នឹងតែម្តង?

**ឆ៖** បាទ ទៅនៅក្នុងជើងទឹក គឺនៅតែក្នុងសមុទ្រតែម្តង នៅលើទូកធំ មានចាប់អាវុធដើម្បីការពារដែនសមុទ្រពីចោរសមុទ្រហ្នឹង លួចអូសត្រី លួចស្អីៗហ្នឹង។ ទាហានរដ្ឋាភិបាលថៃ ទាហានយួនអីហ្នឹង គឺបានប៉ះទង្គិចគ្នាជាបន្តបន្ទាប់អស់រយៈប្រហែលជា ខ្ញុំនៅក្នុងហ្នឹង ប្រហែលជា៥ខែ នៅលើទូកហ្នឹង។

**ស៖** បាទ សូមអរគុណ។ តើមានហេតុការណ៍អីទៀតទេ ក្រោយពេលពូនៅលើ នៅខាងជើងទឹកហ្នឹង នៅកំពង់សោមបាន៥ខែហ្នឹង តើមានហេតុការណ៍អីកើតឡើងដល់ដល់ពូទៀតទេ?

**ឆ៖** នៅក្នុងពេលនោះ គេហៅតាមវិទ្យុទាក់ទងឲ្យខ្ញុំមកប្រជុំ ប្រជុំនៅកោះស្តេច។ ដល់តែពេលខ្ញុំមកដល់ ខ្ញុំមាន វាហៅថានីរសារម្នាក់ ពីរនាក់នឹងខ្ញុំ។ ខ្ញុំមកដល់គេភ្ជង់កាំភ្លើង។ ភ្ជង់ ខ្ញុំរកវើបម្រះនឹងបម្រុងថា អាមេកាំភ្លើងហើយ ប៉ុន្តែដល់ពេលនោះ គឺគ្នាគេច្រើន ខ្ញុំតែពីរនាក់។ អ៊ីចឹងខ្ញុំត្រូវដាក់អាវុធដាក់អាវុធរួច គេយកខ្នោះមកដល់ដាក់ដៃ។ ខ្នោះដាក់ដៃខ្ញុំទាំងពីរ។ ឯអង្គរក្សខ្ញុំ គេដេញចេញហើយអានីរសាររបស់ខ្ញុំ។

**ស៖** អ៊ីចឹងបានន័យថា គេហៅពូមកកោះស្តេច គឺគេចាប់ពូ។ តើពូដឹងថា អ្នកណាអ្នកចាប់ពូ? ហើយក្រោយមកមានហេតុការណ៍អីកើតឡើងចំពោះពូទៀត?

[១៤:៣៣:២៧]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**2-TCCP-235៖**

**ឆ៖** នៅពេលនោះ មិនមែនចាប់តែរូបខ្ញុំទេ ចាប់ចំនួនប្រាំបួននាក់។ យកទៅលើកប៉ាល់ធំមួយ ដូច

ថាកប៉ាល់ធំមានដុំភ្លើងឆក់អ៊ីចឹង គេឆក់ខ្សែភ្លើង ដើម្បីសួរចម្លើយ ចោទប្រកាន់ថា ជាខ្មាំងជាអី បង្កប់។ ហើយក៏ពេលនោះ ខ្ញុំត្រូវគេឆក់ខ្សែភ្លើងក្រោយគេ។ ក្រោយគេ គេសួរទៅខ្ញុំបដិសេធ ខ្ញុំថាអត់ដឹងអីទាំងអស់ រឿងអ្វីខ្ញុំដឹងតែពីការគោរពអង្គការតាំងពីណាពីណីមក ខ្ញុំមិនដែលមានប្រឆាំងជាមួយអង្គការបដិវត្តន៍បានទេ។ ពេលនោះគឺឃើញថា រួចខ្លួនចំនួនបីនាក់ ទាំងរូបខ្ញុំហ្នឹង ហើយនិងប្រាំមួយនាក់ទៀតគឺត្រូវគេបញ្ចូលទៅក្នុងឃ្លុបទូក ឃ្លុបទូកបាត់ទៅ មិនដឹងថាទៅណាទេ។ ហើយរូបខ្ញុំទាំងបីនាក់ គេបញ្ជូនឱ្យទៅធ្វើការងារជាទម្ងន់នៅខេត្តកោះកុង។ នៅទីរួមខេត្តកោះកុង គឺនៅរោងចក្រត្រីខ ហើយក៏ទៅដល់កន្លែងនោះ មិនមែនតែរូបខ្ញុំទេ មានគ្នាច្រើនទៅទៀតដែលត្រូវជាកងទ័ព ប៉ះអ្នកដែលគេត្រូវរំសាយហ្នឹងក៏នៅជាប់នៅទីនុ៎ងដែរ។ គេបង្ខំឱ្យធ្វើការ ធ្វើស្ពាន ធ្វើថ្នល់ ដោយមានកងការពារតំបន់១១ ដែលលេខាតំបន់គេនោះឈ្មោះ រ៉ន ហើយនិង រី (ស្រី) ដែលគេមានកងការពារ គេការពារពួកខ្ញុំហ្នឹង។ ទៅឱ្យខ្ញុំធ្វើការទាំងយប់ទាំងថ្ងៃ ហើយអាហារក៏គេមិនដែលឱ្យហូបគ្រប់គ្រាន់ដែរ។ ហើយក៏ជាបន្តបន្ទាប់ ក៏ដកបាត់ខ្លួនជាបន្តបន្ទាប់។ នៅគ្នាប្រហែលជាសាមសែសិបនាក់ នៅសល់ប្រហែលជា១០នាក់ជាងប៉ុណ្ណោះកាលនោះ។

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** បាទ សូមអរគុណ។ ពូៗ អាចបញ្ជាក់បានទេ ដែលគេបញ្ជូនពូទៅកោះកុងនោះ ថាតើពូទៅធ្វើការនៅទីនោះជាទម្ងន់រយៈពេលប្រហែលប៉ុន្មានខែដែរ នៅកោះកុងនោះ?

[១៤:៣៦:០៨]

**ឆ៖** ជា១២, ១៣ខែ។ ប្រហែលរយៈ១២, ១៣ខែហ្នឹងប៉ុណ្ណឹងឯង។

**ស៖** សុំៗអរគុណ។ ពូៗអាចបញ្ជាក់បានទេ មានហេតុការណ៍កើតឡើងទៀតទេ ក្រោយនៅនឹងកោះកុងរហូត ឬក៏មានហេតុការណ៍អីចំពោះពូទៀត បន្តមកទៀត?

**ឆ៖** នៅពេលនោះមាននីរសារតំបន់១១ហ្នឹង គេមកហៅខ្ញុំ និងពីរនាក់ -- ម្នាក់ទៀត ដែលនៅរស់។ ម្នាក់នោះគឺដោយឈ្មោះ ចាន់ថា នោះគាត់ស្លាប់ហើយ ដោយសារតែគាត់និយាយថា "សម្រាកប្រុង អង្ករបីកំប៉ុងគ្នា៣០នាក់! សម្រុកទៅមិត្ត! សម្រុកទៅមិត្ត!" ត្រង់នេះហើយដែលធ្វើឱ្យលេខាបក្សតំបន់១១ហ្នឹង គេចាប់ខ្លួនជាបន្ទាន់ យកទៅសម្លាប់ចោលនៅសាធារណៈដូចជាឱ្យខ្ញុំឃើញ ជាមិត្តភក្តិខ្ញុំជិតស្និទ្ធខ្ញុំ។ ព្រួយបារម្ភចាប់ពីពេលនោះមក។ ហើយដល់ពេលរួចពីហ្នឹង បន្ទាប់មកនៅពាក់កណ្ដាលឆ្នាំ ១៩៧៧ ស្រាប់តែមាននីរសារតំបន់គេមកដល់ គេហៅឈ្មោះខ្ញុំតែម្តង។ ឈ្មោះខ្ញុំកាលនោះគឺមិនមែនថា

2-TCCP-235 ទេ ដោយខ្ញុំលាក់ប្រវត្តិរូបដាក់ឈ្មោះ 2-TCCP-235 បាទ 2-TCCP-235 វិញ ចូលបដិវត្តន៍គេសួរ “មិត្តសឿន នៅ? ថាបងឲ្យហៅ”។ ខ្ញុំ គេហៅទាំងពីរនាក់ដែលនៅរស់ហ្នឹង។ ហើយគេបញ្ជូនតាមកាណូត តាមកាណូតក្នុងសមុទ្រ សមុទ្រក្នុង គេហៅ “សមុទ្រក្នុង” មកដល់ត្រពាំងរូង។ ត្រពាំងរូង គេក៏ឲ្យខ្ញុំចុះដើរ ៗដោយកងការពារគេ ៗប្រយ័ត្ន។ ហើយខ្ញុំចេះតែក្នុងចិត្តថា ខ្ញុំប្រហែលជាត្រូវស្លាប់នៅពេលនេះហើយ។ ខ្ញុំគេមិនឲ្យជាប់គ្នាទេ។ ខ្ញុំដោយឡែក ម្នាក់នោះវាឲ្យដើរដោយឡែក។ ខ្ញុំគិតហើយ។ មកដល់អណ្ដូងទឹក ធ្វើដំណើរចាប់ពីត្រពាំងរូងហ្នឹងដោយថ្មើរជើងមកដល់អណ្ដូងទឹក កន្លែងតំបន់គេរស់នៅហ្នឹង ក៏គេឲ្យសម្រាក។ សម្រាកជិតវិហារមួយ ហើយអ្នកទោសពេញហ្នឹងទាំងអស់ ជាប់ខ្នោះ ជាប់ជើង ជាប់ដៃ ខ្ញុំថាដល់ហើយខ្ញុំ ម្ដងនេះ។ ខ្ញុំគិតថាប្រហែលជាត្រង់ហ្នឹងហើយ។ ខ្ញុំលបមើលទៅតាមបង្អួច ឃើញតែវិហារលោក វិហារមួយជាប់ខ្នោះទាំងអស់ មនុស្សនៅទីនោះ។ ប៉ុន្តែពេលនោះ នីរសារតំបន់ហ្នឹង គេយកបាយយកអីមកឲ្យហូបធម្មតា។ ខ្ញុំក៏នៅដេកលើសាលាឆាន់លោកហ្នឹង រហូតដល់ព្រឹក ប៉ុណ្ណឹង។ អរគុណ។

[១៤:៤០:០១]

**ស៖** ចុះក្រោយមកទៀត ពេលដល់ព្រឹកឡើង តើគេបញ្ជូនពូទៅណាទៀតដែរ?

**ឆ៖** នៅពេលព្រឹកប្រហែលជាម៉ោងប្រាំពីរ ទៅជិតប្រាំបី មានមីក្រូគេប្រកាសប្រាប់ទៅដល់បងប្អូនយើង គេហៅថា គេប្រកាសថា សមមិត្ត! យុទ្ធមិត្តយើងដែលបក្សឲ្យមកនេះ គឺសូមនាំគ្នាឡើងលើទូកធំ។ ទូក ៗហ្នឹងទូកធំ គេហៅទូកប៉ុកចាយ អាធំៗនោះ។ ដឹកចំណុះប្រហែល ក្នុងមួយទូកហ្នឹងប្រហែលជា១០០នាក់ជាង ២០០នាក់អីហ្នឹង។ បីទូកកាលនោះ ឡើងពេញបីទូក។ ហើយគេក៏មកប្រាប់ខ្ញុំថាឲ្យមិត្តឯងឡើងទូកនឹងគេនឹងឯងទៅ អ៊ីចឹងបាទ។

**ស៖** ថាតើបន្តដំណើរទៅណាទៀត? ឡើងទូកមកណាពូដឹងទេ?

**ឆ៖** បាទ ពេលនោះទូកនោះក៏ឡើងមកដល់ស្រែអំបិល។ ស្រែអំបិល ថ្ងៃរសៀល ដល់ហើយៗក៏មានរថយន្ត ហ្សេ.អឹម.សេ ហើយរថយន្តអាហ្ស៊ីលចិនហ្នឹង មកដឹកយកទៅដាក់នៅវាលរេញណោះ។

**ស៖** តើៗមានមនុស្សច្រើនទេដែលមកជាមួយពូ ថាទៅវាលរេញ មានជួបមនុស្សដទៃទៀតនៅវាលរេញដែរ? ហើយក្រោយមកគេបញ្ជូនពូទៅណាទៀតដែរ?

**ឆ៖** បាទ ដល់ទៅវាលរេញ គឺសម្រាកនៅទីនេះមួយយប់ ម៉ោងប្រហែលជាប្រាំបី ទៅប្រាំបួន ក៏មានឧគ្ឃោសនសព្ទ មីក្រូ ដូចថាប្រកាស មិនខុសអីប្រកាសនៅអណ្ដូងទឹកអីទេ ប្រកាសឲ្យសមមិត្ត ៗ

ហ្នឹងគឺសុទ្ធតែបក្ខជនហើយ គេហៅ “សមមិត្ត” ហ្នឹង យុទ្ធមិត្តធម្មតាហ្នឹង មិនមែនសមមិត្តទេ។ សមមិត្ត យុទ្ធមិត្ត ទាំងអស់ដែលបក្សយើងបានឲ្យមកនេះ សូមនាំគ្នាឡើងរថភ្លើង ឡើងជិះរទេះភ្លើង ឡើងជិះរទេះភ្លើង ឡើងជិះរទេះភ្លើង។ បាទ ប៉ុណ្ណឹង។

**ស៖** ក្រោយមកទៀត តើពូ ក្រុមពួកពូឡើងរទេះភ្លើងហ្នឹងចេញទៅខាងណាវិញ? បើមកៗកន្លែងណាពូចាំទេ?

[១៤:៤៣:០១]

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមការបញ្ជាក់បំភ្លឺពីអង្គជំនុំជម្រះ។ មកទល់ពេលនេះគឺថាមិនមែនសួរតែមួយសំណួរនោះទេ មិនទាន់មានសួរពីតួនាទីរបស់ជនជាប់ចោទមួយសំណួរសោះ ហើយការសួរអំពីការជម្លៀសប្រជាជនជាផ្នែកនៃសំណុំរឿង០០២/០១ ហើយការសួរ<អំពីអ្វីដែលបានកើតឡើង> នៅខេត្តកោះកុងនោះ ក៏ស្ថិតនៅក្រៅវិសាលភាពទៀត។ ហើយមិនដឹងថាហេតុអ្វី ពីព្រោះថា សហមេធាវីនាំមុខហ្នឹងក៏បានចូលរួមជ្រើសរើសសាក្សីរូបនេះ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ដើម្បីមកបញ្ជាក់បំភ្លឺអំពីតួនាទីរបស់ជនជាប់ចោទ។ <ហើយបន្ទាប់មក អង្គជំនុំជម្រះបានជ្រើសរើសសាក្សីរូបនេះ។> អ៊ីចឹងខ្ញុំស្នើសុំថា ការសួរហ្នឹងគឺធ្វើម៉េចឲ្យវាពាក់ព័ន្ធទៅនឹងវិសាលភាពរបស់វា គឺតួនាទីរបស់ជនជាប់ចោទ <នួន ជា និងខៀវ សំផន>។ ហេតុអ្វីក៏កោះហៅបុគ្គលរូបនេះមកផ្ដល់សក្ខីកម្ម? ហើយថាតើតួនាទីរបស់ជនជាប់ចោទនោះ ត្រូវទុកមួយអន្លើសិន ឬក៏យ៉ាងណា លោកប្រធាន?

[១៤:៤៤:២៧]

**លោក គង់ សំអុន៖**

បាទ លោកប្រធាន។ ខ្ញុំសូមគាំទ្រចំពោះការបដិសេធនេះ។ ជាពិសេសយើងមើលឃើញថា លោកប្រធានបានបញ្ជាក់ជាញឹកញាប់ហើយ ហើយជាពិសេសព្រឹកមិញ បានសង្កត់ទៅលើថា បើអង្គហេតុដែលកើតឡើងនៅក្រៅពីវិសាលភាព អាចសួរទាក់ទងទៅនឹងលក្ខណៈជាគោលការណ៍ ជានយោបាយ។ ប៉ុន្តែចម្លើយសំណួរដែលសួរកន្លងមកនេះ គឺសួរទៅលើអង្គហេតុជាក់លាក់ ទៅលើព្រឹត្តិការណ៍

ដែលកើតឡើងជាក់លាក់ ទីតាំងដែលមិនជាប់ពាក់ព័ន្ធនៅក្នុងវិសាលភាព។ ដូច្នេះចំណុចទាំងអស់នេះ វាមិនអាចឆ្លុះបញ្ចាំងនូវគោលនយោបាយទាក់ទងទៅនឹងតួនាទីរបស់ជនជាប់ចោទបានទេ។ ដូច្នេះ វាមិនជាប់ពាក់ព័ន្ធនៅក្នុងសំណុំរឿងនេះ។ បាទ សូមអរគុណ។

**លោក វ៉ែន ពៅ៖**

សូមគោរពលោកប្រធាន។ តាមពិតសំណួរខ្ញុំនឹងចូលដល់បន្តិចទៀតហើយ នឹងពាក់ព័ន្ធនឹងបញ្ហាជាមួយជនជាប់ចោទហើយ លោកប្រធាន តែមួយសំណួរទៀត នឹងដល់ហើយ។

[១៤:៤៥:៣៦]

**ប្រធានអង្គជំនុំ៖**

ប៉ុន្តែយើងអូសវាវាងពេក វាងឆ្ងាយពេក អ្វីដែលជាបន្ទាប់បន្សំ អ្វីដែលជាសំណួរចម្បង។ សំណួរចម្បងក្នុងការតាំងសំណួរដើមបណ្តឹងរដ្ឋប្បវេណី គួរតែសួរដើម្បីរំលេចឱ្យឃើញថា គាត់ទទួលរងព្យសនកម្ម និងអន្តរាយបែបណា។ ការសួរបែបនេះ អង្គជំនុំជម្រះអនុញ្ញាត ទោះបីមិនពាក់ព័ន្ធជាមួយនឹងអង្គហេតុក៏ដោយ ពីព្រោះវិសាលភាពនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី វាមានលក្ខណៈទូលំទូលាយ ហើយផលប្រយោជន៍ដែលបានទទួលជាសមូហភាពទេ ដើម្បីឱ្យគាត់អស់ចិត្តអំពីអ្វីដែលគាត់បានជួបប្រទះ។ ប៉ុន្តែសំខាន់អង្គជំនុំជម្រះបានកំណត់អំពីកាលបរិច្ឆេទនៃការសវនាការស្តាប់សក្ខីកម្មសាក្សីនីមួយៗហ្នឹងជាក់លាក់ទៅតាមអង្គហេតុជាក់លាក់។ អ៊ីចឹងហើយបានអង្គជំនុំជម្រះយើងព្យាយាមរំឭកអំពីការស្តាប់សក្ខីកម្មសាក្សីរូបនេះ នៅក្នុងតួនាទីរបស់ជនជាប់ចោទ។ អ៊ីចឹងការរំលេចឱ្យវាឃើញពាក់ព័ន្ធជាមួយអ្វីដែលជាគោលការណ៍ចម្បងនៅក្នុងការតាំងសំណួរ ជាអង្គហេតុចម្បងដែលត្រូវសួរដេញដោលចំពោះអង្គហេតុផ្សេងទៀត វាជារឿងបន្ទាប់បន្សំ។ បើសិនជាយើងអាចសួរគឺពីរបីសំណួរ ដើម្បីភ្ជាប់ទៅនឹងឱ្យវាកើតហេតុ ពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលមានព្យសនកម្ម ឬផលអន្តរាយចំពោះគាត់។ នេះបានវាសមស្រប ទោះបីយើងបើកទូលាយក៏ដោយ ប៉ុន្តែយើងបានកំណត់ច្បាស់លាស់ណាស់អំពីអង្គហេតុណាធ្វើសវនាការ អង្គហេតុណាមិនធ្វើសវនាការ នៅក្នុងកិច្ចបំបែកកិច្ចដំណើរនីតិវិធី។ ចំពោះគោលនយោបាយហ្នឹង យើងស្តាប់ច្រើនហើយគួរតែបន្ថយទៅ។ ចំណុចណាដែលចាំបាច់ រំលេចបន្តិចបន្តួចប៉ុណ្ណោះ ពីរបីសំណួរវាល្មមហើយ។ ដល់ពេលយើងសួរលម្អិត វាអាចនឹងមានបញ្ហាដូច្នេះឯង។

[១៤:៤៧:២០]

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំសូមធ្វើការកត់សម្គាល់ ពីព្រោះថា ឃើញថាខាងមេធាវីការពារក្ដីគាត់និយាយទៅដូចមិនជាត្រូវនឹងសំណួរដែលសួរទៅដើមបណ្ដឹងរដ្ឋប្បវេណីទេ។ លោកមេធាវី កូប៉េ គាត់និយាយថា សំណួរដែលចោទសួរទៅនឹងការជម្លៀសនោះ មិនត្រឹមត្រូវនោះទេ។ តាមពិតសំណួរហ្នឹងសួរទាក់ទងទៅនឹងការចាប់ទាហានលន់នល់ នៅពោធិ៍ចិនតុងវិញទេ។ អ៊ីចឹងខ្ញុំសូមអរគុណចំពោះការសម្រេចសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ដែលមានសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមួយចំពោះមុខនេះ ដែលគាត់ផ្ដល់ ឥឡូវគាត់កំពុងតែផ្ដល់បរិបទហើយ បន្តិចទៀតគាត់នឹងផ្ដល់តួនាទី ឬមុខងាររបស់ នួន ជា ពាក់ព័ន្ធទៅនឹងក្រាំងតាចាន់ អីជាដើមលោកប្រធាន។ អ៊ីចឹងបន្តិចទៀតហ្នឹងអាចចូលសាច់រឿងហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញ! ប៉ុន្តែគ្រាន់តែវាផ្លូវវាងវាឆ្ងាយពេក អាបន្ទាប់បន្សំហ្នឹង វាច្រើនជាងអាចម្បង។ បើសិនជាយើងសួរ យើងអត់ដឹងថា អ្វីទៅដែលយើងត្រូវគោលដៅដែលត្រូវសួរចម្បង អ្វីទៅបន្ទាប់បន្សំនោះ។ ហើយគេបានកំណត់ច្បាស់លាស់ណាស់អង្គហេតុដែលយកមកធ្វើសវនាការ ស្អីគេដែលជាចម្បងនោះ។ ហើយយើងកំណត់ច្បាស់ហើយ នៅក្នុងការណែនាំជូនដំណឹងជាផ្លូវការ ក៏ដូចជាយើងជូនដំណឹងអំពីមិញបន្ថែមទៀត រំឭកក្នុងគោលដៅ ក្នុងគោលបំណងឲ្យសម្រួចនូវការសួរដេញដោលឲ្យជាប់ពាក់ព័ន្ធនឹងអង្គហេតុដែលកំណត់ធ្វើសវនាការ។

[១៤:៤៨:៤៧]

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** ពូ ខ្ញុំសូមឲ្យពូបញ្ជាក់ឲ្យច្បាស់ទៅ ថាតើក្រោយពេលគេបញ្ជូនពូតាមរថភ្លើងទៅភ្នំពេញនោះ ពូបានទៅស្នាក់នៅឯណា? ហើយពូបានឃើញហេតុការណ៍អីខ្លះ?

**2-TCCP-235៖**

**ឆ៖** បាទ នៅពេលដែលគេបញ្ជូនតាមរថភ្លើងនោះ គឺទៅដល់ក្រុងភ្នំពេញ គឺប្រហែលជាម៉ោងដប់យប់ ប្រហែលពាក់កណ្ដាលយប់។ គេបញ្ជូនខ្ញុំបាទហ្នឹង មនុស្សហ្នឹងប្រហែលជាជិត១.០០០នាក់ទៅបុរីកីឡា ទៅបុរីកីឡា ទៅមានអគារគេឲ្យសម្រាកស្នាក់នៅហ្នឹង។

**ស៖** តើពូទៅដល់បុរីកីឡានោះ នៅស្នាក់នៅប៉ុន្មានថ្ងៃ? ហើយពូបានជួប ឬក៏បានជួបប្រជុំ ឬ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ជួបហេតុការណ៍អីទេ នៅក្នុងអំឡុងពេលពូស្នាក់នៅបុរីកីឡានោះ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**2-TCCP-235៖**

**ឆ៖** បាទ ស្នាក់នៅបុរីកីឡានោះគឺរយៈ២យប់។ មួយយប់ទី១ គឺពាក់កណ្ដាលយប់។ ដល់យប់ទី២ គេបញ្ចាំងខ្សែភាពយន្ត ឯកសារចិនច្បាំងជាមួយជប៉ុនឲ្យមើល ទាល់ចប់។ ហើយនៅវេលាព្រឹកឡើង ថ្ងៃទី៣ គេឲ្យចុះមកហូបបាយ។ ហូបបាយរួច គេឲ្យប្រជុំជួរ។ នៅពេលដែលប្រជុំជួរនោះ គឺមាន តាម៉ុក, សុន សេន, និងលោកមា នួន ជា ផង ដែលគាត់មក ដើម្បីលើកទឹកចិត្តដល់ពួកខ្ញុំហ្នឹង។

[១៤:៥១:១៧]

**ស៖** ពូបញ្ជាក់ថា ពូឃើញ តាម៉ុក, សុន សេន ហើយនិងលោក នួន ជា។ តើម៉េចបានពូដឹងនៅពេលនោះថា គាត់ជា នួន ជា? ពូដឹងដោយរបៀបណា? ឬពូស្គាល់គាត់យ៉ាងម៉េច បានពូដឹងថាគាត់ជា នួន ជា?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំទាលទាន់!

**2-TCCP-235៖**

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំទាលទាន់!

**2-TCCP-235៖**

**ឆ៖** ព្រោះថាខ្ញុំស្គាល់ច្បាស់រូបគាត់ហ្នឹង នួន ជា ហ្នឹង ហើយបើ តាម៉ុក គឺនៅជាប់រហូត។ ហើយ តាម៉ុក ហើយលោកមា នួន ជា ហ្នឹងគាត់នៅជាប់ជាមួយ តាម៉ុក តាំងពីអើយមកហ្នឹង។ ហើយនៅពេលដែលខ្ញុំដឹងច្បាស់ថា លោកមា នួន ជា ហ្នឹងគឺនៅពេលនោះ ខ្ញុំត្រូវរបួសក្នុងឆ្នាំ ចុងឆ្នាំ១៩៧៣ របួសធ្ងន់ ក៏បានសែងយកទៅដាក់ពេទ្យនៅក្រាំងល្វា ក្នុងព្រៃក្រាំងល្វា ចន្លោះឱរ៉ាល ឬក៏អមលាំងហ្នឹង ក្នុងព្រៃក្រាំងល្វាហ្នឹង។ ពេលនោះឃើញខ្ញុំរាងធូរស្រាយហើយ ក៏ឃើញលោក តាម៉ុក ហើយនិងលោក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មា នួន ជា ហ្នឹងគាត់បានមកសួរសុខទុក្ខអ្នកជំងឺ មកលើកទឹកចិត្តអ្នកជំងឺ អ្នកត្រូវរបួសទាំងអស់ហ្នឹង។ ខ្ញុំក៏មិនបានស្គាល់ដែរ ក៏ប៉ុន្តែខ្ញុំស្គាល់នាយ គេហៅថានីរសារ កាលនោះនីរសារ តាម៉ុក ហ្នឹង ខ្ញុំក៏បានសួរ នីរសារ តាម៉ុក ហ្នឹងថា "បងណាគេដែលដើរមួយ បងម៉ុក ហ្នឹង?" កាលហ្នឹងហៅគេបង១។ ហើយ ដល់នីរសារដែលស្គាល់គ្នាហ្នឹង គាត់ឆ្លើយថា៖ "ហ្នឹងហើយ បងទី២ ហើយគាត់ជាអនុលេខាបក្សកុម្មុយ នីស្តកម្ពុជាផង។" ថាអ៊ីចឹង គាត់ឈ្មោះ ជា គេមិនបានប្រាប់ថា នួន ទេ ប្រាប់ថា "តាជា"។ បានខ្ញុំថា អំ អ៊ីចឹង។ ហើយខ្ញុំក៏មានការចំណាំទុកតាំងពីពេលនោះមក បាននៅបុរីកីឡាហ្នឹង ខ្ញុំបានឃើញគាត់ម្តង ទៀត។

[១៤:៥៣:៤៧]

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** សូមអរគុណ។ ពូបញ្ជាក់ថា ពូឃើញគាត់នៅពេលនោះ ថាតើក្រោយពេលពូឈរជាជួរ ឃើញហ្នឹង តើមានថ្នាក់ដឹកនាំគាត់និយាយពីស្អី ឬក៏ពូចាំសម្តី គាត់និយាយពីស្អីខ្លះទេ ពូនៅពេលនោះ?

**ឆ៖** រយៈក្នុងពេលដែលប្រជុំជួរនោះ ក្រោយពីលោកទាំងបីនាក់ លោក សុន សេន, លោក តា ម៉ុក ហើយលោកមា នួន ជា អីហ្នឹងហើយ លោកមា នួន ជា គាត់ជាអ្នកទទួលខុសត្រូវផ្នែកខាងឃោធា ហើយ ជាការពិត។ ហើយគាត់បានមានប្រសាសន៍ទៅលើ លើកទឹកចិត្តដោយពួកយើងខ្ញុំជិត១.០០០ នាក់នោះថា ដែលជាទ័ពចាស់ៗ។ ប៉ុណ្ណឹងបាទ លើកទឹកចិត្តខ្ញុំ។

**ស៖** តើពូមាននៅចាំសម្តីគាត់និយាយទេ ឬក៏គ្រាន់តែពូអាចនៅនឹកឃើញថា គាត់និយាយអីខ្លះ នៅពេលនោះ ដល់អតីតយុទ្ធជនដែលពូថាជាង១.០០០នាក់ដែលឈរជាជួរៗនោះ ពូនៅចាំខ្លះទេ?

**ឆ៖** ខ្ញុំដូចជាបានចាំខ្លះ មិនជាច្រើនទេ ប៉ុន្តែខ្ញុំចាំត្រង់កន្លែងចំណុចសំខាន់ៗ ខ្លះៗថា គាត់បាន លើកទឹកចិត្តដល់ពួកខ្ញុំថា "សមមិត្ត យុទ្ធមិត្ត ប្អូនៗជាទីស្រលាញ់របស់បក្ស! សមមិត្ត យុទ្ធមិត្ត ប្អូនៗ សុទ្ធសឹងជាអ្នកធ្លាប់បានប្រយុទ្ធច្បាំងជាមួយនឹងចក្រពត្តិអាមេរិកាំង និងឆ្កែបរិវារបម្រើដាច់ថ្លៃរបស់វា បានវាយដណ្តើមយកជ័យជម្នះនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ជូនបក្សបដិវត្តប្រជាជនយើង ធ្វើឲ្យល្បីរន្ទឺ ពាសពេញសកលលោក។ ក៏ប៉ុន្តែមកដល់ពេលឥឡូវនេះ អាខ្មាំងយួន វាបាន វាមិនអាចលះបង់នូវ មហិច្ឆតារបស់វា លោភលន់ចង់បាន នាំកម្ពុជាប្រជាធិបតេយ្យរបស់យើងចូលទៅក្នុងសហព័ន្ធឥណ្ឌូចិន របស់វាទេ។ វាបានលើកកងទ័ពរាប់សិបកងពល ហើយនិងបញ្ចូលនូវចារកម្មរបស់វាដើម្បីរំលោភឈ្លាន ពានមកលើទឹកដីកម្ពុជាប្រជាធិបតេយ្យយើងជាបន្តបន្ទាប់។ ក៏បានត្រូវកងទ័ពដ៏អង់អាចក្លាហានរបស់

យើងបានវាយបំបាក់ និងចាប់បានជាឈ្លើយជាច្រើននាក់។ ហេតុនេះបក្សយើងសង្ឃឹមជឿជាក់លើសមមិត្ត យុទ្ធមិត្ត ប្អូនៗទាំងអស់ ដាច់ខាតមិនអនុញ្ញាតឲ្យអាខ្មាំងយួនរំលោភឈ្លានពានបានទៀតជាដាច់ខាត។" ខ្ញុំចប់ប៉ុណ្ណឹងបាទ ចាំប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ ចុះក្រោយមកទៀត ក្រោយពេលចប់--

[១៤:៥៧:៣២]

**ប្រធានអង្គជំនុំ៖**

បាទ បានៗ! បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី និងដប់ប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៥៨ នាទី ដល់ម៉ោង ១៥:១៥ នាទី)*

[១៥:១៥:៤៤]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលសិទ្ធិ បន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី។

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** សូមអរគុណលោកប្រធាន។ បាទ នេះជាសំណួរចុងក្រោយរបស់ខ្ញុំហើយ។ មុនពេល

សម្រាក ពូបានឆ្លើយបញ្ជាក់ហើយថាក្រោយពេលលោក នួន ជា បានមានមតិលើកទឹកចិត្តដល់ក្រុមយុទ្ធជនរបស់ពូដែលមកចូលរួមនៅបុរីកីឡានោះ តើក្រោយពេលគាត់បញ្ចប់ តើគេបញ្ជូនពូទៅណាទៀត ឬមានហេតុការណ៍អីចំពោះក្រុមពូទៀតដែរទេ?

**2-TCCP-235៖**

**ឆ៖** នៅក្រោយបញ្ចប់ពីការលើកទឹកចិត្តរបស់លោកមា នួន ជា ក្តី, តាម៉ុក ហើយនិងទាំងអស់ហ្នឹង គេក៏រៀបចំចាត់ចែងបញ្ជូនពួកខ្ញុំហ្នឹងជាពីរផ្លូវ មួយចំនួនទៅឆ្លងអ្នកលឿង ឆ្លងសាឡាងអ្នកលឿង ហើយពួកខ្ញុំប្រហែលជា៤០០នាក់ហ្នឹង គេឲ្យឆ្លងសាឡាងនៅខាងជើងស្ពានជ្រោងចង្វារ ហើយនិងទៅឆ្លងទន្លេបិទ សាឡាងនៅទន្លេបិទទៀត។

[១៥:១៧:៥៩]

**ស៖** បាទ តើគេបញ្ជូនពូទៅខ្លួនទទេ ឬមួយបំពាក់ជាសម្ភារៈយោធាឲ្យដែរ ឬយ៉ាងម៉េចពូ?

**ឆ៖** ពេលនោះគេបញ្ជូនទៅខ្លួនទទេទេ ខោអាវធម្មតា មានរថយន្ត ហ្សេ.អឹម.សេ, រថយន្តអាហ្ស៊ីលចិនអីហ្នឹងដឹករថក្រោះ អឹម-សង់ត្រីអាមេរិកអីហ្នឹង ដឹកទ័ពហ្នឹងដាក់លើសាឡាងហ្នឹងឆ្លងរហូតទៅដល់ឆ្លងទន្លេបិទទៀត អាហ្នឹងពួកខ្ញុំ។ តែពួកខាងអ្នកលឿង គេទៅអ្នកលឿង ខ្ញុំអត់ដឹងដែរទេ ទៅប្រហែលជា៤០០នាក់ដែរ ទៅហ្នឹង។ ទៅដល់ ខ្ញុំឆ្លងពីទន្លេបិទទៅ ក៏ទៅដល់ គេហៅថាអគ្គសេនាធិការរង មាន តាពីន តែគាត់ទទួលខុសត្រូវនៅកន្លែងនោះ គឺនៅវត្តស្រះ នៅវត្តស្រះ តាពីន នៅទទួលខុសត្រូវនៅកន្លែងនោះ ហើយជាអគ្គសេនាធិការមួយ។ អាហ្នឹងហើយ សម្រាកនៅហ្នឹងមួយយប់ ព្រឹកឡើងម៉ោងប្រហែលជាប្រាំបីប្រាំបួន បានឃើញរថយន្តកាម៉ង់កាចិន មានដឹក សុន សេន ទីប្រឹក្សាចិនពីរនាក់ ហើយនិងអង្គរក្សបីបួនប្រាំឡានទៅដល់កន្លែងខ្ញុំហ្នឹង។

**លោក វ៉ែន ពៅ៖**

បាទ សូមអរគុណ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្តឹង។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្តាងលេះ**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំនឹងសួរលោកនៅរសៀលនេះ និងស្អែកព្រឹកទៀតផងដែរ។ ឥឡូវនេះខ្ញុំចង់ត្រឡប់មកសួរលោកពាក់ព័ន្ធនឹងបញ្ហាបរិបទបន្តិច។ ជាដំបូង គឺពាក់ព័ន្ធនឹងចម្លើយដែលលោកបានឆ្លើយថា លោកជាព្រះសង្ឃ គឺលោកបួសប្រហែលជាមួយឆ្នាំ នៅឆ្នាំ៧០ ដល់ឆ្នាំ៧១។ ពេលដែលគេផ្សឹកលោកជាមួយនឹងព្រះសង្ឃផ្សេងទៀត តើជនបដិវត្តទាំងអស់នោះ មានប្រាប់លោកទេថា ហេតុអីបានជាលោកត្រូវសឹក?

**2-TCCP-235៖**

**ឆ៖** កាលនោះគឺកងឈ្លបរបស់អង្គការបដិវត្តហ្នឹង គេប្រាប់ថាឲ្យសឹក ទៅតស៊ូវៃចក្រពត្តិអាមេរិកាំង ទៅវៃទាហានលន់ នល់អី ជាមួយគេនឹងឯង អ្អែងនៅធ្វើអីទៀត អាណាគេឲ្យបាយអ្អែងស៊ី។ អ៊ីចឹងក៏គេបណ្តេញឲ្យសឹក ដល់យើងមិនសឹក ក៏គេនៅតែមកថា ឲ្យសឹកទៅ។ ដល់ពេលយើងសឹកហើយគេ អាកងឈ្លបហ្នឹងគេបញ្ជូនកងឈ្លបរបស់អង្គការបដិវត្តហ្នឹង គេបញ្ជូនតាមខ្សែរយៈគេទៅលើៗទៅ ប៉ុណ្ណឹង។

**ស៖** ក្នុងពេលនោះ លោកគិតថា លោកមានជម្រើសក្នុងការប្រកែកមិនព្រមសឹកទេ?

[១៥:២២:០៦]

**ឆ៖** មិនអាចបានទេ។ មិនអាចប្រកែកថា មិនសឹកទេ គឺត្រូវតែសឹកតែម្តង។ បើមិនសឹក ក៏គេយកទៅទាំងព្រះសង្ឃហ្នឹងដែរ វាមានច្រើនហើយ គេយកទៅទាំងព្រះសង្ឃ ព្រះសង្ឃក្មេងៗ ចាស់ៗគេឲ្យនៅ គេមិនយកទេ យកតែក្មេងៗកាលនុ៎ង។

**ស៖** ឥឡូវនេះខ្ញុំទៅនិយាយពេលដែលលោកចូលទៅក្នុងកងពលលេខ១។ លោកអាចជម្រាបបានទេ ថាអ្នកណាជាមេបញ្ជាការកងពលលេខ១នេះ?

**ឆ៖** បាទ មេបញ្ជាការកងពលទី១ធំហ្នឹង គឺមេបញ្ជាការខ្ញុំហ្នឹង គឺមួយ ទី១ គឺស្នងការកងពលនោះគឺលោក សៀ ម៉េត ហើយបន្ទាប់មកមាន តាសឿង ហើយនិង តាសារី បីនាក់ ដែលសុទ្ធទទួលខុសត្រូវផ្នែកផ្សេងៗគ្នា។

**ស៖** ចុះអ្នកណាជាប្រធានកងវរសេនាតូច១៨០របស់លោក?

**ឆ៖** បង ប៊ុន ថេង ស្នងការកងវរៈ ប៊ុន ថេង ហើយនិងមេបញ្ជាការ ស៊ុត ហើយនិងមានម្នាក់

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ទៀតរងគឺ ឆាយ ហៅ លួន ដែលគាត់មកពីហាណូយ។

**ស៖** ចុះពេលនៅកំពង់សោម និងនៅកោះកុងហ្នឹង ប៊ុន ថេង ហ្នឹង គាត់នៅជាមេរបស់លោក រហូត មែនទេ?

**ឆ៖** គាត់ត្រូវគេចាប់ខ្លួនបាត់ តាំងពីទៅដល់ដំបូងម្ល៉េះ។ ពួកគាត់ហ្នឹងត្រូវគេចាប់ខ្លួនទាំងពីរនាក់ ទាំង ស៊ុត ហើយបើ ឆាយ ហៅ លួន នោះ គេចាប់ខ្លួនតាំងពី៧៥ មុនៗគេ បក្សចាប់ខ្លួន អង្គការបក្សចាប់ខ្លួន ហើយ បងស៊ុត, បងប៊ុន ថេង ហ្នឹងគាត់ត្រូវគេចាប់ខ្លួនក្រោយ។

[១៥:២៥:១៥]

**ស៖** មុននេះលោកឆ្លើយថា លោកស្គាល់ តាម៉ុក ច្បាស់។ លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា លោកជួប តាម៉ុក ហ្នឹងញឹកញាប់ប៉ុនណាដែរ ក្នុងចន្លោះពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥?

**ឆ៖** បាទ តាម៉ុក គឺជាមេបញ្ជាការក្នុងសមរភូមិផ្ទាល់ជាមួយកងពលទី១, ទី២, ទី៣ ហ្នឹងគឺ តាម៉ុក ហើយអ្នកក្តាប់ទាំងអស់ ហើយដៃគូគាត់ហ្នឹង គឺមានតែលោកមា នួនជា ទេ ខ្ញុំនិយាយមែន ហ្នឹង ដែលដៃគូ តាម៉ុក នោះ។ គេទុកចិត្ត តាម៉ុក ទុកចិត្តអីខ្លាំង តែ តាម៉ុក ព្រោះ តាម៉ុក គាត់ផ្នែកខាងយោធា តាំងពីគាត់នៅក្នុងសមរភូមិផ្ទាល់ក៏មានដែរបាទ កាលនោះ។ ខ្ញុំច្បាស់ណាស់អារឿង តាម៉ុក។ អាចារ្យ ឈឿន ហៅ តាម៉ុក។

**ស៖** ឥឡូវនេះខ្ញុំចូលទៅហេតុការណ៍ដែលកើតឡើងនៅពោធិ៍ចិនតុង។ ក្រោយវាយយកព្រលានយន្តហោះបាន លោកថា ទាហាន និងអ្នកបើកយន្តហោះហ្នឹងត្រូវបានគេចាប់ដាក់ទៅ នាំចេញទៅតាមឡាន។ ហើយមុននេះ ក៏លោកបាននិយាយថា លោកចង់ទាក់ទងប្អូនរបស់លោក។ ដូច្នេះខ្ញុំចង់សួរថា លោកអាចទាក់ទងគាត់យ៉ាងម៉េចបាន? ហើយលោករកឃើញគាត់ទេ ឬក៏រកឃើញតែមិត្តភក្តិរបស់គាត់ទេ?

[១៥:២៧:០៤]

**ឆ៖** បាទ មិនមែនប្អូនទេ បង។ បងបង្កើតរបស់ខ្ញុំដែលមានឈ្មោះថា អ៊ូ ដាន់។ គាត់ជាពីឡុតបើកយន្តហោះចម្បាំង អេលេកុបទ័រហ្នឹង បាញ់។ ហើយថាគេហៅកាលណោះគឺថា ខ្មែរៗ អាបងប្អូនឯងក៏វ៉ៃដែរ។ ហើយពេលដែលចូលទៅដល់ពោធិ៍ចិនតុងហ្នឹងគឺខ្ញុំ ដូចខ្ញុំជម្រាបពីមុនហើយជាមួយលោកមេធាវីថា ពេលនោះខ្ញុំដឹងច្បាស់ថា បងបង្កើតរបស់ខ្ញុំនៅពោធិ៍ចិនតុងហ្នឹង តាមរយៈវិទ្យុទាក់ទង ដឹងច្បាស់ថា នៅបើកយន្តហោះចម្បាំងនៅពោធិ៍ចិនតុងហ្នឹង។ ខ្ញុំក៏ចូលដល់ភ្លាម ខ្ញុំសង្វាតទៅរកគាត់ដើម្បី

ប្រាប់ដំណឹងឲ្យគាត់ដោះខោអាវសម្លៀកបំពាក់អីផ្សេងៗដែលគេហៅថា អ្នកបើយន្តហោះនោះ ហើយនិងមិត្តភក្តិគាត់ពីរនាក់ទៀត នៅជុំគ្នាហ្នឹង មិនមែនតែពីរនាក់ទេ គ្នាច្រើន។ ប៉ុន្តែមួយចំនួន ដោយមនុស្សពីស្រុកមក ម្នាក់នោះគាត់អត់ជឿទេ អត់ជឿខ្ញុំ គាត់ទៅតាមអង្គការ ទៅតាមពួកគេហ្នឹងទៅ។ ទៅនៅអង្គុយចាំ ទទួលអង្គការពេលនោះទៅ។ ឯបងរបស់ខ្ញុំហ្នឹង ខ្ញុំក៏បានជម្លៀសចេញ មិត្តភក្តិគាត់ពីរនាក់ហ្នឹង អត់មានឲ្យយកអីទេ។ ខ្ញុំថា មិនខ្វះទេខោអាវស៊ីវិល ទៅៗក្រៅទៅ។ ហើយស្រុកកំណើតប្រពន្ធណាទៅហ្នឹងទៅបងៗ។ អ៊ីចឹងនាំគាត់ចេញមកដល់របងពោធិ៍ចិនតុង ពីខាងកើត វាឆាកមកជើងបន្តិច។

**ស៖** អ៊ីចឹងលោកបានទៅជួបបងលោក ហើយលោកប្រាប់ថា កុំឲ្យជឿគេ។ តើលោកមានព័ត៌មានអ្វីខ្លះ បានជាលោកគិតថា នឹងមានហេតុការណ៍អាក្រក់កើតឡើងចំពោះបងប្រុសលោក ហើយនិងអតីតទាហានលន់នល់ ដែលឈរជើងនៅពោធិ៍ចិនតុងនោះ?

[១៥:២៩:៥៤]

**ឆ៖** បាទ ខ្ញុំដឹងថា តាមរយៈអង្គការបង្រៀននៅតាមអង្គភាព ទាំងមេបញ្ជាការបង្រៀនប្រាប់ថា មិនមែនបង្រៀនប្រាប់ថាទេ គឺជាសាធារណៈ និងនិយាយអ៊ីចឹងថា បើចូលទៅដល់ឲ្យតែអ្នកបើកយន្តហោះគឺបាញ់ចោលទាំងអស់ ឲ្យតែយើងបានចូលទៅដល់។ អាចំណុចត្រង់នេះហើយដែលខ្ញុំគិតថា យើងត្រូវតែមានការប្រាប់ទៅបងប្អូន ឬក៏បងបង្កើតខ្ញុំហ្នឹង បានទៅមិត្តភក្តិគាត់ហ្នឹងពីរនាក់ ហើយនិងបងបង្កើតខ្ញុំហ្នឹងម្នាក់ ហើយនិងអ្នកដទៃក៏ខ្ញុំប្រាប់ដែរ ប៉ុន្តែពួកគាត់មិនបានជឿលើខ្ញុំទេ។ បងប្អូន បងម្នាក់នោះនៅស្រុកខ្ញុំហ្នឹងអ៊ីចឹង ខ្ញុំថា "កុំទៅបង! កុំទៅនឹងគេ" "អញចង់ដឹងអាអូន អញទៅមើលមើល៍អង្គការ ឲ្យអញបើកយន្តហោះវិញ អញក៏បើកដែរ។" ខ្ញុំថា "បងឯងតែទៅ ខ្ញុំមិនធានាទេ អត់ដឹងទេ" ដល់អ៊ីចឹងទៅ ដល់ថ្ងៃក្រោយឡើង សួរទៅកូន ៗគាត់នៅរស់ពីរនាក់បីនាក់ ខ្ញុំថា "អ៊ីចឹងគាត់មិនជឿពូឯង បានអ៊ីចឹង បានឪពុកខ្ញុំ ប៉ាខ្ញុំស្លាប់។" អ៊ីចឹងហ្នឹងហើយ ប៉ុណ្ណឹង។

**ស៖** លោកជាសមាជិកវរសេនាតូច១៨០ ក្នុងកងពលលេខ១ ហើយលោកបានចូលធ្វើកងទ័ពហ្នឹង នៅឆ្នាំ៧១។ ហើយលោកមានបងប្រុសម្នាក់ធ្វើការនៅក្នុងកងទ័ព លន់ នល់។ តើមានអ្នកណាផ្សេងទៀតនៅក្នុងក្រុមគ្រួសារលោក ដែលធ្វើការនៅក្នុងរដ្ឋបាល ឬក៏នៅក្នុងកងទ័ពរបស់សាធារណរដ្ឋខ្មែរ ឬរបប លន់ នល់ ទេ?

[១៥:៣២:១៥]

**ឆ៖** បាទ មានបងបង្កើតពីរនាក់ទៀតនៅក្នុងតំបន់សាធារណរដ្ឋ លន់ នល់ ហ្នឹង។ បងបង្កើត

បី ទាំងអស់គឺបីគ្រួសារ ដែលនៅក្នុងរបបសាធារណរដ្ឋ លន់ នល់។

**ស៖** តើលោកមានបានលាក់បាំងថាមានបងប្អូនធ្វើការឲ្យរបប លន់ នល់ ជាទាហាន ឬក៏ជាអ្នករដ្ឋការទេ? <តើលោកត្រូវតែលាក់រឿងនេះ ពីកម្លាំងបដិវត្តន៍ដែរឬទេ?>

**ឆ៖** សួរចំណុចនេះគឺថា ឲ្យខ្ញុំឆ្លើយយ៉ាងណា បើខ្ញុំលាក់បាំងអំពីប្រវត្តិរូបរបស់អង្គការ ឬមួយក៏យ៉ាងម៉េច?

**ស៖** គឺនៅក្នុងចន្លោះឆ្នាំ៧១ រហូតទៅដល់ឆ្នាំ៧៩ហ្នឹង គឺនៅមុនរបបខ្មែរក្រហម ហើយនិងក្នុងរបបខ្មែរក្រហមហ្នឹង លោកមានលាក់មិនឲ្យគេដឹងទេថា លោកហ្នឹងមានបងប្អូនដែលធ្វើការជាទាហាន ឬក៏ជាមន្ត្រីរដ្ឋការក្នុងរបប លន់ នល់? ហើយប្រសិនជាលោកលាក់ហ្នឹង តើហេតុអ្វីបានជាលោកគិតថាត្រូវលាក់បាំងព័ត៌មានទាំងអស់ហ្នឹង?

**ឆ៖** ខ្ញុំសូមជម្រាបថា នៅពេលនោះនៅពេលដែលខ្ញុំធ្វើជាកងទ័ពអង្គការបដិវត្ត នោះគឺខ្ញុំមានការមិនមែនដាក់ឈ្មោះ 2-TCCP-235 ហ្នឹងទេ ដាក់ឈ្មោះ 2-TCCP-235 ហើយក៏មិនមែនដាក់នៅភូមិកំណើតរបស់ខ្លួនដែរ ព្រោះថាពេលនោះខ្ញុំដឹងថា គ្រាន់តែខ្ញុំចូលទៅគេបង្រៀនឲ្យធ្វើបដិវត្តន៍។ អង្គការគេបង្រៀនតាមរយៈមេបញ្ជាការអី ហៅប្រជុំជួរ រៀនសូត្រថា រៀនគឺរៀននោះគឺរៀននិយាយពីរឿងកុម្មុយនីស្តគឺថា តស៊ូ ធ្វើបដិវត្តន៍ដើម្បីវាយចក្រពត្តិអាមេរិកាំង និងឆ្កែបរិវារវាឲ្យបរាជ័យ វាយទាំងអស់សក្តិភូមិ នាយទុន ប្រតិកិរិយាអីហ្នឹង។ គេបង្រៀនបែងចែកវណ្ណភាពយ៉ាងណាអីណើ។ ខ្ញុំ ក្រោយមកខ្ញុំក៏ធ្វើប្រវត្តិរូបហ្នឹងលាក់ជាបន្តបន្ទាប់ ឪពុកក៏មិនដែលដាក់ឈ្មោះថាឪពុកការដែរ រហូតមក។ ហើយបងប្អូនហ្នឹងក៏ខ្ញុំអត់មាននិយាយថា មានបងប្អូនប៉ុន្មានៗអី ខ្ញុំមានថាតែបងប្អូនបង្កើតហ្នឹង មានតែពីរនាក់ប៉ុណ្ណឹង។

[១៥:៣៥:៥៧]

**ស៖** មុននេះលោកបាននិយាយថា មានសេចក្តីណែនាំដែលបានផ្សព្វផ្សាយតាមវិទ្យុថាត្រូវតែកម្ទេចទាហាន លន់ នល់។ ចុះ តាម៉ុក គាត់មានបាននិយាយអ្វីខ្លះពាក់ព័ន្ធនឹងជោគវាសនារបស់ទាហាន លន់ នល់ ដែលត្រូវបានបញ្ជូនតាមឡាន ហ្សេ.អឹម.សេ ចេញទៅហ្នឹងទេ?

**ឆ៖** តាម៉ុក គាត់អត់មាននិយាយអីទេ។ គាត់គ្រាន់ឲ្យនាំគ្នាឡើងឡានហ្នឹង បញ្ជូនទៅៗខាងលិចទៅ គេមានតែកុងគេបើក ៗហើយជូនទៅលិច មានអង្គរក្សអីជូនទៅតាមផ្លូវជាតិលេខ៤ ទៅហួសទៅលិចទៅ ៗខ្ញុំលែងដឹងហើយប៉ុណ្ណឹង។ ដឹងថា ឃើញថាគេបញ្ជូនទៅទិសខាងលិចហ្នឹង ចំនួនបីបួនគ្រឿង

រថយន្តហ្នឹង។

**ស៖** ឥឡូវខ្ញុំសូមអានសម្រង់មួយនៃកំណត់ហេតុស្តាប់ចម្លើយរបស់លោកគឺ <E319/23.3.42> ដើម្បីរំឮកការចងចាំរបស់លោក។ លោកនិយាយដូចតទៅនេះ នៅសំណួរចម្លើយលេខ៣៤ ហើយនិងបន្ទាប់ទៅទៀត ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស ពីព្រោះថាអត់មានជាភាសាបារាំងទេ។ ដូច្នេះខ្ញុំដកស្រង់សំណួរ៣៤៖ "តើលោកមានបានស្តាប់ពីឮទាហានដែលដឹកជញ្ជូនអ្នកទាំងនោះនូវអ្វីដែលកើតឡើងទៅដល់ប្រជាជនទាំងនោះទេ? ចម្លើយលេខ៣៤៖ តាម៉ុក ខ្លួនឯងបាននិយាយថាប្រជាជនទាំងអស់ហ្នឹងគឺត្រូវគេយកទៅកម្ទេចចោលហើយ។ សួរ៖ តើ តាម៉ុក និយាយហ្នឹងនៅពេលណា? ចម្លើយលេខ៣៥៖ តាម៉ុក និយាយពីបញ្ហានេះក្រោយពេលទាហាន លន់ នល់ ទាំងនោះឡើងចូលទៅក្នុងរថយន្តធំៗរួចហើយ។ សួរ៖ តើមេបញ្ជាការមកពីកងពលដទៃទៀតមានវត្តមាននៅជាមួយ តាម៉ុក ទេ? ចម្លើយរបស់លោកគឺលេខ៣៥៖ ស៊ូ ម៉េត និង មាស មុត នៅជាមួយ តាម៉ុក។ សួរ៖ តើគេដឹកប្រជាជនតាមរថយន្តធំហ្នឹងប៉ុន្មាននាក់ដែរ? ឆ្លើយ៖ គេដឹកក្នុងមួយឡានៗប្រហែល៣០ ទៅ៤០នាក់ ហើយឡានមួយៗគឺថាដឹកពេញៗតែម្តង។" បញ្ចប់ការដកស្រង់។

លោកដើមបណ្តឹងរដ្ឋប្បវេណីលោកនឹកឃើញទេ ព្រោះលោកឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេតនៃចៅក្រមអង្កេតដែលថា តាម៉ុក និយាយបានថា ពួកទាំងអស់នេះត្រូវបាននាំចេញទៅដើម្បីយកទៅកម្ទេច តើលោកចាំទេ នឹកឃើញទេលោក?

[១៥:៣៩:០៦]

**ឆ៖** ខ្ញុំភ្លេចដែរ មិនបានចាំទេ រឿងអស់ហ្នឹង។

**ស៖** ឥឡូវខ្ញុំចូលមកនិយាយអំពីកិច្ចប្រជុំនៅទីក្រុងភ្នំពេញវិញម្តង គឺនៅពេលដែលគេយកលោកពីកោះកុងតាមកប៉ាល់ រួចមកជិះឡានធំ ហើយក៏មកតាមរថភ្លើង។ តើលោកអាចជម្រាបជូនបានដែរឬទេ ថានៅឆ្នាំណា ហើយនៅរដូវណាដែរ ដែលពេលមកដល់ភ្នំពេញមកដល់បុរីកីឡាហ្នឹង?

**ឆ៖** រដូវដើមឆ្នាំ ពិសាខ ជេស្ឋ។

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំស្តាប់ចម្លើយលោកអត់ឮទេ តើលោកអាចឆ្លើយនឹងសំណួរខ្ញុំបានទេ ថានៅពេលណា នៅរដូវណា នៅឆ្នាំណាពេលដែលលោកមកដល់ទីក្រុងភ្នំពេញ? នៅពេលដែលលោករាងស្រួលខ្លួនបន្តិចហើយ ឆ្លើយបន្តបាន។

**ឆ៖** ដូចខ្ញុំបញ្ជាក់អីចឹងថា មកក្នុងរដូវដើមឆ្នាំ ១ខ្មែរ មកដល់បុរីកីឡាហ្នឹងប្រហែលជាក្នុងជាង

ពាក់កណ្ដាល បើពាក់កណ្ដាលខែ៦ ខែ៧ ក្នុងខែ៧ ខែ៨ហ្នឹងបាទ មកដល់បុរីកីឡាហ្នឹង។

**ស៖** តើលោកនៅចាំឆ្នាំដែរឬទេ? នៅឆ្នាំចុងក្រោយនៃរបបហ្នឹង ឬក៏សល់២ឆ្នាំទៀតបានរបបហ្នឹងរលំទៅកាលហ្នឹង?

**ឆ៖** ខ្ញុំអត់បានចាំសំណួរលោកទេអម្បាញ់មិញ ថាស្ដាប់អត់បានទេ។

[១៥:៤២:៣៣]

**ស៖** បាទ ខ្ញុំចង់ដឹងថាតើលោកនិយាយអំពីខែមិថុនា កក្កដា <សីហា> ឆ្នាំ១៩៧៧ ឬក៏ឆ្នាំ១៩៧៨ បានន័យថាមួយឆ្នាំកន្លះមុនពេលរបបកម្ពុជាប្រជាធិបតេយ្យរលំទៅ ឬក៏ពីរបីខែមុនពេលរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងរលំទេ គឺថាជិតដល់ពេលដែលវៀតណាមចូលមកប្រទេសកម្ពុជាហើយ?

**ឆ៖** បាទ ជាងពាក់កណ្ដាលឆ្នាំ១៩៧៧ ដែលគេបញ្ជូនខ្ញុំទៅបុរីកីឡាហ្នឹង អាហ្នឹង។

**ស៖** បាទ សូមអរគុណ។ មុនពេលមកដល់បុរីកីឡានោះ ពេលដែលលោកជិះចេញពីកោះកុងមកតាមកប៉ាល់ហ្នឹង តើគេមានប្រាប់លោកថាតើលោកត្រូវទៅណាដែរឬទេ? ហើយហេតុអីបានទៅណា? តើគេមានប្រាប់លោកពីមូលហេតុដែលត្រូវទៅសមរភូមិនៅបូព៌ាដែរឬទេ?

**ឆ៖** អត់មានប្រាប់ទេ គេអត់មានប្រាប់ខ្ញុំអីទេ គេគ្រាន់តែ ដូចខ្ញុំនិយាយអ៊ីចឹងគឺថាក្រោយពេលដែលការលើកទឹកចិត្តរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យហ្នឹង គេបែងចែកទៅតែម្ដង។ ទៅដល់វត្តស្រះ កន្លែងអគ្គសេនាធិការដែលមាន តាពីន នៅប្រចាំនៅទីនោះ។ ដូចខ្ញុំលើកឡើងថា ដល់ពេលម៉ោងប្រហែលជា -- នៅសម្រាកនោះមួយយប់ ម៉ោងប្រាំបួន -- សុន សេន ហើយ--

[១៥:៤៤:២៨]

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំសូមកាត់ផ្ដាច់លោកបន្តិច ព្រោះថាវាជាប្រធានបទមួយផ្សេងទៀតទេហ្នឹង។ ខ្ញុំសូមបញ្ជាប់លោកនៅលើចំណុចនេះ ព្រោះថាប្រធានបទហ្នឹង ខ្ញុំនឹងនិយាយនៅពេលក្រោយ ឥឡូវខ្ញុំនិយាយនៅកោះកុងដដែលទេ។ អ៊ីចឹងខ្ញុំចង់សួរលោកថាតើលោកមានបានទទួលព័ត៌មានអំពីអ្វីដែលលោកនឹងត្រូវធ្វើនៅពេលក្រោយដែរឬក៏អត់ទេ? លោកឆ្លើយថាអត់ហើយ។ អ៊ីចឹងនៅពេលដែលលោកនៅ ពេលដែលឡើងកប៉ាល់ហ្នឹង ដូចដែលឡើងកប៉ាល់អីហ្នឹង គេៗហើយក្រោយមកគេឲ្យឡើងជិះរថភ្លើងអីនោះ<ជាមួយមនុស្សច្រើនផ្សេងទៀត គឺវានៅមុនពេលដែលលោកត្រូវបានគេចាប់ខ្លួន និងឲ្យធ្វើការងារ> តើពេលហ្នឹង លោកមានខ្លាចដែរឬទេ នៅពេលដែលដឹងថា គេយកលោកទៅឆ្ងាយពីកោះកុងហ្នឹង មានអារម្មណ៍អីមួយភ័យខ្លាចទេ?

**ឆ៖** កាលពីដំបូងខ្ញុំព្រួយបារម្ភដែរ។ ព្រួយបារម្ភថា ប្រហែលជាគេយកខ្ញុំទៅដាក់គុកកន្លែងថ្មីគុកកន្លែងថ្មីនៅភ្នំពេញនេះ ឬក៏នៅកន្លែងណា។ ប៉ុន្តែដល់ពេលមកដល់វាលរេញ បានទើបខ្ញុំដឹងថា ប្រហែលជាគេមិនយកទៅដាក់គុកទេ តែមិនដឹងថាបញ្ជូនទៅណាទេ គ្រាន់តែដឹងថា ឃើញមិត្តយើង សមមិត្តយើង យុទ្ធមិត្តយើងច្រើនអ្នកឡើងរថភ្លើងហ្នឹង បានខ្ញុំហាក់បីដូចមិនមានការព្រួយបារម្ភទេពេលនោះ។

**ស៖** និយាយអំពីរថភ្លើងហ្នឹង តើអ្នកដែលឡើងជិះលើរថភ្លើងទាំងអស់ហ្នឹង ត្រូវបានគេនាំទៅបុរីកីឡាដែរឬទេ?

[១៥:៤៦:៣៦]

**ឆ៖** បាទ នាំទៅបុរីកីឡាទាំងអស់តែគ្នា។ ទៅស្នាក់នៅអគារ មានអគារខ្ញុំនៅ អគារបីជាន់។ អគារបីជាន់ ខ្ញុំនៅ ឡើងទៅអគារខ្ពស់ជាងគេ អាទី៣។

**ស៖** ពេលដែលទៅដល់បុរីកីឡាហើយហ្នឹង តើអ្នកដែលនៅជុំវិញលោកនោះ សុទ្ធតែជាយោធាទាំងអស់ ឬក៏ជនស៊ីវិលទេ?

**ឆ៖** បើតាមខ្ញុំមើល ឃើញថា សួរសាកទៅ ថានៅកងណាកងណី មានអ្នកខ្លះគឺគ្នាធ្វើកងចល័តអ្នកខ្លះក៏កងទ័ពស្រុក តំបន់ ហើយផ្សេងៗអ៊ីចឹងទៅ។ ហ្នឹងខ្ញុំសួរ។

**ស៖** តើមានស្ត្រី ឬក៏កុមារៗ ឬក៏ក្មេងៗនោះ នៅក្នុងចំណោមអ្នកទាំងអស់នុ៎ងដែរឬទេ?

**ឆ៖** មិនជាមានទេ ច្រើនតែមនុស្សដែលពេញវ័យ ប៉ុន្តែទៅដល់វត្តស្រះនោះ បានក្មេងៗច្រើន។

**ស៖** អំមិញលោកនិយាយថា នៅពេលដែលគេឲ្យលោកមើលកុនពេលយប់ អំពីសង្គ្រាមរវាងប្រទេសចិននិងប្រទេសជប៉ុននោះ តើលោកមានដឹងថា គេឲ្យលោកមើលកុនហ្នឹងក្នុងបំណងអីដែរឬទេ?

**ឆ៖** បាទ កុន ខ្សែភាពយន្តឯកសាររបស់ចិនហ្នឹង គេបញ្ចាំងឲ្យមើលរហូតដល់ចប់រឿងជប៉ុនច្បាំងជាមួយចិនហ្នឹង។ ហើយខ្ញុំក៏មើលឃើញថា ខ្ញុំគិតថា រូបខ្ញុំ និងមិត្តយើងទាំងអស់ហ្នឹង ប្រហែលជាគេបញ្ជូនឲ្យទៅច្បាំងជាមួយប្រទេសណាមួយមិនខានទេ។ នេះខ្ញុំគិតថាអ៊ីចឹងហើយ។ ខ្ញុំគិត មើលឃើញហើយ ខ្ញុំពិចារណា ថាប្រហែលជាត្រូវគេបញ្ជូនឲ្យទៅច្បាំងនៅប្រទេសណាមួយ មិនខាន។ ប៉ុណ្ណឹង។

[១៥:៤៩:៤៨]

**ស៖** អម្បាញ់មិញនេះ លោកបាននិយាយថា លោកបានស្គាល់ នួន ជា រួចហើយ នៅឆ្នាំ១៩៧៣ នៅពេលដែលគាត់មកជាមួយ តាម៉ុក ដើម្បីធ្វើទស្សនកិច្ចនៅមន្ទីរពេទ្យដែលលោកទទួលរងគ្រោះថ្នាក់របួសកាលនុ៎ង។ ក៏ប៉ុន្តែនៅក្នុងទម្រង់បែបបទព័ត៌មានបន្ថែមរបស់លោកគឺឯកសារ <E3/5979a>

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទំព័រជាភាសាបារាំងគឺ 01190877 រហូតដល់ 78, ជាភាសាអង់គ្លេសគឺ 00865686, ជាភាសាខ្មែរគឺ 00578510។ លោកបានលើកឡើងពីឈ្មោះ ខៀវ សំផន ដែរនៅកន្លែងនេះ។ តើលោកបានឃើញគាត់នៅឆ្នាំ១៩៧៣ ដែរ ឬក៏ជាកំហុសទេ នៅក្នុងទម្រង់បែបបទព័ត៌មានបន្ថែមរបស់លោកនេះ?

**ឆ៖** ខ្ញុំអត់ដែលបានឃើញផ្ទាល់សោះ អត់ដែលបានឃើញ។ លោកមា ខៀវ សំផន គឺខ្ញុំមិនដែលបានឃើញគាត់ទេ គ្រាន់តែឮតែសម្ដីតែប៉ុណ្ណោះ។

**ស៖** អ៊ីចឹងនៅពេលដែលលោកនិយាយថា លោកបានស្ដាប់សុន្ទរកថាគាត់នោះ លោកចង់និយាយថា លោកបានស្ដាប់សុន្ទរកថាគាត់ហ្នឹងតាមវិទ្យុទេ ឬក៏យ៉ាងម៉េច? ឬក៏នៅក្នុងឱកាសណាមួយនៅពេលណាមួយលោកបានស្ដាប់សុន្ទរកថារបស់គាត់ហ្នឹង?

**ឆ៖** ខ្ញុំស្ដាប់សំឡេងរបស់លោក ខៀវ សំផន ហ្នឹងគឺតាមវិទ្យុ ស្ដាប់តាមវិទ្យុៗផ្សព្វផ្សាយ។ វិទ្យុគាត់ផ្សព្វផ្សាយអំពីអ្វីដែលនៅក្នុងឆ្នាំ៧៥, ៧៦អីហ្នឹងខ្ញុំឮ នៅក្នុងឆ្នាំ៧៦ ច្បាស់តែនៅក្នុងឆ្នាំ៧៦ ខ្ញុំបានស្ដាប់សំឡេងរបស់មា ខៀវ សំផន ហ្នឹងគាត់បាននិយាយ បាននិយាយតាមវិទ្យុ។

**ស៖** តើលោកមានចាំអំពីកម្មវិធីផ្សព្វផ្សាយហ្នឹងទេ? ហើយខ្លឹមសារនៃការនិយាយរបស់គាត់ហ្នឹង យ៉ាងម៉េចដែរ?

[១៥:៥៣:១២]

**ឆ៖** គាត់និយាយប្រកាសៗជាសេចក្ដី គាត់និយាយគឺសុទ្ធតែពាក្យល្អៗទាំងអស់ហ្នឹង។ គាត់ដូចជារបបអង្ករ ដល់ប្រជាជនកម្ពុជាទូទៅគឺ ដូចជារបបអង្ករអីហ្នឹង ថាក្នុងមួយនាក់ ទទួលបានមួយកំប៉ុងកន្លះ ឬពីរកំប៉ុង នៅពេលដែលគាត់ប្រកាសអ៊ីចឹង។ ហើយគាត់ប្រកាសប្រាប់តាមវិទ្យុអ៊ីចឹង ក្នុង១ថ្ងៃក្នុងម្នាក់ បងប្អូនប្រជាជនទូទាំងប្រទេសហ្នឹង។

**ស៖** តើពេលដែលលោកស្ដាប់សុន្ទរកថាគាត់ហ្នឹង គឺលោកនៅកំពង់សោម នៅឆ្នាំ១៩៧៥ ឬក៏ពេលហ្នឹងលោកបានចេញពីកំពង់សោមទៅកន្លែងផ្សេងបាត់ទៅហើយ?

**ឆ៖** ក្នុងរយៈកាលដែលរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងកើតឡើងភ្លាម គាត់និយាយ ប៉ុន្តែខ្ញុំវាមិនអាចចាំបានទេ កាលនោះខ្ញុំស្ដាប់វ៉ាដ្យូ ខ្ញុំតាមដានវ៉ាដ្យូ។ ភាគច្រើនគេចាក់ចម្រៀងអ៊ីចឹងក្នុងវ៉ាដ្យូហ្នឹង ហើយនិងសេចក្ដីថ្លែងការណ៍អីផ្សេងៗ អ៊ីចឹងបាទ។

**ស៖** លោកមានវិទ្យុមួយ អង្កាល់ហ្នឹងនៅឆ្នាំ១៩៧៥ ពីដំបូងលោកនៅពោធិ៍ចិនតុង ក្រោយមកទៅកំពង់សោម។ អ៊ីចឹងមុនពេលដែលគេចាប់ខ្លួនលោកនោះ តើលោកជាបក្ខជនបក្សកុម្មុយនីស្តកម្ពុជា

ឬក៏លោកជាសមាជិកយុវកកកាលនុ៎ង?

**ឆ៖** ខ្ញុំជាសមាជិកយុវកកហើយ ជនចម្រើន ដែលអ្នកសមាជិកយុវជនយុវកក សម្ព័ន្ធយុវកក។

**ស៖** អម្បាញ់មិញលោកបាននិយាយថា នៅក្នុងសុន្ទរកថារបស់ នួន ជា ហ្នឹងលោកនិយាយថា នួន ជា ជាអ្នកទទួលបន្ទុកខាងយោធា ទទួលខុសត្រូវខាងយោធា។ អ៊ីចឹងតើលោកម៉េចបានលោកដឹងថា អ៊ីចឹង? ហើយអ្នកណាអ្នកប្រាប់លោកអំពីតួនាទីរបស់ នួន ជា នៅក្នុងកងទ័ព?

[១៥:៥៦:២៨]

**ឆ៖** នេះខ្ញុំបានយល់យ៉ាងច្បាស់ ព្រោះអីគាត់ លោកមា នួន ជា ហ្នឹងគាត់ជាអនុលេខាបក្សតាំងពីអើយមកម្ល៉េះបាទ អនុលេខាបក្ស។ ហើយបើអ៊ីចឹងអនុលេខបក្សហ្នឹង គឺត្រូវតែមើលខុសត្រូវទៅលើផ្នែកយោធា ច្រើនយ៉ាងណាស់ ហើយនិងសេដ្ឋកិច្ចអីអ៊ីចឹង។

**ស៖** លោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាអ្នកណាអ្នកប្រាប់លោក<ថា> នួន ជា ហ្នឹងគាត់មានតួនាទីខាងយោធាហ្នឹង អ្នកណាប្រាប់លោក? តើលោកបានព័ត៌មានហ្នឹងមកពីណាដែរ?

**ឆ៖** មានកាលនោះគឺខ្ញុំ ដូចខ្ញុំបញ្ជាក់អ៊ីចឹង។ កាលខ្ញុំត្រូវរបួសហ្នឹង ហើយខ្ញុំសួរនីរសារ ៗរបស់តាម៉ុក ដែលស្គាល់គ្នាជាមួយខ្ញុំហ្នឹង ខ្ញុំសួរទៅពួកគេ។ គេឆ្លើយអ៊ីចឹង គេថា បងធំទី២ អនុលេខាបក្ស ហើយជាអង្គការជាន់ខ្ពស់មួយរូប អង្គការជាន់ខ្ពស់មួយ អ៊ីចឹង។ ហើយខ្ញុំចំណាំកត់ជារឿងរហូតមក ហើយគាត់ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជាកាលនុ៎ង។

**ស៖** កាលនៅឆ្នាំ១៩៧៣ហ្នឹង លោកបានព័ត៌មានហ្នឹងនៅពេលហ្នឹង ដឹងពេលហ្នឹង <គឺនៅពេលដែលលោករងរបួសហ្នឹង> ឬក៏ក្រោយមកហើយទេ បានលោកដឹងព័ត៌មានទាំងអស់ហ្នឹង?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំអាចជួយទៅដល់សហព្រះរាជអាជ្ញាបាន <យើងបានទទួលស្គាល់>ច្រើនលើកច្រើនសាហើយដែលថា នួន ជា គឺ<ជា>អនុលេខាបក្សកុម្មុយនីស្តកម្ពុជា ហើយ<>គាត់ហ្នឹងបានដើរតួយ៉ាងសំខាន់ពាក់ព័ន្ធទៅនឹងគោលនយោបាយ<បក្ស> គាត់ឡើងនិយាយ ឡើងបង្រៀននៅបុរីកីឡា។ ហើយយើងខ្ញុំ<រីករាយក្នុងការយោង>បង្ហាញទៅ<អង្គជំនុំជម្រះ អំពីសារណាបណ្តឹងឧទ្ធរណ៍របស់យើង, សារណាបញ្ចប់កិច្ចសួរដេញដោលរបស់យើង។ វាប្រហែលជួយឱ្យ>ដំណើរការទៅលឿន។

[១៥:៥៩:១៦]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ ខ្ញុំសុំអរគុណមេធាវីការពារ។ សំណួររបស់ខ្ញុំសួរទាក់ទងនឹងទំនួលខុសត្រូវរបស់ នួន ជា ផ្នែកយោធា។ អ៊ីចឹងខ្ញុំមានសិទ្ធិចំណុចនេះ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្វាងលេ៖**

**ស៖** អ៊ីចឹងខ្ញុំសួរលោក ថាតើ<>លោកដឹងអំពីតួនាទីរបស់<បងទី២ នៅក្នុងយោធា និងសេដ្ឋកិច្ច ដោយរបៀបណា>? ហើយលោកបានឆ្លើយអម្បាញ់មិញនេះ ថានីរសាររបស់ តាម៉ុក ប្រាប់លោក <អំពីរឿងហ្នឹង>កាលដែលលោករបួស <តើវា>នៅឆ្នាំ១៩៧៣ <នៅពេលដែលរបួស ឬលោកបានឮរឿងហ្នឹងនៅក្រោយ>ឆ្នាំ៧៥ហើយទេ បានលោកដឹងថា នួន ជា ធ្វើអីៗនុ៎ងណ៎ា?

**2-TCCP-235៖**

**ឆ៖** បាទ គាត់ប្រាប់កាលនុ៎ង កាលខ្ញុំត្រូវរបួស។ ពួកគេប្រាប់ខ្ញុំ ខ្ញុំសួរ ជជីកសួរ។

**ស៖** សំណួរចុងក្រោយមុនពេលសម្រាកលោកប្រធាន។ ខ្ញុំមានសំណួរផ្សេងទៀតនៅសម្រាប់ពេលស្អែក។ តើអ្នកណានិយាយពី -- នៅពេលដែលប្រជុំនៅបុរីកីឡាហ្នឹង តាម៉ុក, នួន ជា, សុន សេន អីហ្នឹង ក្នុងចំណោមទាំងបីនាក់ហ្នឹង អ្នកណាអ្នកធ្វើបទឧទ្ទេសនាមមុនគេ?

**ឆ៖** ខ្ញុំសន្និដ្ឋានយ៉ាងច្បាស់ថា ពិតជាលោកមា នួន ជា គាត់បានលើកឡើង លើកទឹកចិត្តពួកខ្ញុំកាលហ្នឹង។

[១៦:០១:០៩]

**ប្រធានអង្គជំនុំ៖**

សវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅស្អែកថ្ងៃសុក្រ ទី១១ ខែវិច្ឆិកា ឆ្នាំ ២០១៦ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-235 បញ្ចប់ សូមភាគីជ្រាប និងអញ្ជើញចូលរួមបានតាមពេលវេលាកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី។ សវនាការស្ដាប់សក្ខីកម្មរបស់លោកនៅថ្ងៃនេះមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។

ហើយឲ្យមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ វិលទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅ និងឲ្យអញ្ជើញគាត់

ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកទៀត។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*